ទស្សនាវដ្តីដែលផ្សព្វផ្សាយឯកសារកម្ពុជា

# ស្វែងរក ការពិត



- សីលធម៌ប្រការ៦
- វីរលោកស្ត្រីដែលជាឡើងកម្មករ

លេខ០០៣ ខែមីនា ឆ្នាំ២០០០

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៥ ខែមីនា ឆ្នាំ២០០១

## មាតិកា

◆សំបុត្រៈ សីលធម៌ប្រការទី៦ ..... ១

**ផ្នែកឯកសារ**

◆រំលោភស្រ្តីដែលជាខ្មាំងអង្គការ ..... ២

◆អតីតយុទ្ធជននៃសោទត្រី ..... ៦

◆សុន្ទរកថារបស់ឯកឧត្តម សុខ អាន ..... ៨

◆តើគោរពអង្គការវិន័យរបស់បក្សគឺគោរពអ្វី? ..... ១០

◆រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម ..... ១២

**ផ្នែកប្រវត្តិសាស្រ្តនិងការស្រាវជ្រាវ**

◆ករណីអ្នកទោស ម៉ាន ម៉ាត់ ..... ១៦

◆សម្លេងពីមន្ទីរ ស-២១ ..... ១៩

◆ជនដែលរួចជនរងគ្រោះ ..... ២៤

◆ការស្រាវជ្រាវតាមរយៈរូបថត ..... ២៨

◆រង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ..... ៣២

**ផ្នែកច្បាប់**

◆គំរូមួយនៃភស្តុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់ ..... ៣៦

◆ការរើសអើងប្រឆាំងនឹងជនជាតិភាគតិច ..... ៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆ខៀវ សំផនៈ សង្គមបាក់បែក ..... ៤២

◆កំណត់ហេតុស្តីពីអង្គប្រជុំសភាជាតិ ..... ៤៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ទទួលបានប៉ុនណា បាត់ទៅវិញប៉ុណ្ណឹង ..... ៥៤

◆សៀវភៅកំណត់ហេតុជីវិត ..... ៥៨

**សិល្បៈខ្មែរក្រហម**

◆**រូបថតៈ** ហួត បុប្ផាណា ..... ក្របក្រោយ



ហេង យ៉ុន

កងការពារ



ឡុង រី



ឡាង នឿន

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្រ្តី និងរដ្ឋមន្រ្តីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ** ដេវីត ឆេនដល័រ, ស៊ីវ ហេឌ័រ, អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ម៉ារី ម៉ាទីន, យិមស៊ុត រ៉ាណាជិត, អ៊ីសា ឧស្មាន, ហ៊ុយ វណ្ណៈ, អៀ ម៉េងទ្រី, ផេង ពង្សរ៉ាស៊ី, **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃីម **និពន្ធនាយករងទី១ៈ** ផាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

**សំបុត្រៈ**

# សីលធម៌ ប្រការទី៦

សីលធម៌១២ប្រការរបស់ជនបដិវត្តជាក្រឹត្យវិន័យរបស់បក្សដែលជនបដិវត្តគ្រប់រូបត្រូវតែគោរពអនុវត្តតាមគ្រប់ "ប្រការ" ដោយជ្រួតជ្រាបនិងភ្ជាក់រឭកដើម្បីកសាងខ្លួនឲ្យទៅជាជនបដិវត្តល្អបរិសុទ្ធផូរផង់ អាចវាយសម្រុកបំពេញភារកិច្ចបដិវត្តន៍តូចធំជាផលប្រយោជន៍របស់ប្រទេសជាតិ ប្រជាជន បក្ស និងវណ្ណៈក្រីក្រ ។ នៅក្នុងទស្សនាវដ្ដី "យុវជននិងយុវនារីបដិវត្តន៍" លេខ១០ ខែតុលា ឆ្នាំ១៩៧៨ នៃរបបកម្ពុជាប្រជាធិបតេយ្យ ចែងអំពីសីលធម៌១២ប្រការរបស់ជនបដិវត្តដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦៨ ។ សីលធម៌ទាំង១២ប្រការនេះមាន ÷

១) ស្រឡាញ់ គោរព ហើយបម្រើប្រជាជន កម្មករ-កសិករជាប់ជានិច្ច ។

២) នៅកន្លែងណាបម្រើប្រជាជននៅកន្លែងនោះឲ្យអស់ពីចិត្តពីថ្លើម ។

៣) មិនធ្វើអ្វីដែលប៉ះពាល់ដល់ប្រជាជនឲ្យសោះ ទោះជាម្ទេសមួយដើម ឬសម្ដីមួយម៉ាត់ក្ដី ។

៤) បើមានការខុសឆ្គងអីពីប្រជាជន ត្រូវសុំទោសប្រជាជន បើមានធ្វើអ្វីឲ្យខូចខាតដល់ប្រជាជន ត្រូវសងប្រជាជនវិញ ។

៥) និយាយស្ដី ដេកដើរ ឈរអង្គុយ ស៊ីចុក ស្លៀកពាក់ លេងសើច តាមសភាពប្រជាជន ។

**៦) កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ ។**

៧) កុំផឹកស៊ីអ្វីដែលមានលក្ខណៈមិនបដិវត្តឲ្យសោះ ។

៨) កុំលេងល្បែងស៊ីសងឲ្យសោះ ។

៩) កុំប៉ះពាល់លុយកាក់រួម ទ្រព្យសម្បត្តិរួម ទោះជាប្រាក់១រៀលក្ដី អង្ករ១កំប៉ុង ឬថ្នាំ១គ្រាប់ក្ដី ។

១០) សុភាពរាបសាជាប់ខាតចំពោះប្រជាជន តែមានកំហឹងឆាបឆេះជានិច្ចចំពោះខ្មាំង ។

១១) ស្រឡាញ់ហើយធ្វើពលិកម្មជានិច្ច ។

១២) ប្រយុទ្ធនឹងខ្មាំង ប្រយុទ្ធនឹងឧបសគ្គដោយអង់អាច ហើយហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាងជូនប្រជាជនកម្មករ-កសិករ ជូនបក្ស ជូនបដិវត្តន៍ ដោយឥតលក្ខខណ្ឌ ក្នុងគ្រប់កាលៈទេសៈ ។

**កញ្ញា សាន់ កល្យាណ**

សីលធម៌ប្រការទី៦សម្រាប់កម្មាភិបាលនិងយុទ្ធជនខ្មែរក្រហមទាំងអស់គឺ "កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ" ។ អំពើ "ខុសសីលធម៌" រវាងភេទនៅក្នុងរបបខ្មែរក្រហមគឺមានទោសកម្ទេចចោល ។ ខ្ញុំបាទផ្ទាល់ជាសាក្សីផ្ទាល់ភ្នែកចំពោះបុរសស្ត្រីមួយគូដែលត្រូវបានសម្លាប់ចោលនៅកណ្ដាលអង្គប្រជុំថ្នាក់ឃុំមួយនៅវត្តព្រះនេត្រព្រះ ខេត្តបាត់ដំបងពីបទ "រួមរក្ស" ដោយគ្មានការអនុញ្ញាតពីអង្គការ ។

មានឯកសារជាច្រើនដែលយ៉ាងហោចណាស់អាចបង្ហាញឲ្យឃើញថាមានចំនួន១៥៦ករណីស្ដីអំពីកម្មាភិបាលខ្មែរក្រហមដែលបានរំលោភស្ត្រីនៅតាមភូមិ សហករណ៍ និងមន្ទីរឃុំឃាំង ។ កម្មាភិបាលទាំងនោះមិនបានទទួលទោស "កម្ទេចចោល" ពីអង្គការថ្នាក់លើទេ ។ ប៉ុន្តែផ្ទុយទៅវិញ ស្ត្រីជាច្រើនត្រូវបានយកទៅកម្ទេចចោលពីបទបម្រើ "សេ.អ៊ី.អា" "កាហ្សេបេ" ឬជា "ខ្មាំង" របស់អង្គការ បន្ទាប់ពីត្រូវបានកម្មាភិបាលខ្មែរក្រហមរំលោភរួចហើយ ។ ស្ត្រីរងគ្រោះដែលបានបាត់បង់ជីវិត ត្រូវបានចាត់ទុកនៅក្នុងប្រភេទបញ្ជី "សម្អាតខ្មាំងផ្ទៃក្នុង" ដើម្បីកសាង "សង្គមបរិសុទ្ធ" របស់ខ្មែរក្រហម ។

សាច់ញាតិនៃស្ត្រីរងគ្រោះដែលកំពុងមានជីវិតរស់នៅសព្វថ្ងៃគឺជាសាក្សីនៃរឿងរ៉ាវទាំងអស់នោះ ។ ឯកសារខ្មែរក្រហមផ្ទាល់ក៏បានកត់ត្រាទុកពីសកម្មភាព "រំលោភ" ដោយកម្មាភិបាលរបស់ខ្លួនដែរ ។

តើអ្វីទៅដែលជាយុត្តិធម៌សម្រាប់ស្ត្រីរងគ្រោះ? ការពិនិត្យឡើងវិញទៅលើគោលនយោបាយ "ខុសសីលធម៌" នៃរបបកម្ពុជាប្រជាធិបតេយ្យគឺមានសារសំខាន់ណាស់មិនត្រឹមតែជាការស្វែងរកការពិតនិងយុត្តិធម៌តែប៉ុណ្ណោះទេ ប៉ុន្តែគឺជាការគោរពដល់វិញ្ញាណក្ខន្ធស្ត្រីដែលបានទទួលរងនូវអំពើរំលោភព្រៃផ្សៃ ហើយក៏ជាការគោរពចំពោះស្ត្រីដែលរស់រានមានជីវិត ហើយដែលគឺជាអ្នកកសាងប្រទេសឡើងវិញនៅក្រោយពេលរបបខ្មែរក្រហមបានដួលរលំទៅក្នុងឆ្នាំ១៩៧៩ ។

ចម្លើយពិតប្រាកដទាំងស្រុងមួយត្រូវតែបានផ្ដល់ដល់ស្ត្រីកម្ពុជា ។

**ឆាំង យុ**

# រំលោភស្ត្រីដែលជាខ្មាំងអង្គការ

នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ គោលបំណងរបស់របបនេះគឺដើម្បីសម្រេចឲ្យបាននូវបដិវត្តន៍កុម្មុយនិស្តដោយប្រែក្លាយប្រទេសកម្ពុជាទាំងស្រុងទៅជាសង្គមមួយដែលលះបង់យ៉ាងខ្លាំងក្លាដល់ការបង្កើនផលិតផលកសិកម្ម ។ រាល់ការប្រឹងប្រែងទាំងអស់គឺដើម្បីសម្រេចគោលដៅនេះ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទំនាក់ទំនងរវាងសមាជិកគ្រួសារនិងមនុស្សដែលមានភេទខុសគ្នា (ស្ត្រីនិងបុរស) គឺបង្កជាការគំរាមកំហែងមួយចំពោះសង្គម ។ ច្បាប់ត្រូវបានបង្កើតឡើងដើម្បីហាមប្រាមការទាក់ទងគ្នារវាងសមាជិកដែលមានភេទខុសគ្នា ។ របបកម្ពុជាប្រជាធិបតេយ្យមានជំនឿថាក្នុងការអនុញ្ញាតឲ្យមានទំនាក់ទំនងរវាងស្ត្រី និងបុរសក្នុងផ្លូវភេទអាចធ្វើឲ្យប្រជាជនបែងចែកអារម្មណ៍ពីការងារបដិវត្តន៍ និងការលះបង់ចំពោះអង្គការ ។ ជនទាំងឡាយណាប៉ុនប៉ងបង្កើតឲ្យមានទំនាក់ទំនងរវាងសមាជិកដែលមានភេទផ្ទុយគ្នា ត្រូវបានចាត់ទុកថា "ខុសសីលធម៌" ហើយត្រូវទទួលពិន័យយ៉ាងធ្ងន់ធ្ងរ ។នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាមានច្បាប់ដើម្បីទប់ស្កាត់ប្រជាជនទូទៅកុំឲ្យមានទំនាក់ទំនងទៅវិញទៅមកយ៉ាងណាក៏ដោយក៏ច្បាប់នេះមិនបានទប់ស្កាត់កម្មាភិបាលខ្មែរក្រហមពីការទាញយកផលប្រយោជន៍លើផ្លូវភេទពីស្ត្រីបានដែរ ។ អត្ថបទនេះជាការសង្ខេបអំពីការសិក្សាមួយ និងឆ្លុះបញ្ចាំងទៅលើរបៀបនៃការអនុវត្តច្បាប់នៃរបបកម្ពុជាប្រជាធិបតេយ្យដើម្បីកាត់បន្ថយសកម្មភាពផ្លូវភេទ និងដើម្បីបង្កើតឲ្យមានសង្គមដ៏ស្អាតស្អំមួយដែលផ្តោតការយកចិត្តទុកដាក់ទៅលើផលិតផលកសិកម្ម ។ ទង្វើនេះទទួលបានជោគជ័យក្នុងការធ្វើឲ្យស្ត្រីរឹតតែឆាប់ទទួលរងពីការបំពានខាងផ្លូវភេទ ។

សម្រាប់របបកម្ពុជាប្រជាធិបតេយ្យមាន "សីលធម៌" គឺមានន័យថា ប្រតិបត្តិទៅតាមច្បាប់និងគោលបំណងរបស់បដិវត្តន៍ ។ ការប្រកាន់ខ្ជាប់សីលធម៌គឺមានន័យថាមានការប្រុងប្រយ័ត្ននិងយកចិត្តទុកដាក់ ដើម្បីប្រឹងធ្វើការងារជូនបដិវត្តន៍ ជូនអង្គការ និងបូជាការរីករាយនិងផលប្រយោជន៍ផ្ទាល់ខ្លួនដើម្បីផលប្រយោជន៍សមូហភាព ។ នៅក្នុងក្រមសីលធម៌ទាំង១២ប្រការ របស់ជនបដិវត្តន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ បានរាយចំណុចសីលធម៌ដែលយុទ្ធជនត្រូវបានរំពឹងថានឹងគោរពតាម ។ ទោះបីជាក្រមសីលធម៌ទាំងនេះគាត់តែងឡើងសម្រាប់តែយុទ្ធជន ក៏ក្រមសីលធម៌ទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញនូវអ្វីដែលប្រជាជនទាំងអស់បានសង្ឃឹមទុក ។ ក្រមសីលធម៌ប្រការទី១ ទី១១ និងទី១២ បានចែងអំពីការតម្រូវឲ្យមានភាពលះបង់ទាំងស្រុងពីជនបដិវត្តន៍ ។ ប្រការទី១) ស្រឡាញ់ គោរព ហើយបម្រើប្រជាជន កម្មករ កសិករជាប់ជានិច្ច ។ ប្រការទី១១) ស្រឡាញ់ហើយធ្វើពលិកម្មជានិច្ច ។ ប្រការទី១២) ប្រយុទ្ធនឹងខ្មាំង ប្រយុទ្ធនឹងឧបសគ្គដោយអង់អាចហើយហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ជូនប្រជាជន កម្មករ កសិករជូនបក្ស ជូនបដិវត្តន៍ដោយឥតលក្ខខណ្ឌក្នុងគ្រប់កាលៈទេសៈ ។

សេចក្តីស្រឡាញ់ ការបម្រើ និងការបូជាចំពោះប្រជាជនគឺមានន័យថា ស្រឡាញ់ បម្រើ និងបូជាចំពោះអង្គការ ។ រាល់សកម្មភាពទាំងឡាយណាដែលប្រឆាំងនឹងភារកិច្ចនេះត្រូវបានចាត់ទុកថា "ខុសសីលធម៌" ហើយប្រឆាំងទៅនឹងគោលបំណងរបស់អង្គការ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនត្រឹមតែការទាក់ទងផ្លូវភេទមុនពេលរៀបការត្រូវចាត់ទុកថាខុសសីលធម៌នោះទេ សូម្បីតែការសើច ការញញឹម ការនិយាយ ការចែចង់ និងការសម្លឹងទៅរកមនុស្សដែលមានភេទខុសគ្នា ក៏ចាត់ទុកថាខុសសីលធម៌ដែលមានកម្រិតស្មើគ្នាដូចការទាក់ទងផ្លូវភេទមុនពេលរៀបការដែរ ។ សកម្មភាពទាំងនេះចាត់ទុកជាទង្វើមួយដែលប្រឆាំងនឹងបដិវត្តន៍ និងខុសសីលធម៌ ពីព្រោះទង្វើទាំងនេះបង្វែរបុគ្គលឲ្យដើរចេញពីសកម្មភាពសីលធម៌ដូចជាការងារនិងការផលិតទិន្នផលជូនអង្គការ ។

ជារៀងរាល់សប្តាហ៍ឬជារៀងរាល់១០ថ្ងៃម្តង សហករណ៍នៅក្នុងប្រទេសទាំងមូលបានបើកអង្គប្រជុំមួយដើម្បីអប់រំប្រជាជនអំពីបដិវត្តន៍ដើម្បីជំរុញទឹកចិត្តប្រជាជនឲ្យខំប្រឹងធ្វើការងារនិងដើម្បីធ្វើឲ្យប្រជាជនមានការកក់ក្តៅ ហើយរក្សាភាពស្មោះត្រង់

ចំពោះបដិវត្តន៍និងអង្គការ ។ ការប្រជុំទាំងនេះបានផ្តល់ដំបូន្មានដល់ប្រជាជនអំពីរបៀបដែលប្រជាជនអាចលើកស្ទួយខ្លួនឯងនិងការងាររបស់ខ្លួន ។ អមជាមួយការកោតសរសើរពីផលរបស់ការងារ ជាទូទៅអ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យតែងតែធ្វើការណែនាំប្រជាជនមិនឲ្យប្រព្រឹត្តអំពើខុសសីលធម៌ ហើយនិងជំរុញប្រជាជនឲ្យផ្តោតអារម្មណ៍ទៅលើការកិច្ចនិងកាតព្វកិច្ចចំពោះប្រទេស ។

*«នៅពេលដែលយើងជួបជុំគ្នាក្នុងអង្គប្រជុំគោលនយោបាយរបស់ខ្មែរក្រហមបានបញ្ជាក់ថារបបនេះមិនចង់ឲ្យយើងប្រព្រឹត្តអំពើ «ខុសសីលធម៌» នេះទេ ។ ខ្មែរក្រហមចង់ឲ្យយើងស្មោះត្រង់និងខំប្រឹងធ្វើការ ។ ខ្មែរក្រហមមិនចង់ឲ្យយើងស្រឡាញ់គ្នាទេ (ដោយគ្មានការអនុញ្ញាតពីអង្គការ) ។ យើងត្រូវតែសាមគ្គីគ្នាទៅវិញទៅមកហើយយើងត្រូវតែធ្វើការ» ។*

របបកម្ពុជាប្រជាធិបតេយ្យបានព្រមានប្រជាជនមិនឲ្យទាក់ទងគ្នា(ខាងផ្លូវភេទ) ប៉ុន្តែឲ្យរួបរួមការប្រឹងប្រែងរបស់ខ្លួនដើម្បីឈានទៅរកការងារសាធារណៈនិងសង្គម ។ «ខ្មែរក្រហមមិនចង់ឲ្យប្រជាជនលូកលាន់នៅក្នុងសកម្មភាពដែលផ្ទុយទៅនឹងអត្ថន័យរបស់អង្គការថ្នាក់លើ» នេះជាសម្តីរបស់ មីង (ដាវី) ដែលក្លាយជាប្រធានឃុំបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ។

របបកម្ពុជាប្រជាធិបតេយ្យមានការបារម្ភថា ប្រសិនបើប្រជាជនត្រូវបានអនុញ្ញាតិឲ្យស្រឡាញ់គ្នាទៅវិញទៅមកនិងមានការរួមរក្ស (ដោយខ្វះការត្រួតពិនិត្យពីអង្គការ) ប្រជាជននឹងអាចលះបង់ការងាររបស់ខ្លួន និងធ្វើឲ្យខូចដល់គោលដៅរបស់បដិវត្តន៍ដើម្បីផលិតនិងបង្កើនផលិតផលកសិកម្ម ។

*«នេះហើយជាគោលនយោបាយរបស់ខ្មែរក្រហម ។ គោលនយោបាយនេះមិនអនុញ្ញាតឲ្យប្រជាជនស្រឡាញ់គ្នាទៅវិញទៅមកដោយសេរី ។ អ្នកឯងមិនអាចលួចស្រឡាញ់គ្នាស្ងាត់ៗ ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនស្រឡាញ់គ្នាទៅវិញទៅមកទេ ។ ប៉ុន្តែឥឡូវនេះយើងអាចសម្រេចចិត្តបង្កើតចំណងស្នេហា ហើយវាជារឿងធម្មតាគ្មាននរណាចាំតាមដានយើងទេ ព្រោះជាសិទ្ធិរបស់យើង ។ របបខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងស្រឡាញ់ ឬប្រាស្រ័យទាក់ទងគ្នា ពីព្រោះការនេះអាចធ្វើឲ្យខូចការងាររបស់អង្គការ» ។*

ដើម្បីធានាថាបុរសនិងស្ត្រីគ្មានការទាក់ទងគ្នាទៅវិញទៅមក របបកម្ពុជាប្រជាធិបតេយ្យបានដាក់ពិន័យយ៉ាងធ្ងន់ធ្ងរដល់ជនទាំងឡាយណាដែលហ៊ានប្រព្រឹត្តបំពានច្បាប់ ។ របបកម្ពុជាប្រជាធិបតេយ្យនឹងកម្ចាត់ជាបន្ទាន់ចំពោះអ្នកដែលប្រព្រឹត្តខុសសីលធម៌ដោយក្តីភ័យខ្លាចថា ជនខុសសីលធម៌ទាំងនេះធ្វើឲ្យប្រឡាក់ដល់ភាពបរិសុទ្ធនៅក្នុងសង្គម និងជះឥទ្ធិពលដល់អ្នកដទៃនាំឲ្យអ្នកដទៃប្រព្រឹត្តខុសសីលធម៌ដែរ ហើយនិងធ្វើឲ្យប្រជាជនមិនគិតគូរអំពីការងារ ។ របបកម្ពុជាប្រជាធិបតេយ្យសង្ឃឹមថានឹងធ្វើឲ្យមានការភ័យខ្លាច និងចង្អុលបង្ហាញដល់ប្រជាជនអង្គការថាមិនត្រាប្រណីដល់អាកប្បកិរិយាមិនត្រឹមត្រូវ (ខុសសីលធម៌) ។ របបកម្ពុជាប្រជាធិបតេយ្យចង់ឲ្យប្រជាជនរបស់ខ្លួនខិតខំប្រឹងធ្វើការជាទម្ងន់ និងផ្តល់កម្លាំងពលកម្មទាំងស្រុងដល់បដិវត្តន៍ ហើយមិនឲ្យចំណាយពេលវេលាសម្រាប់ស្រឡាញ់គ្នា និងសម្រាប់ការរួមរក្ស ។

នៅក្នុងឃុំព្រៃករការ បុរសនិងស្ត្រីត្រូវបានឆក់ខ្សែភ្លើងភ្លាម ប្រសិនបើបុរសនិងស្ត្រីនោះត្រូវបានសង្ស័យថាមានការជជែកគ្នា ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នាទៅវិញទៅមក ។ យោងទៅតាមសម្ភាសន៍ជាមួយអ្នកមីង (គីម គីន) ដែលមានប្រសាសន៍ថា «ប្រធានកងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើដូច្នេះ ពីព្រោះប្រធានកងទាំងនេះបារម្ភខ្លាចប្រជាជនស្រឡាញ់គ្នា ។ អ្នកប្រព្រឹត្តខុសសីលធម៌ នឹងក្លាយទៅជាសត្រូវរបស់សង្គម ហើយត្រូវតែកម្ទេចចោលជាបន្ទាន់ មុនពេលអ្នកទាំងនោះធ្វើឲ្យជះឥទ្ធិពលដល់អ្នកដទៃទៀត ។»

អ្នកមីង (រស់ ញឹប) ដែលធ្វើការជាជំនួយការផ្នែកពេទ្យក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅចងចាំថា «កម្មាភិបាលពេទ្យដែលប្រព្រឹត្តខុសសីលធម៌ មិនត្រូវបានអនុញ្ញាតឲ្យធ្វើការជាមួយអ្នកជំងឺទៀតទេ ។ កម្មាភិបាលពេទ្យដែលប្រព្រឹត្តខុសសីលធម៌ត្រូវបានដកចេញ ហើយបង្ខំឲ្យធ្វើការងារយ៉ាងធ្ងន់ធ្ងរដែលខ្មែរក្រហមហៅថា អប់រំ ឬលត់ដំ» ។

> "ប្រសិនបើអ្នកណាម្នាក់ប្រព្រឹត្តខុសសីលធម៌ ខ្មែរក្រហមនឹងយកបុរស ឬស្ត្រីនោះទៅអប់រំនៅតាមការដ្ឋានវាលស្រែ ឬកន្លែងដាំដំណាំ ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យអ្នកនោះស្នាក់នៅនិងបម្រើអ្នកជំងឺទេ ។ ខ្មែរក្រហមបារម្ភថា អ្នកទាំងនេះធ្វើឲ្យខូចខាតអ្វីដែលជារបស់បដិវត្តន៍ (ឬទ្រព្យសម្បត្តិរបស់បដិវត្តន៍) ។ ខ្មែរក្រហមមិនយកកម្មាភិបាលពេទ្យដែលខុសសីលធម៌នេះទៅណាទេ ។ ប្រសិនបើខ្មែរក្រហមអាចអប់រំកសាងនិងឲ្យអ្នកទាំងនេះឲ្យធ្វើការបានច្រើន នោះខ្មែរក្រហមនឹងទុកអ្នកទាំងអស់រស់នៅ ។

អ្នកដែលប្រព្រឹត្តខុសសីលធម៌ ជាធម្មតាត្រូវពិន័យឬត្រូវកម្ទេចចោលដើម្បីទុកជាឧទាហរណ៍ដល់អ្នកដទៃឲ្យយល់ឃើញពីផលលំបាកដែលត្រូវទទួលនៅពេលដែលអ្នកណាម្នាក់ជ្រើសរើសយកផ្លូវប្រឆាំងនឹងសង្គម ។ នៅក្នុងកាលៈទេសៈបែបនេះ ទាំងបុរស ទាំងស្ត្រីដែលជាប់ពាក់ព័ន្ធត្រូវទទួលពិន័យ ។ នៅពេល មីង (កាន់ ជឹម) ប្រព្រឹត្តខុសសីលធម៌ គាត់ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខកោះគរអស់រយៈពេល៩ខែ ។ ពេលដែលគាត់ចេញពីមន្ទីរសន្តិសុខវិលមកផ្ទះសម្បែងវិញ គាត់ត្រូវបានបង្ខំឲ្យឈរនៅពីមុខអ្នកភូមិ ហើយសន្យាថាគាត់នឹងឈប់ប្រព្រឹត្តខុសសីលធម៌ទៀតហើយ ។ គាត់បាននិយាយថា "ពេលណាក៏ដោយដែលរឿងបែបនេះកើតឡើង ខ្មែរក្រហមបានកោះហៅប្រជាជនឲ្យមកប្រជុំដើម្បីធ្វើឲ្យគ្រប់ៗគ្នាបានស្តាប់ឮហើយដឹង ។ ក្រោយមកប្រសិនបើយើងប្រព្រឹត្តបែបនេះម្តងទៀត ខ្មែរក្រហមនឹងចាត់វិធានការដូចដែលមានជាគំរូ" ។ មានអ្នកដទៃទៀតដែលមិនមានសំណាងដូចមីង (កាន់ ជឹម) ។ មានបុរស និងស្ត្រី ខុសសីលធម៌មួយគូដែលត្រូវបានវាយទម្លាក់ចូលទៅក្នុងរណ្តៅដោយសារតែលួចស្រឡាញ់គ្នា ។

> "ខ្មែរក្រហមជីករណ្តៅរួចហើយក៏វាយអ្នកទាំងពីរនាក់នោះចូលទៅក្នុងរណ្តៅម្តងមួយៗ ។ ខ្មែរក្រហមបង្ខំឲ្យបុរសនោះសន្យាថាគាត់ស្ម័គ្រចិត្តស្លាប់ជាមួយនារី រួចហើយឲ្យនារីនោះថាស្ម័គ្រចិត្តស្លាប់ជាមួយបុរសនោះដែរ ។ ខ្មែរក្រហមសម្លាប់អ្នកទាំងពីរ ពីព្រោះអ្នកទាំងពីរនាក់បានស្រឡាញ់គ្នា" ។ មីង (កាន់ ជឹម) ជឿថារបបកម្ពុជាប្រជាធិបតេយ្យបានពិន័យអ្នកដែលប្រព្រឹត្តខុសសីលធម៌ក្នុងគោលបំណងធ្វើឲ្យមានការភ័យខ្លាចនិងទប់ស្កាត់អ្នកដទៃទៀតមិនឲ្យប្រព្រឹត្តខុសសីលធម៌ និងមិនឲ្យប្រជាជនភ្លេចភារកិច្ចរបស់ខ្លួនចំពោះសង្គម ។ ខ្មែរក្រហមសាហាវ ពីព្រោះបើខ្មែរក្រហមមិនសាហាវទេនោះ ប្រជាជននឹងមិនខ្លាចឡើយ ។ ប្រសិនបើប្រជាជនបន្តការខុសសីលធម៌ អ្វីៗទាំងអស់និងត្រូវខូចខាត ហើយសង្គមនឹងត្រូវខូចខាត ។ ប្រសិនបើប្រជាជនរវល់តែប្រព្រឹត្តអំពើផ្តេសផ្តាសរវាងគ្នាទៅវិញទៅមក ប្រជាជននឹងមិនខិតខំប្រឹងប្រែងធ្វើការងារទេ ។ខ្មែរក្រហមបង្ខំប្រជាជនឲ្យធ្វើការទាំងយប់ទាំងថ្ងៃ ។

របបកម្ពុជាប្រជាធិបតេយ្យបានព្យាយាមធ្វើឲ្យមានភាពភ័យខ្លាចដល់ប្រជាជនក្នុងសង្គមទាំងមូល ដូច្នោះហើយទើបមិនមានការប៉ុនប៉ងគេចវេះពីការងារ ។ អ្នកមីង (ជា សាន់) បាននិយាយថា "ខ្មែរក្រហមរក្សាប្រជាជនដើម្បីទុកប្រើ ។ ប្រសិនបើខ្មែរក្រហមមិនប្រើប្រាស់ការសម្លាប់ប្រជាជនជាការគំរាមកំហែងទេនោះប្រជាជននឹងមិនគោរពតាមច្បាប់ឡើយ" ។ ទង្វើរបស់របបកម្ពុជាប្រជាធិបតេយ្យមិនមែនធ្វើឡើងព្រោះតែចាប់អារម្មណ៍ក្នុងការការពារទ្រព្យសម្បត្តិរបស់ខ្លួន និងដើម្បីថែរក្សាសង្គមដ៏ស្អាតស្អំមួយនោះទេ តែដោយសាររបបកម្ពុជាប្រជាធិបតេយ្យចាប់អារម្មណ៍ធ្វើឲ្យមនុស្សផ្តោតតែពីរឿងធ្វើការងារ ។ របបកម្ពុជាប្រជាធិបតេយ្យបានដាក់កម្រិតលើទំនាក់ទំនងផ្លូវភេទមិនមែនពីព្រោះតែហេតុផលរឿងសីលធម៌នោះទេ ប៉ុន្តែគឺដើម្បីផលប្រយោជន៍ការងារសមូហភាព ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអ្នកប្រព្រឹត្តខុសសីលធម៌ត្រូវបានដាក់ពិន័យនិងដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ។ ច្បាប់ដ៏តឹងរ៉ឹងនេះបានទប់ស្កាត់ប្រជាជនទូទៅមិនឲ្យមានទំនាក់ទំនងផ្លូវភេទជាមួយគ្នាទៅវិញទៅមក ។ នៅខណៈនោះដែរ ក៏មានគោលនយោបាយដ៏ប្រាកដប្រជាដើម្បីហាមឃាត់កម្មាភិបាលខ្មែរក្រហមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកុំឲ្យមានការបំពានផ្លូវភេទទៅលើក្រុមផ្ទៃក្នុងរបស់ខ្លួន ។ ស្ត្រីដែលត្រូវបានធ្វើការសម្ភាសន៍ បាននិយាយថា ទោះបីជាខ្លួនត្រូវបាន

រំលោភបំពាន និងរងទារុណកម្មទាំងផ្នែកអារម្មណ៍ និងស្មារតី ដោយថ្នាក់ដឹកនាំខ្មែរក្រហមដោយឈ្លបនិងដោយអ្នកយាមមន្ទីរសន្តិសុខយ៉ាងណាក៏ដោយ ក៏ករណីបទឧក្រិដ្ឋផ្លូវភេទនិងការចាប់រំលោភមានតិចតួចណាស់ ។ ស្ត្រីជាច្រើនជឿជាក់ថាមានសង្គមបរិសុទ្ធនិងស្អាតស្អំមួយ ព្រោះស្ត្រីទាំងនោះបានឃើញនិងដឹងពីការដាក់ពិន័យទៅលើបទឧក្រិដ្ឋផ្លូវភេទ ។

«បើតាមការយល់ដឹងរបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហមនេះ ប្រសិនបើយើងជជែកអំពីការរំលោភស្ត្រី វាហាក់ដូចជាមិនមានបញ្ហាធ្ងន់ធ្ងរអ្វីទេ ពីព្រោះខ្មែរក្រហមមានច្បាប់និងទំនៀមទម្លាប់ផ្ទាល់ខ្លួន គឺជាច្បាប់ដែលខ្មែរក្រហមមិនចង់ឲ្យប្រជាជនចូលលាយឡំជាមួយ ។»

សូម្បីតែនៅក្នុងគុកក៏របបកម្ពុជាប្រជាធិបតេយ្យបានដាក់បម្រាមប្រឆាំងនិងទោសឧក្រិដ្ឋផ្លូវភេទដែរ ។ អ្នកមីង (ដាន់ ផាត) និយាយថា «ដោយសារតែគោលនយោបាយរបស់ខ្មែរក្រហមតឹងរ៉ឹងដូច្នេះហើយ ទើបខ្មែរក្រហមមិនហ៊ានចាប់រំលោភខ្ញុំនៅពេលដែលខ្ញុំជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខកោះគរ ។ នៅមន្ទីរសន្តិសុខកោះគរ ខ្មែរក្រហមមិនបានធ្វើអ្វីចំពោះខ្ញុំ ។ មិនដែលទេ ។ គោលនយោបាយរបស់ខ្មែរក្រហមតឹងរ៉ឹងណាស់ ។ ខ្មែរក្រហមមិនហ៊ានទេ ។ ខ្មែរក្រហមមិនហ៊ាន មិនហ៊ានធ្វើទេ ។ ប៉ុន្តែខ្មែរក្រហមវាយខ្ញុំ វាយតាមតែទំនើងចិត្តតែម្តង ។» រឿងនេះកើតឡើងដូចគ្នាទៅនឹងរឿងរបស់អ្នកមីង (ស៊ាន ដាន) ដែលត្រូវបានឃុំឃាំងខ្លួននៅមន្ទីរសន្តិសុខស្អាង ។ អ្នកមីង (ស៊ាន ដាន) បានត្អូញត្អែរពីការងារលំបាកធ្ងន់ធ្ងរនិងខ្វះម្ហូបអាហារ ។ ប៉ុន្តែកម្មាភិបាលរបបកម្ពុជាប្រជាធិបតេយ្យមិនហ៊ានរំលោភបំពានផ្លូវភេទទៅលើរូបគាត់ទេ ។

«វាហាក់បីដូចជាខ្មែរក្រហមមិនដែលរំលោភទេ នៅពេលនោះខ្ញុំមិនបានដឹងអំពីផ្ទះនៅប៉ែកខាងកើត ខ្ញុំគ្រាន់តែដឹងរឿងពួកខ្ញុំគឺខ្មែរក្រហមមិនហ៊ានរំលោភទេ ។ ខ្មែរក្រហមមិនហ៊ានចាប់រំលោភពួកខ្ញុំ ។ ខ្មែរក្រហមគ្រាន់តែប្រើខ្ញុំឲ្យធ្វើការងារធ្ងន់ៗ ហើយខ្មែរក្រហមមិនឲ្យខ្ញុំបរិភោគគ្រប់គ្រាន់ទេ ។ ប៉ុន្តែការចាប់រំលោភគឺកម្មាភិបាលខ្មែរក្រហមមិនហ៊ានទេ ព្រោះគោរពច្បាប់របស់ខ្លួនឯងណាស់» ។

ទោះបីជាច្បាប់នោះបានការពារ អ្នកមីង (ដាន់ ផាត) និងអ្នកមីង (ស៊ាន ដាន) មិនឲ្យត្រូវបានរំលោភយ៉ាងណាក៏ដោយ ក៏មានស្ត្រីជាច្រើនអ្នកទៀតដែលគ្មានសំណាង ហើយដែលបានជាប់ឃុំឃាំងនៅក្នុងប្រព័ន្ធមួយដែលបានដាក់ស្ត្រីទាំងនោះឲ្យស្ថិតនៅក្នុងគ្រោះថ្នាក់មួយយ៉ាងធំដោយសារការរំលោភផ្លូវភេទ ។ ពីព្រោះតែច្បាប់មានភាពតឹងរ៉ឹងហួសហេតុពេក ទើបកម្មាភិបាលខ្មែរក្រហមអាចមានលទ្ធភាពចាប់រំលោភ ឬបំពានផ្លូវភេទទៅលើស្ត្រី ហើយអាចលាក់បំបាំងទោសឧក្រិដ្ឋរបស់ខ្លួន ។ សារជាតិរបស់ច្បាប់ដែលបានដាក់ពិន័យទៅលើអ្នករំលោភ ក៏ដូចអ្នកដែលត្រូវរងទទួលការរំលោភបានជំរុញឲ្យកម្មាភិបាលខ្មែរក្រហមទាញយកផលប្រយោជន៍ពីតំណែងរបស់ខ្លួន ។ ច្បាប់នេះមិនបានជួយទប់ស្កាត់បុរសដែលមានសិទ្ធិអំណាចនៅក្នុងសង្គមមិនឲ្យប្រព្រឹត្តបទឧក្រិដ្ឋផ្លូវភេទ ប៉ុន្តែច្បាប់នេះបែរជាការពារអ្នករំលោភឲ្យរួចផុតពីការដាក់ពិន័យទៅវិញ ។

ស្ត្រីដែលត្រូវបានរំលោភមានការភ័យខ្លាច ពីព្រោះថាប្រសិនបើខ្លួននិយាយរឿងនេះចេញមកតទល់ជាមួយអ្នកចាប់រំលោភខ្លួន ស្ត្រីនោះនឹងត្រូវបានសម្លាប់ដោយអ្នករំលោភ ឬត្រូវពិន័យដោយរបបកម្ពុជាប្រជាធិបតេយ្យពីបទប្រព្រឹត្តខុសសីលធម៌ ។ អ្នករំលោភយល់ថា ឲ្យតែខ្លួនអាចលាក់ភ័ស្តុតាងពីបទឧក្រិដ្ឋរបស់ខ្លួនបានជាទូទៅ ដោយសម្លាប់អ្នកដែលខ្លួនបានរំលោភនោះចោល បទឧក្រិដ្ឋនោះនឹងគ្មានអ្នកណាដឹង ហើយក៏គ្មានអ្នកណាដាក់ពិន័យអ្វីទេ ។ សារជាតិបែងចែកជាសហករណ៍ និងមន្ទីរសន្តិសុខនៅក្នុងរបបខ្មែរក្រហមបានជួយការពារថ្នាក់ដឹកនាំខ្មែរក្រហមមិនឲ្យទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ។ បញ្ហានេះហើយ បានធ្វើឲ្យស្ត្រីទទួលបាននូវការការពារតិចតួចពីការរំលោភនិងបទឧក្រិដ្ឋផ្លូវភេទ ។ គ្មានច្បាប់ណាសម្រាប់ស្ត្រីដើម្បីធ្វើការប្តឹងផ្តល់ទេ ។ ច្បាប់បានតាក់តែងឡើងក្នុងគោលបំណងការពារស្ត្រីពីការរំលោភផ្លូវភេទ ប៉ុន្តែផ្ទុយទៅវិញច្បាប់នេះបែរជាធ្វើឲ្យស្ត្រីក្លាយទៅជាជនរងគ្រោះពីជនដៃដល់ និងសង្គមខ្មែរក្រហមនោះទៅវិញ ។

ទោះបីជាកម្មាភិបាលខ្មែរក្រហមដូចជាអ្នកដឹកនាំអង្គភាព និងអ្នកយាមគុកក៏ដូចប្រជាជនឯទៀតត្រូវបាន **(តទៅទំព័រទី៦០)**


តាក ទ្រី

## អតីតយុទ្ធជននេសាទត្រី
### នៃរបបកម្ពុជាប្រជាធិបតេយ្យ

ស្ថិតក្នុងស្ថានភាពនិងមានសម្បៀកបំពាក់ជាអ្នកស្រែចម្ការ នៅតាមចុងកាត់មាត់ញកនា ស្រុកស្អាង ខេត្តកណ្តាល តាក ទ្រី ក្នុងវ័យ៤២ឆ្នាំ បានផ្តល់ការធ្វើសម្ភាសន៍រយៈពេលជាង ១ម៉ោងអំពីរឿងរ៉ាវទាំងឡាយដែលទាក់ទងនឹងភារកិច្ចជាយុទ្ធជននេសាទត្រីនៃវរសេនាតូច១១២ វរសេនាធំ២៦៧ កងពល១២ នៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ទ្រី បាននិយាយរៀបរាប់ថា មកដល់បច្ចុប្បន្ននេះ (ឆ្នាំ២០០០) ខ្ញុំមានអាយុ៤២ឆ្នាំ ហើយបានក្លាយជាកូនកំព្រាឪពុកតាំងពីអាយុ១២ឆ្នាំម៉្លេះ ។ ក្រោយរដ្ឋប្រហារ លន់ ណុល ឆ្នាំ១៩៧០ ឪពុកម្តាយបានឲ្យខ្ញុំទៅបួសរៀននៅវត្តស្អាងស្រែ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ។ សាងផ្នួសបានពីរព្រះវស្សាក៏លាចាកសិក្ខាបទដើម្បីជួយបម្រើការងារឪពុកម្តាយ ។ ដោយលុះតាមការឃោសនាដែលប្រើរូបភាព “រណសិរ្សរួបរួមជាតិកម្ពុជា” វាយរំដោះទឹកដីដើម្បីយកសម្តេចឪមកវិញ ខ្ញុំក៏បានចូលបម្រើជាកងទ័ពរំដោះនៅឆ្នាំ១៩៧២ ក្នុងវ័យ១៥ឆ្នាំ ។ ជំនាន់នោះពុំមានកំណែនទ័ពនៅឡើយទេ ។ ការចូលបម្រើកងទ័ពគឺជាទឹកចិត្តដែលផុសចេញពីការគោរពស្រឡាញ់ចំពោះសម្តេចឪ ។ គួបផ្សំនឹងការពន្យល់ណែនាំពីសំណាក់បងប្រុសរបស់ខ្ញុំម្នាក់ដែលមាននាទីជាប្រធានភូមិទួលសាលា ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល នៅឆ្នាំ១៩៧៣ ខ្ញុំក៏សម្រេចស្ម័គ្រចិត្តចូលបម្រើទ័ពជាយុទ្ធជនសេដ្ឋកិច្ចផ្នែកនេសាទត្រី ប្រចាំវរសេនាតូច១១២ វរសេនាធំ២៦៧ កងពល១២ ដែលមានឈ្មោះ ម៉ាន ជាប្រធានក្រុម ។

នៅអំឡុងឆ្នាំ១៩៧០-៧៥ ប្រទេសកម្ពុជាត្រូវបានទទួលរងការទម្លាក់គ្រាប់បែករាប់រយតោននៅក្នុងសង្គ្រាមរវាងរបបសាធារណរដ្ឋខ្មែរនិងខ្មែរក្រហម ។ នាពេលមួយនៃឆ្នាំ១៩៧២ យន្តហោះបានទម្លាក់គ្រាប់ជាច្រើនគ្រាប់នៅពេលដែលខ្ញុំកំពុងតែជួយសែងយុទ្ធជនរបួសមកមន្ទីរពេទ្យវត្តត្របែក ។ ពេលនោះហើយដែលសម្លេងខ្ទរនៃគ្រាប់ផ្ទោងបេ៥២បានធ្វើឲ្យត្រចៀករបស់ខ្ញុំទាំងពីរហ៊ឹងនិងថ្លង់រហូតដល់សព្វថ្ងៃនេះ ។

ដោយសារពិការភាព ខ្ញុំមានតួនាទីត្រឹមតែជាយុទ្ធជនសេដ្ឋកិច្ចសមរភូមិក្រោយទទួលបន្ទុកនេសាទតែប៉ុណ្ណោះ ។ ជាយុទ្ធជននេសាទត្រី ការងារពុំស្ថិតស្ថេរឡើយ ម្តងទៅអង្គរបូរី (ខេត្តតាកែវ) ម្តងទៅទន្លេសាប និងទៅដែនសមុទ្រក៏មាន ។ ក្រៅពីការងារនេសាទត្រី ខ្ញុំមានភារៈចម្អិនបាយរៀបចំដាក់ស្នុកសម្រាប់កុមារជាច្រើនដែលមានអាយុប្រហែល១២ឆ្នាំដើម្បីជញ្ជូនទៅឲ្យយុទ្ធជននៅសមរភូមិមុខ ។

នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានអង្គការថ្នាក់លើដកទៅនៅបឹងទន្លេសាប ។ ពេលនោះខ្ញុំហៀបតែនឹងចូលគុកទៅហើយព្រោះថាខ្ញុំត្រូវបានចោទប្រកាន់ពីបទជាប់និន្នាការទាហាន លន់ ណុល ដោយម្តាយខ្ញុំធ្លាប់រស់នៅទីក្រុងភ្នំពេញនាឆ្នាំ១៩៦៨ ។ ជាបន្តបន្ទាប់ ខ្ញុំត្រូវបានអង្គការផ្លាស់ពីយុទ្ធជននេសាទមកជាយុទ្ធជនធ្វើស្រែ ។ កាលណោះខ្ញុំដឹងច្បាស់ណាស់ថា ការដែលផ្លាស់មកធ្វើស្រែនេះមានន័យថា យកមកដាក់គុកតែម្តង ដែលគុកនោះនៅព្រលានយន្តហោះ ខេត្តកំពង់ឆ្នាំង ។ យុទ្ធជនទាំងឡាយដែលមកធ្វើស្រែនៅព្រលានយន្តហោះ ខេត្តកំពង់ឆ្នាំង ត្រូវបានអង្គការដាក់ឈ្មោះថា “០៤” ឬ “អ្នកបញ្ញើ” ហើយពុំមែនជាយុទ្ធជនកាន់កាំភ្លើងឡើយ ប៉ុន្តែគឺជាយុទ្ធជនត្រៀមចាំថ្ងៃស្លាប់ ។

ចាប់តាំងពីខ្ញុំចូលធ្វើយុទ្ធជនមក ខ្ញុំមិនដែលទទួលបានការបង្ហាត់បង្រៀនទ្រឹស្តីយុទ្ធជនម្តងណាសោះ ។

កាលនោះមានសាលាបច្ចេកទេសនៅម្តុំវត្តកោះ វត្តខ្សាច់ពន្លា វត្តកណ្តាល និងក្រាំងយ៉ូវ ។ ជាទូទៅ យុទ្ធជនភាគច្រើនបានទទួលការបង្ហាត់បង្ហាញផ្នែកយុទ្ធវិធីសង្គ្រាមរយៈពេលខ្លី ។ មានយុទ្ធជនខ្លះពុំបានទទួលការបណ្តុះបណ្តាលអ្វីទេ ប៉ុន្តែក្រោយពេលបម្រើការងារយូរខែ អង្គការចាត់ឲ្យទៅសមរភូមិមុខតែម្តង ។ ចំពោះគ្រូបង្ហឹកគឺជនជាតិខ្មែរដែលធ្វើការបង្ហាត់បង្រៀនបច្ចេកទេសកងទ័ពដូចជាៈ ដំណើរទ័ព ដើរសម្ងាត់ ដើរលាក់ការណ៍ ដើរស៊ើបអង្កេតតាមប្រកល្បកនិងមើលភូមិសាស្ត្រដើម្បីវាយលុកជាដើម ។ នៅពេលចេញទៅសមរភូមិម្តងៗ ហេង ប្រធានមន្ទីរវរៈ ១១២ ជាអ្នករៀបចំចាត់ចែងការងារនិងសម្ភារៈសឹក ។

ខ្ញុំនៅកងនេសាទរយៈពេលបីឆ្នាំ ចាប់តាំងពីមុនឆ្នាំ១៩៧៥ រហូតដល់ក្រោយឆ្នាំ១៩៧៥ ។ ខ្ញុំតែងតែត្រូវបានអង្គការផ្លាស់

ប្តូរជានិច្ច ដោយសារតែជាប់និន្នាការឪពុកម្តាយធ្លាប់រស់នៅទីក្រុងភ្នំពេញ ហើយខ្ញុំក៏ពុំដឹងថាតើអង្គការមានផែនការយ៉ាងណាចំពោះខ្ញុំ ។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាអង្គការធ្វើអ្វីៗព្យាយាមមិនឲ្យយើងដឹងខ្លួនឡើយ សូម្បីចង់ដក ចង់ដាក់គុក ឬចង់សម្លាប់ ។ គុកក្នុងរបបនោះជាគុកឥតជញ្ជាំង គឺឲ្យយើងធ្វើស្រែពេញ១ថ្ងៃដោយឥតមានពេលសម្រាក ឬម្ហូបអាហារគ្រប់គ្រាន់ ។

ទោះបើខ្ញុំធ្វើការងាររអស់កម្លាំងឬហេវហត់យ៉ាងណាក៏ដោយ ជារៀងរាល់ថ្ងៃខ្ញុំទទួលបានតែរបបអង្ករ២កំប៉ុងតែប៉ុណ្ណោះ សម្រាប់២ពេល ក្នុង១ថ្ងៃ ។ ចំពោះសម្លៀកបំពាក់វិញគ្មានអ្វីក្រៅពីខោអាវជាឳបពណ៌ខ្មៅ ។ ឯកសណ្ឋានខ្មៅបែបនេះគឺជាឯកសណ្ឋានទាហានខ្មែរយៀកកុង ។ ក្រៅពីនោះមានស្បែកជើងកង់ឡាន ពណ៌ខ្មៅ អង្រឹងមួយ ក្រមាក្រហមមួយ និងបាឡូ (ប្រដាប់សម្រាប់ដាក់ខោអាវ) សម្រាប់ដាក់សម្ភារទាំងនោះ ។ ខោអាវនោះដូនកាលរហែករយ៉េរយ៉ៃ ពិបាកមើលពេកណាស់ ទោះបើមានអាវពណ៌ផ្សេងខុសពីខ្មៅ ក៏ពុំត្រូវបានអនុញ្ញាតឲ្យស្លៀកពាក់ដែរ ។ យុទ្ធជនខ្លះគ្មានទាំងក្រមាសម្រាប់ប្រើប្រាស់ទៀតផង ។ យុទ្ធជនទាំងនោះត្រូវបានអង្គការបំពាក់កាំភ្លើងអឹមសិ (M16) គ្រប់ៗគ្នា លើកលែងតែផ្នែកនេសាទប៉ុណ្ណោះដែលសមាជិក ១៥០នាក់មានកាំភ្លើងតែ១ដើមគត់ ។ ដោយហេតុថាយុទ្ធជននេសាទពុំមានភារៈចេញទៅធ្វើសង្គ្រាមនៅសមរភូមិមុខ ។ ខ្ញុំពុំដែលបានចេញទៅសមរភូមិមុខម្តងណាឡើយ ។ ខ្ញុំគិតថា "ខ្មែរយើងកាលសម័យនោះកាប់ចាក់តែគ្នាឯង ដោយពុំមានផលប្រយោជន៍អ្វីទាំងអស់" ។

ថ្វីបើខ្ញុំជាយុទ្ធជន ប៉ុន្តែខ្ញុំពុំដែលបានឃើញអ្នកធំៗណាម្នាក់ឡើយ សូម្បីតែ តាណាត ក៏ទេដែរ ។ បើទោះបីជាខ្ញុំឃើញអ្នកធំទាំងនោះ ក៏ខ្ញុំមិនហ៊ានស្គាល់នឹងអ្នកទាំងនោះ ហើយអ្នកធំទាំងនោះតែងតែផ្លាស់ប្តូរឈ្មោះម្តងយ៉ាងនេះ ម្តងយ៉ាងនោះនិងនៅពេលធ្វើដំណើរទៅណាមកណាមាននិរសាស្តាយកាំភ្លើងវែងស៊ើរអូសដីដើរជាមួយខ្លួនជាប់ជានិច្ច ។ និរសានេះទៀតសោតក៏មានការផ្លាស់ប្តូរជាញឹកញាប់ ។ មនុស្សដែលអាចធ្វើជានិរសាបានល្អកណាអ្នកនោះឈ្លាសវៃ រហ័សរហួន ក្លាហាន ស្មោះត្រង់ ហ៊ានធ្វើពលិកម្មសព្វគ្រប់បែបយ៉ាងរួមទាំងអាយុជីវិត ឲ្យតែកម្មាភិបាលជាន់ខ្ពស់ទាំងនោះចាកផុតពីការប៉ុនប៉ងឃាយ៉ុទាំងឡាយមកលើរូបរាងកាយនិងអាយុជីវិត ។ ខ្ញុំមានភារៈចម្បងគឺរកត្រីដើម្បីផ្គត់ផ្គង់កងទ័ព ។ ជារៀងរាល់មួយសប្តាហ៍ម្តង តែងតែមានយុទ្ធជនបើកកាណូតមកយកត្រីទាំងនោះ ។ ទ័ពដែលចុះមកយកត្រីមានការផ្លាស់ប្តូរគ្នាជាញឹកញាប់ ធ្វើឲ្យខ្ញុំពិបាកនឹងសម្គាល់ថាអ្នកនោះជានរណា មានឋានៈត្រឹមណា ។ ប៉ុន្តែខ្ញុំអាចដឹងត្រឹមថាជាយុទ្ធជនសេដ្ឋកិច្ចផ្នែកចុងភៅដែលត្រូវបានទទួលបញ្ជាតៗគ្នា ។

នៅឆ្នាំ១៩៧៣ខ្មែរក្រហមជ្រើសរើសកងទ័ពបានយ៉ាងច្រើនដោយសារតែពាក្យឃោសនាដ៏មានប្រសិទ្ធភាពរបស់អង្គការគឺ "ចូលធ្វើបដិវត្តន៍ដើម្បីរំដោះទឹកដីថ្វាយសម្តេចឪ" ។ ក្រៅពីពាក្យឃោសនារបស់មេភូមិ មេឃុំ អង្គការបានបោះពុម្ពឯកសារជាច្រើន ដែលឯកសារទាំងនោះប្រើប្រាស់ពាក្យពេចន៍ឃោសនាអប់រំគួឲ្យជក់ចិត្ត សូម្បីតែអ្នកមិនចេះអក្សរនៅពេលដែលបានពុម្ពមិត្តភក្តិអានឲ្យស្តាប់ក៏ជឿតាមដែរ ។ ក្នុងឆ្នាំដដែលនេះកងពល១២ពុំមានទីតាំងពិតប្រាកដឡើយមានតែមន្ទីរតូចៗ ឬមន្ទីរវរៈ ១២ ដែលនៅជិតផ្ទះ ម៉ាន ក្នុងភូមិដំរីស្លាប់ ឃុំស្អាងភ្នំ ស្រុកស្អាងខេត្តកណ្តាល ។ ទាក់ទិននៅនឹងការរៀបចំបែងចែកកម្លាំងរបស់កងពល១២ ទ្រី បានរៀបរាប់តាមការចងចាំដោយស្រពេចស្រពិលថាៈ នៅក្នុងកងពល១២ទាំងមូលបែងចែកជា៤វរសេនាធំដែលស្ថិតក្រោមបញ្ជាការដឹកនាំរបស់ តាណាត ។ ក្នុងនោះមានវរសេនាធំ១១៦, ១១២, ២៦៧ និងកងពិសេស ។ កងពិសេសឬហៅថាកងអន្តរាគមន៍ មានតួនាទីដើរស៊ើបការណ៍និងមើលផ្លូវសម្រាប់វាយលុក ។

នៅឆ្នាំ១៩៧៣និង១៩៧៤ យុទ្ធជនពុំមានបែងចែកជាជើងអាកាសនិងជើងទឹកឡើយ មានតែទាហានថ្មើរជើងប៉ុណ្ណោះ ហើយនៅក្នុងផ្នែកថ្មើរជើងមានកងសេដ្ឋកិច្ច កងពិសេស ឬកងអន្តរាគមន៍ ។ ចំពោះកងពិសេសត្រូវបានអង្គការផ្តល់សិទ្ធិក្នុងការជ្រើសរើសកាំភ្លើងណាមួយដែលខ្លួនពេញចិត្ត ។

ទ្រី បានសម្តែងនូវមនោសញ្ចេតនាថា "កាលណោះ បើខ្ញុំចូលសមរភូមិប្រហែលជាព្រាត់ប្រាសពុំបានមកផ្ទះជួបជុំបងប្អូនម៉្លេះសមស្លាប់បាត់បង់ជីវិតបាត់ទៅហើយ ។ ព្រោះថាអ្នកដែលធ្វើការជាមួយគ្នាទាំងអម្បាលម៉ាន បានស្លាប់បាត់បង់ជីវិតទាំងអស់ មានតែខ្ញុំហើយនិងបង ម៉ាន ដែលរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនេះ" ។

**ហ៊ុយ វណ្ណៈ**

# សម័យប្រជុំលើកទី៥ នីតិកាលទី២
# អំពីការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ
# ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០

*ថ្លែងដោយឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារសហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេស ដើម្បីរៀបចំនីតិវិធីសម្រាប់កាត់ទោសឧក្រិដ្ឋជនខ្មែរក្រហម*

**(តពីលេខមុន)**

◆ នៅថ្ងៃ៨ កុម្ភៈ ២០០០ លោកអគ្គលេខាធិការរង់បានធ្វើលិខិតមួយទៀត លិខិតនោះគឺថានៅតែតានតឹងដដែល គឺលើកឡើងនូវចំណុច៤ដែលជាចំណុចតានតឹង ។ ◆ ទី១ គឺថាសូមឲ្យយើងធានារ៉ាប់រងថាចាប់អ្នកដែលត្រូវចាប់ខ្លួននោះឲ្យបាន ។ ◆ ទី២ គឺថាសូមមិនឲ្យមានការលើកលែងអនុគ្រោះទោស ។ ◆ ទី៣ សូមឲ្យមានព្រះរាជអាជ្ញាបរទេសឯករាជ្យ បានន័យថាសហព្រះរាជអាជ្ញានោះមាន២ តែម្នាក់ៗធ្វើការឯករាជ្យពីគ្នា ។ ចំណុចនេះគឺយើងមិនបានព្រមព្រៀងតាមនោះទេ ប៉ុន្តែទូលបង្គំខ្ញុំបាទសូមរំឭកដែរថា ថ្ងៃ៨ កុម្ភៈនេះ គឺមានសំណើ៤ចំណុចនេះ ។ ◆ ហើយទី៤ គឺមានចៅក្រមបរទេសភាគច្រើន ។ ដូច្នេះចំណុច៤នេះនៅតែតានតឹងណាស់ ។ ◆ នៅថ្ងៃ១២ ខែកុម្ភៈនេះ គឺមានការជួបប្រជុំឡើងមកវិញរវាងឯកឧត្តមអគ្គលេខាធិការជាមួយនឹងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅបាងកកក្នុងឱកាសប្រជុំសន្និសីទសហប្រជាជាតិដើម្បីការអភិវឌ្ឍ (United Nation Conference on Trade and Development =UNCTAD) ។ ដូច្នេះជួបគ្នានៅបាងកកនេះគឺធ្វើឲ្យដំណើរការឈានឡើងវិញ បានន័យថា ឯកឧត្តមអគ្គលេខាធិការប្រកាសថាមានសុទិដ្ឋិនិយមហើយនឹងបញ្ជូនលោកឯកឧត្តម ហែន កូរែល មកភ្នំពេញម្តងទៀត ។ ដូច្នេះនៅខែមីនា ឆ្នាំ២០០០ គឺមានគណៈប្រតិភូទី២ នៃអគ្គលេខាធិការអង្គការសហប្រជាជាតិដែលដឹកនាំដោយឯកឧត្តម ហែន កូរែល ។ ដូច្នេះនៅពេលនោះក្រុមការងារក៏បានធ្វើការអស់រយៈពេលជិតមួយសប្តាហ៍ផងដែរ ដើម្បីសម្រួលនូវចំណុចទាំងប៉ុន្មានដែលយើងមិនទាន់ឯកភាពគ្នា ជាពិសេសចំណុចទាំង៤ ដែលទូលបង្គំបានលើកឡើងថាជាសំណើរបស់ឯកឧត្តម អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ◆ ខែមេសា ឆ្នាំ២០០០ គឺមានការជួបគ្នាម្តងទៀតនៅទីក្រុងឡាហាវ៉ាន ប្រទេសគុយបា រវាងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងឯកឧត្តមអគ្គលេខាធិការរងអង្គការសហប្រជាជាតិ ហែន កូរែល (នៅឡាហាវ៉ាន មិនទាន់មានការឯកភាពគ្នាទេ) ហើយក៏មានការជួបគ្នារវាងសម្តេចជាមួយនឹងលោកព្រឹទ្ធសមាជិក ចន ឃែរី ទៀត ។ លោក ចន ឃែរី គឺលោកបានមកភ្នំពេញម្តងទៀត


ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ លោក កែវ ចិន្តា ប្រធានតុលាការបដិវត្តន៍ប្រជាជនកម្ពុជាអានសាលក្រមសម្រេចកាត់ទោសប្រហារជីវិត ប៉ុល ពត និង អៀង សារី ពីបទឧក្រិដ្ឋកម្មសម្លាប់រង្គាល ។

*នៅខែមេសា ឆ្នាំ២០០០ ហើយក៏បានឈានទៅដល់ការឯកភាពសម្រុះសម្រួលម្តងទៀតចំពោះករណីដែលមានការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ។ ដូច្នេះដំណោះស្រាយមួយទៀតដែលត្រូវបានរកឃើញ ត្រូវឯកភាពគ្នានៅអំឡុងខែមេសា ឆ្នាំ២០០០នេះ ។ នៅខែឧសភា ឆ្នាំ២០០០នេះ គឺមានការផ្ញើលិខិតមួយទៀតជារបស់សម្តេចនាយករដ្ឋមន្ត្រីជូនលោក កូហ្វី អាណាន់ និងជូនលោក ចន ឃែរី បញ្ជាក់អំពីការដែលមានការសម្របសម្រួលលើគោលការណ៍ថ្មីដែលទូលបង្គំខ្ញុំបាទបានលើកឡើងពីខាងលើ ។ ◆ ខែកក្កដា គឺលោក ហែន កូរែល បានដឹកនាំគណៈប្រតិភូមកម្តងទៀតដើម្បីបន្តធ្វើការចរចានៅលើការរៀបចំយន្តការនេះ ។ នៅក្នុងការចរចាលើកក្រោយនេះយើងបានដោះស្រាយនូវចំណុចផ្សេងៗ ហើយបានឈានមកដល់ការព្រមព្រៀងគ្នាលើគោលការណ៍ធំៗ (មិនបាន១០០%ទេ) បានន័យថាការសម្រុះសម្រួលនោះបានឈានមកដល់ចំណុចដែលយើងមានសព្វថ្ងៃនេះ ។ ◆ នៅខែកញ្ញា ឆ្នាំ២០០០ ក្រុមការងាររបស់រាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើការឡើងវិញជាមួយនឹងគណៈកម្មការនីតិកម្មរបស់រដ្ឋសភា ។ ◆ នៅថ្ងៃ២០ វិច្ឆិកា ឆ្នាំ២០០០ លោកព្រឹទ្ធសមាជិក ចន ឃែរី មកម្តងទៀតដើម្បីធ្វើការងារចុងក្រោយបញ្ជាក់ ។ ដោយលោកចង់បញ្ជាក់ដំណើរការច្បាប់នេះឲ្យច្បាស់លាស់ថាតើដំណើរការនេះទៅមុខទេ រដ្ឋសភាយើងប្រជុំលើច្បាប់នេះទេគ្រាន់តែបញ្ជាក់ឡើងវិញនូវការប្រកាន់ជំហររបស់ព្រះរាជាណាចក្រកម្ពុជា ។ ◆ នៅថ្ងៃ ២៨ វិច្ឆិកា ក្រុមការងារជាមួយនឹងគណៈកម្មការនីតិកម្មបានបញ្ចប់ការងាររបស់ខ្លួនជាស្ថាពរ ហើយក៏ឈានមកដល់ការងារដែលមានថ្ងៃនេះ ។ ◆ ទូលបង្គំខ្ញុំបាទមុននឹងឈានមកដល់សេចក្តីសន្និដ្ឋាននេះ ទូលបង្គំខ្ញុំបាទសុំបញ្ជាក់ឡើងវិញនូវចំណុចដែលលើកឡើងថាជាចំណុចសំខាន់នៃការសម្រុះសម្រួលយ៉ាងធំដែលបញ្ជាក់ពីការខិតខំរបស់ភាគីទាំងពីរក្នុងការសម្រុះសម្រួល៥ជំហានធំៗនោះ គឺជំហានទី១គឺនៅពេលដែលយើងមានការឃ្លាតទាំងស្រុង ម្ខាងទាមទារតុលាការអន្តរជាតិ និងយើងទាមទារតុលាការជាតិ ដូច្នេះជំហានទាំង៥នៃការសម្រុះសម្រួលនេះ នេះជាជំហានទី១ដែលថា គេឈប់និយាយអំពីតុលាការអន្តរជាតិ គេនិយាយអំពីតុលាការដែលមានលក្ខណៈជាអន្តរជាតិ ដូច្នេះយើងបានឈានមកដល់ការសម្រុះសម្រួលលើកទី១ ដែលថាតុលាការជាតុលាការជាតិតែមាន អង្គជំនុំជម្រះវិសាមញ្ញដែលមានចៅក្រមបរទេសចូលរួមនេះជាការសម្រុះសម្រួលលើកទីមួយជាគោលការណ៍ថ្មីនៅក្នុងច្បាប់តុលាការ ។ នៅក្នុងច្បាប់ខាងប្រព័ន្ធយុត្តិធម៌មិនដែលមានដូចដែលទូលបង្គំខ្ញុំបាទបានលើកឡើងទេ ។ ដូច្នេះតុលាការអន្តរជាតិត្រូវមកដកពិសោធន៍នៅប្រទេសយើងវិញ ។ ព្រោះថាជាលើកទីមួយដែលមានគោលការណ៍របៀបនេះ ។ ដូច្នេះឯកឧត្តមអាចឆ្ងល់ថាតើហេតុអ្វីបានជាយើងធ្វើច្បាប់មិនត្រូវនឹងច្បាប់ដែលយើងធ្លាប់មានដូច្នេះ? វាជាករណីវិវត្តថ្មីជាករណីដែលមានលើកដំបូងនៅលើសកលលោក បើដូច្នេះវាមិនអាចយកច្បាប់ដែលមានស្រាប់មកអនុវត្តទេ ។ ដូច្នេះហើយការសម្របសម្រួលលើកទី១គឺតុលាការជាតិ ដោយមានអង្គជំនុំជម្រះវិសាមញ្ញ ហើយមានការចូលរួមពីចៅក្រមបរទេស ។ ការសម្របសម្រួលទី២ នៅពេលដែលយើងទទួលឲ្យចៅក្រមបរទេសចូលរួម ហើយជំហានទី២នៅតែទាល់ច្រក ហើយនៅតែគិតគឺគេលើកឡើងថា សូមឲ្យចៅក្រមបរទេសភាគច្រើន យើងថាចៅក្រមខ្មែរភាគច្រើន ដូច្នេះវានៅគាំងមួយលើកទៀតដោះស្រាយការគាំងនេះ ដែលយើងឈានមកដល់គោលការណ៍ថ្មីមួយទៀតគឺថាគេសុខចិត្តឲ្យយើងមានភាគច្រើន គេភាគតិច ប៉ុន្តែគេជា* Minorité Bloquante *ភាគតិចដែលអាចរាំងស្ទះបាន ។ ដូច្នេះគឺចេញតាមរូបមន្តថ្មីមួយទៀតដែលមិនដែលមាននៅលើសកលលោក ។ ជំហានទី៣នៃការសម្រុះសម្រួលគឺសហចៅក្រមស៊ើបអង្កេតដូចដែលទូលបង្គំបានលើកឡើងគឺយើងបានប្រាប់គេថា លោកមិនដែលស្គាល់ចៅក្រមស៊ើបអង្កេតនេះផងមិនចាំបាច់ធ្វើទេ គឺទុកឲ្យកម្ពុជាធ្វើខ្លួនឯង លោកមានតែសហព្រះរាជអាជ្ញាបានហើយ ត្រង់ចំណុចនេះគឺគេក៏មិនព្រមដែរ ។ ដូច្នេះតាមការសម្របសម្រួលមួយរយៈទៅយើងឈានមកដល់រូបមន្តសម្រុះសម្រួលទី៣គឺឲ្យមានសហចៅក្រមស៊ើបអង្កេត ។ ជំហានទី៤ ដែលជាជំហានធំ ហើយមានសារៈសំខាន់ខ្លាំងគឺនៅពេលដែលសហព្រះរាជអាជ្ញាលោកមិនឯកភាពគ្នា បានន័យថាសហព្រះរាជអាជ្ញាលោកចោទប្រកាន់ ម្នាក់ថាចោទ ហើយម្នាក់ទៀតថាទេ អត់ចោទទេ អ៊ីចឹងត្រូវសម្រេចយ៉ាងដូចម្តេច? ជាគោលការណ៍គឺយើងនិយាយអំពីសហប្រតិបត្តិការ ។ ដូច្នេះគោលការណ៍ទី១គឺត្រូវធ្វើដូចម្តេចដើម្បីឲ្យលោកពីរនាក់មានការស្រុះស្រួលគ្នាមានភាពឯកច្ឆ័ន្ទជាមួយគ្នាដើម្បីធ្វើការឲ្យរលូនជាមួយគ្នា* **(តទៅទំព័រទី១៥)**

# តើគោរពអង្គការវិន័យរបស់បក្សគឺគោរពអ្វី?

“គឺគោរពមាគ៌ានយោបាយ មាគ៌ាសតិអារម្មណ៍ មាគ៌ាសកម្មភាពរបស់បក្ស និងលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្សទាំងអស់ តែគឺពុំមែនគោរពបុគ្គលណាម្នាក់ ឬគោរពគណៈកម្មាធិការណាមួយនោះទេ” ។ “៖” នេះបានន័យថា យើងគោរពសមមិត្តតំណាងអង្គការ ឬគណៈកម្មាធិការដឹកនាំផ្សេងៗក្នុងឋានៈដែលសមមិត្តនោះ ឬគណៈកម្មាធិការនោះៗណែនាំយើង អប់រំយើងនិងដឹកនាំយើងតាមមាគ៌ាត្រឹមត្រូវរបស់បក្សតាមលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្សនិងតាមគោលការណ៍ត្រឹមត្រូវរបស់បក្ស ។ តែបើសមមិត្តនោះ ឬគណៈកម្មាធិការនោះ ដឹកនាំយើងទៅផ្លូវខុសឬអប់រំណែនាំយើងឲ្យធ្វើខុស ឬធ្វើផ្ទុយអំពីមាគ៌ារបស់បក្ស ផ្ទុយអំពីលក្ខការណ៍ចាត់តាំងរបស់បក្ស ឬខុសអំពីគោលការណ៍ផ្សេងៗរបស់បក្ស នោះយើងមិនត្រូវអនុវត្តតាមជាដាច់ខាត ទោះបីសមមិត្តនោះ ឬគណៈកម្មាធិការនោះជាកម្មាភិបាលដឹកនាំថ្នាក់ណាក៏ដោយ ។ ហើយផ្ទុយទៅវិញ យើងត្រូវតែធ្វើការតស៊ូទប់ទល់មិនឲ្យគេបញ្ឆោរយើងឲ្យធ្វើខុស ហើយតស៊ូកសាងអូសទាញគេឲ្យមកតាមគន្លងត្រឹមត្រូវនៃមាគ៌ារបស់បក្ស នៃលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្ស និងគោលការណ៍ផ្សេងៗរបស់បក្សវិញដាច់ខាត ។ ធ្វើយ៉ាងនេះទើបហៅថាគោរពអង្គការវិន័យរបស់បក្សដោយឥតលក្ខខណ្ឌនិងដោយភ្ញាក់រឭក ។

### ១) គោរពអង្គការវិន័យ ដោយឥតលក្ខខណ្ឌ

ដើម្បីគោរពអង្គការវិន័យរបស់បក្សដោយឥតលក្ខខណ្ឌ បានលុះត្រាតែយុវជន-យុវនារីបដិវត្តយើងជ្រួតជ្រាបនូវសារសំខាន់នឹងការចាំបាច់នៃអង្គការវិន័យរបស់បក្សនៅក្នុងចលនាតស៊ូបដិវត្ត កាលពីក្នុងសម័យតស៊ូនយោបាយសម្ងាត់និងក្នុងសម័យធ្វើសង្គ្រាមបដិវត្តដែលសភាពការណ៍តឹងតែង ខ្មាំងធ្វើការបង្ក្រាបរាតត្បាត កាប់សម្លាប់បង្ហូរឈាមរៀងរាល់ថ្ងៃ ក៏ដូចក្នុងសម័យធ្វើបដិវត្តសង្គមនិយម កសាងសង្គមនិយមក្នុងសន្តិភាពបច្ចុប្បន្ននេះដែរ ។ ហើយជាពិសេសក្នុងសម័យធ្វើបដិវត្តសង្គមនិយមនិងកសាងសង្គមនិយម ក្នុងពេលសន្តិភាពបច្ចុប្បន្ននេះវារឹតតែទាមទារឲ្យមានអង្គការវិន័យរឹងប៉ឹង ហ្មត់ចត់ ត្រឹមត្រូវដាច់ខាតណាស់ទៅទៀត ។ ព្រោះអីបច្ចុប្បន្ននេះ ពិតមែនតែប្រទេសយើងមានសន្តិភាព ដោយប្រៀបធៀបទៅក្នុងពេលសង្គ្រាម ពិតមែនតែចក្រពត្តិអាមេរិក និងចក្រពត្តិដទៃផ្សេងទៀតត្រូវវាយបណ្តេញចេញផុតអស់ពីទឹកដីកម្ពុជាក៏ដោយ ពិតមែនតែវណ្ណៈសក្តិភូមិនាយទុនត្រូវវាយរំលំអស់ជាមូលដ្ឋានពីក្នុងសង្គមជាតិយើងហើយ តែមារសត្រូវគ្រប់ប្រភេទរបស់យើងវានៅតែបន្តធ្វើសកម្មភាពទាំងសម្ងាត់ ទាំងចំហ ទាំងមកពីក្រៅទាំងនៅផ្ទៃក្នុងប្រទេសជាប់ជាបន្តបន្ទាប់ ប៉ុនប៉ងវាយរំលំរបបគ្រប់គ្រងបដិវត្តដ៏ត្រឹមត្រូវ ស្អាតស្អំ ល្អបរិសុទ្ធរបស់យើងនេះឲ្យវិនាសសូន្យទៅវិញ ។ សកម្មភាពយោធាវាយពីក្រៅក៏វាធ្វើ ។ តែចំពោះសកម្មភាពបែបនេះយើងមើលឃើញ យើងអាចទប់ទល់ និងវាយកម្ទេចបានជាបន្តបន្ទាប់មកហើយ ។ ដូច្នេះមិនជាបញ្ហាគួរឲ្យព្រួយបារម្ភឡើយ ។ តែបញ្ហាដែលគួរឲ្យយើងចាប់អារម្មណ៍ប្រុងប្រយ័ត្នជាប់ជានិច្ច គឺសកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជួរបដិវត្តយើងតែម្តង ដើម្បីវាយផ្តួលបដិវត្តន៍យើងខាងគោលជំហរដោយបង្វែរមាគ៌ាដ៏ត្រឹមត្រូវល្អបរិសុទ្ធរបស់បក្សឲ្យងាកទៅផ្លូវនាយទុនវិញបន្តិចម្តងៗ ដោយវាបំភ្លៃមាគ៌ានិងលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្ស ទៅតាមទិសឧបាយកលខ្មៅងងឹតរបស់វានៅក្នុងរាល់សកម្មភាពបដិវត្តប្រចាំថ្ងៃ និងដោយវាចាត់តាំងបញ្ចូលមកក្នុងជួរបដិវត្ត សុទ្ធតែសមាសភាពមិនល្អ សមាសភាពឱកាសនិយម និងសមាសភាពខ្មាំងគ្នា វាធ្វើឲ្យជួរបដិវត្តយើងប្រែក្លាយធាតុបន្តិចម្តងៗ រហូតដល់ប្រែក្លាយពណ៌សម្បុរទាំងស្រុង ។ល។ ឃើញឧបាយកលពិសពុលខ្មៅងងឹតរបស់ខ្មាំងយ៉ាងនេះ ឃើញសកម្មភាពបំផ្លិចបំផ្លាញបក្សបដិវត្តយើងរបស់ខ្មាំងយ៉ាងនេះ ទើបយើងឃើញនូវការចាំបាច់ថាបច្ចុប្បន្ននេះរឹតតែត្រូវពង្រឹងគោលជំហរគោរពអង្គការវិន័យរបស់បក្ស

ដោយឥតលក្ខខណ្ឌ គ្មានរាករេ គ្មានរារាំង និងដាច់ខាតថែមទៀត ។ បើមិនដូច្នេះទេ បើយុវជន-យុវនារីបដិវត្តយើងធូររលុងខាងអង្គការវិន័យនេះហើយ បើយើងធ្លាក់ទៅក្នុងផ្លូវសេរីនិយមឬធ្លាក់ទៅក្នុងអនាធិបតេយ្យហើយនោះ យុវជន-យុវនារីយើងមុខជានឹងធ្លាក់ចូលអន្ទាក់ខ្មាំង មុខជានឹងលុះទៅតាមឧបាយកលពិសពុលខ្មៅងងឹតរបស់ខ្មាំងពុំខានឡើយ ។ ការនេះបានសេចក្តីថាយើងបើកទ្វារចំហឲ្យខ្មាំងចូលធ្វើសកម្មភាពបំផ្លិចបំផ្លាញបក្សបដិវត្តប្រទេសជាតិ និងប្រជាជនយើង ដោយស្របច្បាប់ហើយ ។ ដូច្នេះទោះចង់ឬមិនចង់ ទោះដឹងខ្លួនក្តីឬមិនដឹងខ្លួនក្តី យើងនឹងក្លាយទៅជាអ្នករួមគំនិតបម្រើខ្មាំង ក្លាយទៅជាដៃជើងបម្រើខ្មាំងក្នុងការបំផ្លិចបំផ្លាញបក្សបដិវត្ត ប្រទេសជាតិ និងប្រជាជនឯងទៅវិញ ។ នេះជាគ្រោះអាសន្នធំណាស់ ចំពោះការធូររលុងខាងអង្គការវិន័យ ឬការមិនគោរពអង្គការវិន័យរបស់បក្សដោយត្រឹមត្រូវ ម៉ឺងម៉ាត់ដាច់ខាត ។

## ៧) គោរពអង្គការវិន័យ ដោយភ្ញាក់រឭក

ដើម្បីគោរពអង្គការវិន័យ ដោយភ្ញាក់រលឹកបានលុះត្រាតែយុវជន-យុវនារីបដិវត្តយើងយល់ជ្រួតជ្រាបមាគ៌ានយោបាយ-សតិអារម្មណ៍គ្រប់ផ្នែករបស់បក្ស ក្តាប់ជាប់នូវលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្ស ។ ដូច្នេះ យុវជន-យុវនារីបដិវត្តយើងចាំបាច់ត្រូវខិតខំរៀនសូត្រឲ្យស្គាល់ ឲ្យយល់ ឲ្យដឹង តើមាគ៌ានយោបាយ-សតិអារម្មណ៍របស់បក្សយ៉ាងណា តើលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្សមានអ្វីខ្លះ ហើយយ៉ាងណាខ្លះ ។ លុះត្រាតែយុវជន-យុវនារីបដិវត្តយើងខិតខំរៀនសូត្រ ក្តាប់ឲ្យជាប់នូវមាគ៌ានយោបាយ មាគ៌ាសតិអារម្មណ៍ និងលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្សបាន ទើបគោរពអង្គការវិន័យរបស់បក្សបានល្អនឹងដោយភ្ញាក់រឭក ។ ទាល់តែភ្ញាក់រឭកយ៉ាងនេះ ទើបយុវជន-យុវនារីបដិវត្តយើង ចេះពិនិត្យពិចារណា ចេះវិភាគនិងវិនិច្ឆ័យពេលឃើញជនណា ទោះបីជាមានឋានៈនាទីជាអ្វីក៏ដោយ ឲ្យតែដឹកនាំឬអនុវត្តខុសពីមាគ៌ា ខុសពីលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្សហើយ នោះយើងហ៊ានតស៊ូ យើងមិនចេះតែគោរពធ្វើតាមដោយងងឹតងងល់ឡើយ ។ ម្យ៉ាងទៀតយើងអាចសម្គាល់ឬបែងចែកតើអ្នកណាជាអ្នកបដិវត្តត្រឹមត្រូវ អ្នកណាជាអ្នកបដិវត្តក្លែងក្លាយ ឬជាសមាសភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តយើង ។

ធ្វើយ៉ាងនេះទើបយុវជន-យុវនារីបដិវត្តយើងអាចពង្រឹងគោលជំហរគោរពអង្គការវិន័យដោយឥតលក្ខខណ្ឌ និងដោយភ្ញាក់រឭកបានដើម្បីរួមចំណែកកសាងពង្រឹងពង្រីកជួរបក្ស ជួរបដិវត្តយើងឲ្យកាន់តែល្អបរិសុទ្ធ ជួរជង់ រឹងប៉ឹង ខ្លាំងក្លាឡើងដើម្បីបន្តដឹកនាំធ្វើបដិវត្តសង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាឲ្យបានជោគជ័យទាំងស្រុង និងជាស្ថាពរទៀត ។

មិត្តយុវជន-យុវនារីបដិវត្តទាំងឡាយ! មិត្តជាអ្នកបន្តវេនធ្វើបដិវត្តន៍សង្គមនិយម សម្រេចបដិវត្តសង្គមនិយមនៅកម្ពុជាឲ្យបានជោគជ័យដាច់ខាតដើម្បីឈានទៅធ្វើបដិវត្តសង្គមនិយមនិងកុម្មុយនិស្តនិយមនៅកម្ពុជាទៀត ។ ដូច្នេះអនាគតរបស់បក្សកុម្មុយនិស្តកម្ពុជា អនាគតនៃចលនាបដិវត្តកម្ពុជាយើង ក៏ដូចជាអនាគតនៃប្រទេសជាតិ និងប្រជាជនកម្ពុជាយើងទាំងមូលដែរគឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់មិត្តទាំងឡាយហើយ! ដូច្នេះមិត្តទាំងឡាយមិនមែនជាអ្នកចាំតែអនុវត្ត ចាំតែធ្វើការងារដាក់ស្តែងដោយឥតលក្ខខណ្ឌ ដោយគ្មានគិតគូរពិចារណាការខុស ការត្រូវដោយគ្មានយល់ដឹងអំពីមាគ៌ានយោបាយ-សតិអារម្មណ៍ និងលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្សឡើយ ។ មិត្តមិនត្រឹមតែធ្វើការងារសកម្មប្រយុទ្ធមួយមុខប៉ុណ្ណោះទេ តែព្រមជាមួយនេះមិត្តត្រូវខិតខំរៀនសូត្រមាគ៌ានយោបាយ-សតិអារម្មណ៍នឹងលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្សជាប់ជានិច្ច ឲ្យកាន់តែក្តាប់បានឲ្យកាន់តែជ្រួតជ្រាបច្រើនឡើងៗជានិច្ច ហើយខិតខំពង្រឹងគោលជំហរ គោរពអង្គការវិន័យរបស់បក្សដោយឥតលក្ខខណ្ឌនឹងដោយភ្ញាក់រលឹកដាច់ខាត ។ ធ្វើយ៉ាងនេះទើបមិត្តទាំងឡាយអាចបន្តវេនបដិវត្តសង្គមនិយមនិងកុម្មុយនិស្តទៅអនាគតទៀតបានត្រឹមត្រូវល្អមិនព្រួយបារម្ភពីរឿងសេរីនិយម មិនព្រួយបារម្ភពីរបបនាយទុនងើបក្បាលឡើងវិញនៅកម្ពុជាយើង ។ **ស៊ឹម សុភ័ក្រ្ត**

***(ដកស្រង់ចេញពីសៀវភៅយុវជន និងយុវនារីបដិវត្ត លេខ៨ ខែសីហា ឆ្នាំ១៩៧៦)***

# រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម

ខេត្តកំពង់ចាមជាខេត្តដែលមានផ្ទៃដីធំទូលាយ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យខេត្តនេះគឺស្ថិតនៅក្នុងភូមិភាគឧត្តរ និងភូមិភាគបូព៌ាដែលមានព្រំប្រទល់ខាងកើតជាប់នឹងប្រទេសវៀតណាម ខាងលិចជាប់នឹងខេត្តកំពង់ឆ្នាំង ខាងជើងជាប់នឹងខេត្តក្រចេះ និងកំពង់ធំ និងខាងត្បូងជាប់នឹងខេត្តព្រៃវែង ។ ខេត្តកំពង់ចាមមានស្រុកចំនួន១៦ និងឃុំចំនួន១៧៣ ជាចំណុះនៃខេត្ត ។ ផ្ទៃដីរួមរបស់ខេត្ត ៩៧៩ ៨៦០ គីឡូម៉ែត្រការេ ។

នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៨ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅកាន់ខេត្តកំពង់ចាម ដើម្បីធ្វើការសិក្សាស្រាវជ្រាវពីទីតាំងប្រល័យពូជសាសន៍នៅស្រុកព្រៃឈរ ។

## ១) ស្រុកព្រៃឈរ

ស្រុកព្រៃឈរជាស្រុកមួយក្នុងចំណោមស្រុកទាំង១៦នៃខេត្តកំពង់ចាម ។ ស្រុកនេះស្ថិតក្នុងតំបន់៤២ ក្នុងភូមិភាគឧត្តររបស់ខ្មែរក្រហម ដែលមានទីតាំងសាលាស្រុកស្ថិតនៅខាងលិចសាលាខេត្តកំពង់ចាមចម្ងាយ២៨គីឡូម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ៧អា ។ ព្រំប្រទល់របស់ស្រុកព្រៃឈរគឺខាងកើតជាប់នឹងស្រុកកំពង់សៀម ខាងលិចជាប់នឹងស្រុកជើងព្រៃ ខាងត្បូងជាប់នឹងស្រុកកងមាស និងខាងជើងជាប់នឹងស្រុកបារាយណ៍ខេត្តកំពង់ធំ ។ មានប្រជាជនរួមចំនួន ១២៧ ០០០នាក់ (គិតត្រឹមឆ្នាំ១៩៩៨) ក្នុងនោះមានប្រជាជនភាគច្រើនប្រកបរបរធ្វើស្រែចម្ការនិងឡើងត្នោត ។ ស្រុកព្រៃឈរ មានឃុំចំនួន១៥ និង១៧៦ភូមិ ។

តាមការផ្តល់ពត៌មានពីសាលាស្រុកព្រៃឈរថាមានទីតាំងសម្លាប់មួយកន្លែងនិងមន្ទីរសន្តិសុខមួយកន្លែង ។

### ក) ទីតាំងសម្លាប់នៅទួលត្រពាំងល្ហុ លេខកូដភូមិសាស្ត្រ ០៣១៣០២

ទីតាំងភូមិសាស្ត្រនៃទួលត្រពាំងល្ហុតាមរយៈការប្រើប្រាស់



ទីតាំងសម្លាប់នៅទួលត្រពាំងល្ហុ

ប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកគឺខ្សែបណ្តោយ E១០៥º ១៥' ៣៣:៩៧" និងចំណុចខ្សែស្រប N១២º ០៤' ១០:៤០" ។ ទីតាំងសម្លាប់នៅទួលត្រពាំងល្វា ស្ថិតនៅភូមិដូនដី ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ ទីតាំងសម្លាប់នេះបច្ចុប្បន្នបាន បន្សល់ទុកនូវស្នាកស្នាមរណ្តៅមួយចំនួន ដូចជានៅមានភាព ក្រហេងក្រហូង និងមានលក្ខណៈខុសប្លែកពីដីរាបស្មើធម្មតា ។ ប្រធានភូមិដូនដីឈ្មោះ ឈាន ហៀង បាននិយាយថា ស្នាកស្នាម ក្រហេងក្រហូងនេះជាអតីតរណ្តៅកប់សាកសពសម័យខ្មែរក្រហម ។ នៅឆ្នាំ១៩៨២ រណ្តៅទាំងនោះត្រូវបានគាស់យកអដ្ឋិធាតុទៅ តម្កល់ទុកដោយប្រជាជនក្នុងភូមិក្រោមការចាត់ចែងរបស់ប្រធាន ភូមិ ។ ទំហំដីនៃទួលត្រពាំងល្វាមានទទឹង៥០ម៉ែត្រ និងបណ្តោយ ប្រហែល១០០ម៉ែត្រ ក្នុងនោះតាមការប៉ាន់ស្មានរបស់មេភូមិ ដូនដីថាមានចំនួនជាង១៥០រណ្តៅ ព្រមទាំងសាកសពប្រហែល ៥០០នាក់ ។ លោក ឈាន ហៀង បានប្រាប់បន្តថារណ្តៅធំៗ ច្រើនស្ថិតនៅលើទួលនិងរណ្តៅតូចៗផ្សេងទៀតគឺស្ថិតនៅតាម ជម្រាលនៃទួលក្នុងបរិវេណទីតាំងទួលត្រពាំងល្វា ។ ជនរងគ្រោះដែលត្រូវបានបញ្ចប់ជីវិតនៅលើទួលនេះច្រើនយកមកពីឃុំថ្មពូននិងឃុំជ្រៃវៀន ។ លោក ឈាន ហៀង បានពន្យល់ថាជនរងគ្រោះទាំងនោះមុននឹងស្លាប់សុទ្ធតែបានចាញ់កលរបស់ខ្មែរក្រហមថា អង្គការឲ្យមកប្រជុំដើម្បីមានផែនការ ។


ឈាន ហៀង

លោកតា ទេព ម៉ៅ អាយុ៦៧ឆ្នាំ បច្ចុប្បន្នរស់នៅភូមិ ដូនដី ឃុំជ្រៃវៀន ស្រុកព្រៃឈរ បានអធិប្បាយថា “ខ្ញុំបានឃើញ ផ្ទាល់ភ្នែកនូវការបណ្តើរមនុស្សយកទៅសម្លាប់នៅទួលត្រពាំងល្វា នេះគឺនៅម៉ោង១ឬ២រសៀលស្ទើរតែរាល់ថ្ងៃ” ។ ហេតុការណ៍នេះ ត្រូវបានលោកតា ទេព ម៉ៅ ប្រទះឃើញនៅពេលដែលគាត់កំពុង បណ្តើរគោឲ្យស៊ីស្មៅ ។ លោកតា ម៉ៅ បញ្ជាក់ថា ពួកខ្មែរក្រហម មិនអនុញ្ញាតឲ្យប្រជាជនដើរឆ្លងកាត់ ឬមកដាំដុះបន្លែបន្ការនៅ ជិតៗទួលនេះឡើយ ។ ជនរងគ្រោះដែលលោកតា ទេព ម៉ៅ ប្រទះឃើញទាំងចំណងមកកាន់ទួលត្រពាំងល្វានេះមានគ្រប់ប្រភេទ ដូចជា ទាហានឬកម្មាភិបាលខ្មែរក្រហមដែលលោកតាអាចសម្គាល់បានយ៉ាងច្បាស់ទៅលើឯកសណ្ឋានដាប់នឹងខ្លួនប្រជាជនចាស់ ប្រជាជនជម្លៀស ។ លោកតា ទេព ម៉ៅ បន្ថែមថាសូម្បីតែអ្នកលួចដំឡូង ចេក ឬខុសសីលធម៌បន្តិចបន្តួច ក៏ត្រូវមកបញ្ចប់ជីវិតនៅលើទួលនេះទាំងអស់ ។ ការសម្លាប់ មនុស្សនៅទួលត្រពាំងល្វា ប្រព្រឹត្តទៅតាំងពីឆ្នាំ១៩៧៦ ដែល កាលនោះលោកតា ទេព ម៉ៅ ត្រូវបានជម្លៀសទៅភូមិទួលចំបក់ ឃុំបារាយណ៍ ស្រុកព្រៃឈរ ដែលមានចម្ងាយមិនឆ្ងាយប៉ុន្មានពី ភូមិកំណើតនិងទួលត្រពាំងល្វាឡើយ ។


ទេព ម៉ៅ

### ១) មន្ទីរសន្តិសុខតំបន់៤២ ឬគុកវត្តតាមាក់ លេខកូដភូមិសាស្ត្រ ០៣១៣០១

ឲ្យតែនិយាយដល់មន្ទីរសន្តិសុខតំបន់៤២ ឬគុកវត្តតាមាក់ អ្នកស្រុកអ្នកភូមិក្នុងស្រុកព្រៃឈរទាំងអស់សុទ្ធតែលាន់មាត់ថា ជាគុកតំបន់ដែលធំជាងគេ ព្រមទាំងគ្រញែងខ្លួនបញ្ជាក់ពីភាព ភ័យខ្លាច តក់ស្លុតយ៉ាងខ្លាំងចំពោះទង្វើពីអតីតកាលរបស់ ខ្មែរក្រហមដែលបានសាបព្រោះនូវអំពើអមនុស្សធម៌ និងបានធ្វើ ឲ្យប្រជាជនខ្មែរខ្លាចខ្មើមរអើមនូវអំពើដ៏ព្រៃផ្សៃរបស់ខ្លួនក្នុងអំឡុង ឆ្នាំ១៩៧៥-១៩៧៩ ។ មន្ទីរសន្តិសុខតំបន់៤២ នេះត្រូវបាន រើកកាយមកនិយាយឡើងវិញក្រោមសំណួរដ៏ច្រើនដែលចោទ សួរជុំវិញបញ្ហាទាក់ទងនឹងមន្ទីរសន្តិសុខនេះ បូករួមនឹងការប្រើប្រាស់ ម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រពិភពលោកដែលប្រើដោយបុគ្គលិក នៃមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីបញ្ជាក់និងទុកជាឯកសារ ប្រវត្តិសាស្ត្រនៅក្នុងដែនទីរណ្តៅសាកសព ។ តាមលទ្ធផលដែល បានកំណត់ក្នុងម៉ាស៊ីនកត់ត្រាតាមផ្កាយរណបនេះបានឲ្យដឹងថា មន្ទីរសន្តិសុខតំបន់៤២ ស្ថិតនៅចំណុចខ្សែស្រប N ១២º ០៣' ៤១:៣១" និងរយៈបណ្តោយ E ១០៥º ១៤' ៥១:៦០" ។ មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងភូមិស្វែង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ។




វត្តជនតាណារ៉ាម ហៅតាមាក់ ត្រូវបានក្លាយជាមន្ទីរសន្តិសុខតំបន់៤២ តាំងពីឆ្នាំ១៩៧៣រហូតមកដល់ឆ្នាំ១៩៧៨ ។ មន្ទីរនេះបានប្រែក្លាយពីមន្ទីរសន្តិសុខទៅជាកន្លែងចិញ្ចឹមគោតាំងពីឆ្នាំ១៩៧៨រហូតដល់បែកឆ្នាំ១៩៧៩ ។ ក្នុងអំឡុងឆ្នាំ១៩៧៣-១៩៧៨ មន្ទីរសន្តិសុខនេះមានភារកិច្ចទទួលខុសត្រូវដាក់គុកមនុស្សចំនួន៤ស្រុកក្នុងខេត្តកំពង់ចាមគឺ ស្រុកកងមាស ព្រៃឈរ កំពង់សៀម និងជើងព្រៃ ។ លោកតា ជុន ចំរើន អាយុ៦១ឆ្នាំ បច្ចុប្បន្នជាគណៈកម្មការអាចារ្យវត្តជនតាណារ៉ាម ហៅតាមាក់ បានរៀបរាប់ថា មន្ទីរសន្តិសុខតំបន់៤២មានការបែងចែកអ្នកទោសជា២ប្រភេទ គឺពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ អ្នកទោសច្រើនជាប្រភេទប៉ូលិស កងជីវពល ទាហាន មន្ត្រីរាជការ ប្រធានឃុំ និងជំទប់ឃុំក្នុងជំនាន់ លន់ ណុល ។ ចំណែកឯពីឆ្នាំ១៩៧៥-៧៨ ប្រភេទអ្នកទោសភាគច្រើនជាប្រជាជនជម្លៀសពីភ្នំពេញ ទាំងក្មេង ចាស់ ប្រុស ស្រី បូករួមទាំងកងចល័តនិងកម្មាភិបាលរបស់ខ្មែរក្រហមខ្លួនឯងដែលត្រូវបានចោទថា "ក្បត់អង្គការ" ។ លោកតា ចំរើន និយាយថា មិនដែលមានអ្នកទោសណាម្នាក់រួចខ្លួនពីសេចក្តីស្លាប់ឡើយ ។ ជនរងគ្រោះស្ថិតនៅពេញៗគ្រប់កុដិទាំងអស់ ។ សាលាឆាន់ត្រូវបានពួកខ្មែរក្រហមយកមកធ្វើជាកន្លែងដាក់ពួកយោធាខ្មែរក្រហម ចំណែកឯកន្លែងផ្សេងៗទៀតត្រូវបានខ្មែរក្រហមយកធ្វើជាឃ្លាំងដាក់គ្រឿងជយភណ្ឌដែលរឹបអូសបានពីប្រជាជនជម្លៀស ។


ជុន ចំរើន

លោកតា ជុន ចំរើន បានបន្តថា ចំពោះការធ្វើទណ្ឌកម្មវិញ គឺខ្មែរក្រហមចងជើងអ្នកទោសព្យួរឡើងលើឲ្យផុតពីដី រួចទើបវាយសួរចម្លើយ ។ បន្ទាប់ពីសួរចម្លើយរួចខ្មែរក្រហមបានបញ្ជូនអ្នកទោសទាំងនោះទៅរៀនសូត្រ ។ តាមសម្តីរបស់លោកតា ជុន ចំរើន ថា "ពួកវា (ខ្មែរក្រហម) គ្មានបានបញ្ជូនទៅរៀនទេគឺយកទៅសម្លាប់ទាំងអស់ដោយដឹកទាំងឡានៗចេញទៅ" ។

លោកតា កេត ម៉ុច ជាអាចារ្យវត្តតាមាក់បានបន្ថែមថា

របៀបសួរចម្លើយរបស់ខ្មែរក្រហមនៅមន្ទីរសន្តិសុខនេះ គ្មានអ្វីក្រៅពីសួរថា "ឯងមានគ្នាប៉ុន្មាននាក់? ហឹងមានគ្នាប៉ុន្មាននាក់?"។ ទោះជាឆ្លើយក្តី មិនឆ្លើយក្តី ក៏គង់តែស្លាប់ទាំងអស់។ លោកតា កេត ម៉ុច បន្តថា "គ្មានប្រជាជនណាម្នាក់បានចូលទៅជិតមន្ទីរសន្តិសុខ នេះទេប៉ុន្តែខ្ញុំអាចមើលឃើញសកម្មភាពរបស់ខ្មែរក្រហមធ្វើបាបជនរងគ្រោះ ព្រោះពេលនោះខ្ញុំកំពុងឃ្វាលគោនៅវាលស្រែដែលមានចម្ងាយប្រហែលពី១០០-២០០ម៉ែត្រពីរបងវត្ត (មន្ទីរសន្តិសុខតំបន់៤២)។ សកម្មភាព


កេត ម៉ុច

ដែលលោកតា កេត ម៉ុច បានឃើញ គឺការសួរចម្លើយទៅលើអ្នកទោសប្រភេទធ្ងន់ដោយចងព្យួរអ្នកទោសឲ្យផុតពីដី រួចវាយសួរចម្លើយទាល់តែស្លាប់នឹងកន្លែងក៏មាន។ ចំពោះអ្នកទោសស្រាលវិញ ពួកខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើស្រែដោយបង្អត់អាហារនៅក្បែរៗមន្ទីរសន្តិសុខនេះ។ អ្នកទោសត្រូវបញ្ចេញទាំងឡានៗយកទៅសម្លាប់ ប៉ុន្តែមិនដឹងយកទៅសម្លាប់នៅកន្លែងណាទេ។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ លោកតា កេត ម៉ុច បានចូលមកកាន់វត្តតាមាក់ ហើយបានប្រទះឃើញស្លាកស្នាមនៅសេសសល់ដូចជាស្នាមចោះខ្សៀនជញ្ជាំង កុដិ រនុកដែកនិងខ្នោះជាច្រើនដែលក្រោយមកឧបករណ៍ទាំងនោះត្រូវបានលោកតា កេត ម៉ុច ប្រមូលយកទៅបោះចោលទាំងអស់ព្រោះគាត់យល់ថាជាឧបករណ៍ក្តៅក្រហាយនាំឲ្យមនុស្សរស់មិនបានសុខ។

**ផេង ពង្សរ៉ាស៊ី**

---

**(តមកពីទំព័រទី៩)** តែយើងក៏បានត្រៀមថាចុះបើរលូនបានតើយើងត្រូវធ្វើដូចម្តេច? ដូច្នេះយើងឯកភាពគ្នាយកដំណោះស្រាយមួយ គឺបង្កើតក្បាលម៉ាស៊ីនមួយថ្មីទៀតដែលនេះក៏មិនដែលមាននៅក្នុងប្រវត្តិច្បាប់តុលាការពីមុនមកទេ គឺអ្វីដែលគេហៅថា Pre-trial Chamber មានន័យថាមុនជំនុំជម្រះក្បាលម៉ាស៊ីននោះ ជំនុំជម្រះមួយលើកសិន ដែលមានន័យជាខ្មែរថាអង្គបុរេជំនុំជម្រះ ដូច្នេះអាចអស់លោកខ្លះបានសួរថាហេតុអ្វីបានជាដាក់ពាក្យថ្មីបែបនេះ ព្រោះពាក្យនេះវាមិនដែលមានពីមុនមក ព្រោះក្បាលម៉ាស៊ីននេះមិនដែលមានពីមុនមកដែរ ដូច្នេះយើងត្រូវរកពាក្យថ្មីដាក់ហើយពាក្យថ្មីនោះគឺ អង្គបុរេជំនុំជម្រះ ពាក្យនេះទើបតែកើតជាលើកទី១ ដើម្បីផ្តល់ដំណោះស្រាយដល់សហព្រះរាជអាជ្ញាក្នុងករណីដែលសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតគាត់ទាស់គ្នា។ ដូច្នេះនេះជាដំណោះស្រាយដែលជំហានទាំង៤នៃការសម្រុះសម្រួលរវាងយើងនិងអង្គការសហប្រជាជាតិ។ ចំណុចទី៥ គឺការលើកលែងទោស និងការអនុគ្រោះទោស។ ខាងអង្គការសហប្រជាជាតិមិនចង់ឲ្យមានការលើកលែងទោស និងការអនុគ្រោះទោសចំពោះជនណាដែលត្រូវទទួលទោសតាមច្បាប់នេះទេ។ ប៉ុន្តែតាមរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រមានព្រះរាជសិទ្ធិបន្ធូរបន្ថយទោសនិងលើកលែងទោស។ ការសម្របសម្រួលគឺយើងបានព្រមព្រៀងគ្នាថា រាជរដ្ឋាភិបាលនឹងមិនធ្វើសំណើឲ្យមានការលើកលែងទោសនិងការអនុគ្រោះទោសចំពោះជនណាដែលទទួលទោសនៅក្រោមច្បាប់នេះទេ។ ◆ នៅក្នុងការសន្និដ្ឋានទូលបង្គំយើងខ្ញុំយល់ឃើញថា បើយើងពិនិត្យច្បាប់នេះគឺទាល់តែយើងគិតអំពីទិដ្ឋភាពទាំងអស់ឲ្យគ្រប់ជ្រុងជ្រោយ បានន័យថា ទាំងទិដ្ឋភាពច្បាប់ ទាំងទិដ្ឋភាពនយោបាយ ទាំងទិដ្ឋភាពប្រវត្តិសាស្ត្រ វាពាក់ព័ន្ធឲ្យគ្រប់ជ្រុងជ្រោយ បានន័យថា ទាំងទិដ្ឋភាពច្បាប់ ទាំងទិដ្ឋភាពនយោបាយ ទាំងទិដ្ឋភាពប្រវត្តិសាស្ត្រវាពាក់ព័ន្ធគ្នាប្រទាក់ប្រទិនគ្នាទាំងអស់ បើយើងគិតតែពីច្បាប់យើងផ្អែកទៅលើច្បាប់អ្វីដែលយើងមានថាខុសច្បាប់ គឺច្បាប់នេះមិនអាចទៅរួចទេ។ ដូច្នេះបានជាទូលបង្គំខ្ញុំបាទសូមលើកចំណុចនេះជាមុនសិន បើយើងគិតថា យើងយកច្បាប់ដែលមានមកមើល ហើយគិតច្បាប់ណាដែលអត់មានវាខុសច្បាប់ នោះច្បាប់នេះមិនអាចទៅរួចទេ ច្បាប់នេះលើកឡើងនូវរូបមន្តថ្មី នូវទស្សនទានថ្មី ហើយក៏គោលការណ៍ថ្មីធំៗដូចដែលទូលបង្គំខ្ញុំបាទលើកឡើងទូលថ្វាយអង្គសភាជាទីគោរពដែរ ហើយដែលឆ្លុះបញ្ចាំងនូវជំហានសម្រុះសម្រួលទាំង៥ធំៗដែលជាលទ្ធផលនៃការចរចាយ៉ាងយូរអង្វែងនៃដំណើរការមួយយ៉ាងយូរអង្វែងតាំងពីឆ្នាំ១៩៩៧-១៩៩៨-១៩៩៩ ដល់ចុងឆ្នាំ២០០០នេះ។ ទូលបង្គំខ្ញុំបាទសូមធ្វើសេចក្តីផ្តើមត្រឹមតែប៉ុណ្ណេះ។ **ចប់**

# ករណីអ្នកទោស ម៉ាន ម៉ាត់ ហៅ ម៉ាន ម៉ន


ម៉ាន ម៉ាត់

ក្រោយពីការតស៊ូដ៏ស្មោះស្ម័គ្រនិងស៊ុតស៊្វាញ បម្រើបក្សកុម្មុយនិស្តរបស់ខ្មែរក្រហមអស់រយៈពេល ៥ឆ្នាំរហូតដល់ធ្លាក់ខ្លួនពិការ ដោយខ្វាក់ភ្នែកម្ខាងនិងដាច់ដៃម្ខាងក្នុងការប្រយុទ្ធវាយដណ្តើមយកអំណាចពីរបប លន់ ណុល ជូនបក្ស នៅសមរភូមិភ្នំប្រសិទ្ធ នាដើមឆ្នាំ១៩៧៥ ម៉ាន ម៉ាត់ ហៅ ម៉ាន ម៉ន បានក្លាយជាអ្នកទោសមន្ទីរស-២១ ឬគុកទួលស្លែង នៅខែតុលា ឆ្នាំ១៩៧៥ ។ ខ្ញុំបានជួប ម៉ាន ហាល់ម៉ាស់ ជាម្តាយរបស់ ម៉ន ដែលសព្វថ្ងៃកំពុងរស់នៅក្នុងសភាពកំព្រា បាត់ប្តី បាត់កូន ហើយបានថ្លែងប្រាប់ខ្ញុំអំពីរឿងរ៉ាវដែលបានកើតឡើងចំពោះកូនប្រុសរបស់គាត់តែមួយគត់ (ម៉ាន ម៉ាត់ ហៅម៉ាន ម៉ន) ហើយដែលត្រូវបានអង្គការចាប់បញ្ជូនយកទៅធ្វើកងទ័ព ។ នៅក្រោយឆ្នាំ១៩៧៩ ហាល់ ម៉ាស់ ចាំមើលផ្លូវកូនត្រឡប់មកវិញ ។ រហូតដល់មកទល់ថ្ងៃនេះ គាត់មិនបានឃើញកូនត្រឡប់មកវិញឡើយ ។ គាត់លាន់មាត់ថា «មានតែពាក្យចចាមអារ៉ាម ខ្លះគេថានៅឯណេះ ខ្លះថានៅឯណោះ ។ ថារស់ក៏មិនដឹង ។ តាមខ្ញុំដឹងប្រហែលជាស្លាប់ ហើយបានជាមិនឃើញមក បើរស់មកហើយ» ហាល់ម៉ាស់និយាយប្រាប់ខ្ញុំទាំងរអ៊ូកខ្សួល ។ លោកអ៊ំប្រុសរបស់ ម៉ន ម្នាក់ឈ្មោះ ម៉ាន សឹម ក៏បានប្រាប់ដែរថា «ឥឡូវឃើញតែគេមក ចំណែកវាម្នាក់អត់ឃើញមក អ៊ីចឹងមានតែស្លាប់ទៅហើយ» ។

មុនពេលដែល ម៉ន ស្លាប់ទៅ គាត់បានបន្សល់ទុកនូវចម្លើយសារភាពតាមឯកសារមួយមានចំនួន១៥៨ទំព័រ ។ ឯកសារនោះត្រូវបានរក្សាទុកឲ្យអ្នកនៅរស់រួមមានក្រុមគ្រួសាររបស់ ម៉ន ជាពិសេស កុលបុត្រ-កុលធីតាជំនាន់ក្រោយ បានដឹងពីប្រវត្តិសាស្ត្រអំពីទុក្ខវេទនាក្តីឈឺចាប់និងការស្លាប់រង្គាលនៅមន្ទីរស-២១ ។ ការរៀបរាប់អំពីការតស៊ូ ការលះបង់ខ្លួនដើម្បីបម្រើខ្មែរក្រហម ក្នុងចម្លើយសារភាពនិងការបំភ្លឺរបស់ម្តាយនិងអ៊ំប្រុសរបស់ ម៉ន អំពីការប្តេជ្ញាចិត្តរបស់ ម៉ន ចូលធ្វើយុទ្ធជនខ្មែរក្រហម បើយកមកប្រៀបធៀបនឹងការចាប់ខ្លួននិងការសម្លាប់ ម៉ន ហាក់ដូចជាស្តែងចេញនូវភាពអយុត្តិធម៌ ។

ម៉ន ជាក្មេងកំព្រាឪពុកតាំងពីអាយុ៤ឆ្នាំ រស់នៅជាមួយម្តាយក្នុងភូមិព្រៃកបាក់ ឃុំព្រៃកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ស្ថិតក្នុងសភាពទីទ័លក្រ ម៉ន ពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីចូលសាលារៀនទេ ។ ដើម្បីបានប្រាក់កាសបន្តិចបន្តួចទិញអង្ករហូបជាមួយម្តាយដែលមានវ័យចំណាស់ ម៉ន បានដើររកត្រីដូចជាចងសន្ទូច ដាក់មងតាមបឹងខាងក្រោយភូមិ ។ លុះ ម៉ន មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ១៩៦៩ ក៏ទៅរកស៊ីតាមអ្នកភូមិចាស់ៗយកសណ្តែកដឹកតាមកង់ពីភូមិអណ្តូងស្វាយ ឃុំអណ្តូងស្វាយ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ទៅលក់នៅព្រំប្រទល់វៀតណាម ។ តាំងពីពេលនោះហើយដែល ម៉ន បានឆ្លើយថាបានចូលសេ.អ៊ី.អា តាមរយៈឈ្មោះ ហេង និង ព្រួញ ដែលធ្លាប់រកស៊ីជាមួយគ្នាហើយទទួលបានប្រាក់ខែពីសេ.អ៊ី.អា ចំនួន៦០០០រៀល នៅពេលចូលធ្វើដំបូង និងក្រោយមកដល់ឆ្នាំ១៩៧០ បានប្រាក់ខែ១៥០០០រៀល និងរហូតដល់ឆ្នាំ១៩៧៤ ប្រាក់ខែឡើងដល់ ៦៥០០០រៀល ។

ហាល់ម៉ាស់ បានមានប្រសាសន៍ថា «កូនខ្ញុំមិនទាំងចេះនិយាយខ្មែរទេ ទៅនោះដោយសារគេទេ ដែលយកសណ្តែកទៅលក់នោះ រឿងកូនខ្ញុំល្ងង់ណាស់ អត់ចេះនិយាយខ្មែរឯណា» ។ ហាល់ម៉ាស់ បន្ថែមទៀតថា «បន្ទាប់ពីរកស៊ីលក់សណ្តែកហើយ អត់បានធ្វើអីទេ មានតែទៅចងសន្ទូចបន្តិចទៅ រត់ទៅដាក់មងបន្តិចទៅ គ្រាន់តែផ្គត់មាត់ស៊ី អត់មានលក់ដូរឲ្យអ្នកណាៗទេ» ។ ការអះអាងរបស់ ហាល់ម៉ាស់ ពុំមានចំណុចណាដែលគួរសង្ស័យ

ថា ម៉ន បានចូលរួមនៅក្នុងសកម្មភាពនយោបាយជាសមាជិក សេ.អ៊ី.អា និងបានទទួលប្រាក់ខែពីសេ.អ៊ី.អាតាំងពីឆ្នាំ១៩៦៩ ដូចក្នុងចម្លើយសារភាពនោះឡើយ ។

តាមចម្លើយសារភាព ម៉ន ថាបានចូលធ្វើឈ្លបខ្មែរក្រហម ក្នុងភូមិរបស់ខ្លួននៅភូមិព្រែកបាក់ ឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧០ តាមរយៈឈ្មោះ «ស» ជាប្រធានសង្កាត់ ។ ចំណុចនេះ ហាល់ម៉ាស់ ក៏បាននិយាយប្រាប់ដូចគ្នាដែរថា «ដំបូងបង្អស់នោះអត់មានធ្វើអីទេ យូរៗទៅគេចេះតែហៅទៅណោះ ហៅទៅណោះ ហើយបានប្រហែលជា៥-៦ខែ គេហៅទៅធ្វើឈ្លប» ។ ហាល់ម៉ាស់ បន្ថែម



ម៉ាន ហាល់ម៉ាស់ ត្រូវជាម្ដាយរបស់ ម៉ន

ទៀតថា «ដំបូងខ្ញុំនេះនិយាយប្រកែកនោះហើយ ប៉ុន្តែអានោះ (ម៉ន) វាប្ដេជ្ញាផ្ទាល់ខ្លួនវាទេ ហើយខ្ញុំជាម្ដាយចេះតែយំ ចេះតែស្រែកទៅ ខ្ញុំនិយាយថា កូនខ្ញុំមួយហ្នឹង ខ្ញុំមិនឲ្យវាទៅទេ តែឃាត់វា វាមិននៅ» ។ ហាល់ម៉ាស់ ក៏បានបន្តទៀតថា ក្រោយពីពេលនោះមកមិត្ត «ស» បានសុំយកកូនគាត់បញ្ជូនទៅកំពង់ចាម «ពេលគេ (កម្មាភិបាលខ្មែរក្រហម) មកប្រាប់ខ្ញុំថា កូនទៅនោះ (ទៅកំពង់ចាម) ខ្ញុំថាមិនឲ្យកូនខ្ញុំទៅទេ គេថាមិនឲ្យទៅយ៉ាងម៉េច បើកូនទៅបាត់ហើយ វាប្ដេជ្ញាខ្លួនវាហើយ» ។ ហាល់ម៉ាស់ បានសម្រក់ទឹកភ្នែករំឭកពីមូលហេតុចុងក្រោយនៃការព្រាត់ប្រាសពីកូន ។ ហាល់ម៉ាស់ មិនដែលបានទទួលដំណឹងអ្វីពីកូនបន្តិចសោះឡើយ ។

សា អ៊ីព្រហ៊ីម ជាអតីតយុទ្ធជនខ្មែរក្រហមតាំងពីឆ្នាំ១៩៧៣ រហូតដល់ឆ្នាំ១៩៨០ ហើយក៏ធ្លាប់ធ្វើជាកូនទាហានរបស់ ម៉ន ក្នុងអំឡុងឆ្នាំ១៩៧៣-៧៥ ។ គាត់បានឲ្យដឹងថា ម៉ន ក្លាហានណាស់ក្នុងការវាយប្រយុទ្ធជាមួយខ្មាំងរហូតដល់បានឡើងឋានៈជាអនុសេនាតូចគ្រប់គ្រងយុទ្ធជនជាង២០០នាក់ ។ អ៊ីព្រហ៊ីម និយាយថា «គាត់ (ម៉ន) ត្រូវរបួសជាមួយខ្ញុំ កាលណោះវ៉ៃនៅភូមិធំ ខាងកើតភ្នំប្រសិទ្ធិ គាត់ដាច់ដៃម្ខាង...ខែមិថុនា ឆ្នាំ១៩៧៥ គាត់ត្រូវបែកពីខ្ញុំ គាត់ធ្លាក់ខ្លួនពិការហើយអត់នៅក្នុងអង្គភាពពិការទេ ...គាត់របួសនៅភូមិធំ (ខាងលិចទីក្រុងភ្នំពេញ) មុនចូលភ្នំពេញពីរខែ» ។

ពាក់ព័ន្ធទៅនឹងការរងគ្រោះរហូតដល់ខ្លួនត្រូវពិការ ម៉ន ក៏បានឲ្យដឹងតាមចម្លើយសារភាពថា «ឆ្នាំ១៩៧៥ អង្គការដាក់ផែនការកម្ទេចខ្មាំង ក្រោយមកទៀតអង្គការឲ្យខ្ញុំទៅកម្ទេចខ្មាំងនៅភ្នំអង្គរស្ស អនុបញ្ជាការស្នងកងធំរបួស ស្នងកងក៏បានចាត់តាំងខ្ញុំជំនួស ដល់ក្រោយមកខ្ញុំក៏ត្រូវរបួស ។ រហូតដល់ថ្ងៃ១៧-មេសា (១៩៧៥) ខ្ញុំចេញពីមន្ទីរពេទ្យាបាលមកវិញ រួចហើយអង្គការបានចាត់តាំងជាប្រធានកងតូចដដែល ។ ដោយសារខ្ញុំពិការជើង ឈឺសួត និងពិការភ្នែក អង្គការក៏ដកខ្ញុំមកខាងយុវជនពិការនៅក្រសួងពាណិជ្ជកម្ម» ។

ពិនិត្យទៅលើឯកសារចម្លើយសារភាពរបស់ ម៉ន ទាំង ១៥៤ទំព័រ ពុំឃើញមានឈ្មោះអ្នកសួរនិងកាលបរិច្ឆេទទេ គ្រាន់តែឃើញនៅលើទំព័រខ្លះនៃឯកសារមាន «មន្ទីរស-២១ លេខ...» នៅត្រង់បន្ទាត់ដើមបង្អស់ក្នុងទំព័រនីមួយៗ ។ ទំព័រខ្លះមានអក្សរវាយដោយម៉ាស៊ីនអង្គុលីលេខនិងខ្លះទៀតអក្សរសរសេរដោយប៊ិកមាន៤ប្រភេទខុសៗគ្នា ដែលអាចសន្មតថា អាចមានមនុស្សបួននាក់ចារលើឯកសាររបស់ ម៉ន ។ នៅលើទំព័រដែលនិយាយអំពីខ្សែក្បត់មានចំណារជាច្រើនរបស់អ្នកពិនិត្យឯកសារ ។ ខ្ញុំសូមដកស្រង់ខ្លះៗនៅលើទំព័រដំបូងនៃចម្លើយសារភាពអំពីខ្សែរយៈក្បត់របស់ ម៉ន អ្នកពិនិត្យឯកសារបានសរសេរថា «ស.ម ហ៊ឺ ខំសួរឲ្យបានមួយចប់គ្រប់ៗគ្នាខ្សែអានេះ ដើម្បីងាយរកសួរទៀត តាមពិសោធន៍គឺអានេះឆ្លើយមិនទាន់អស់ នៅសារភាពបាន

មួយកម្រិតទៀត” “ស.ម ប៉េង ផ្ញើទៅជូនស.ម ហ៊ី ១៤៣” ។ នៅត្រង់បញ្ជីរាយឈ្មោះខ្មែរយៈក្សត់ អ្នកពិនិត្យឯកសារបានចារថា “ថ្ងៃក្រោយហាមមិនឲ្យសរសេរតែឈ្មោះទទេ ត្រូវមាននាមត្រកូល ឈ្មោះដើម+បដិវត្តន៍” និងចុងបញ្ចប់នៃចម្លើយអំពីខ្មែរយៈក្សត់មានអក្សរមួយឃ្លាសរសេរថា “សួរពីសកម្មភាពម្នាក់ៗឲ្យច្បាស់ទៀតតាមមើលអានេះនៅលាក់ច្រើនរឿងនិងសកម្មភាព” ។


សា អ៊ីព្រហ៊ីម

គ្មានសាក្សីណាម្នាក់ដែលខ្ញុំបានជួប ដឹងអំពីសកម្មភាពក្បត់របស់ ម៉ន នោះទេ។ អ៊ីព្រហ៊ីម ធ្លាប់ធ្វើយុទ្ធជនជាមួយគ្នាក៏ពុំបានឃើញថា ម៉ន ធ្វើអ្វីខុសដែរ ។ ផ្ទុយទៅវិញ អ៊ីព្រហ៊ីម ឃើញ ម៉ន មាន គោលជំហររឹងប៉ឹង និងក្លាហានក្នុងការប្រយុទ្ធនៅតាមសមរភូមិ ។ យោងតាមឯកសារចម្លើយសារភាព ម៉ន បានឆ្លើយសារភាពអំពីកំហុសដែលធ្លាប់មានកន្លងមកមានប្រាំមួយចំណុច ។ គឺទី១ “ខ្ញុំរួមប្រជុំជាមួយពួកអាក្បត់ ហើយខ្ញុំមិនរាយការណ៍ជូនអង្គការ” ។ ទី២គឺ “ខ្ញុំរើសបានអាវុធ ហើយខ្ញុំជូនឲ្យសមមិត្ត ពិន ហើយ ពិន មិនរាយការណ៍ជូនអង្គការ គឺគាត់យកទៅលាក់ខ្លួនឯង” ។ ទី៣ “ខ្ញុំឲ្យឈ្មោះ ព្រួញ ដេកនៅកន្លែងខ្ញុំកាលនោះគឺ ពិន យកទៅផ្ញើនៅកន្លែងខ្ញុំមួយយប់” ។ ទី៤ “ឈ្មោះពិន និងព្រួញ យកនិរសាររបស់ព្រួញទៅផ្ញើនៅកន្លែងខ្ញុំចំនួន ៤ថ្ងៃ កាលនោះខ្ញុំនៅឈឺ ក៏ខ្ញុំទទួលផ្ញើនៅកន្លែងខ្ញុំ អង្គការចាប់អារម្មណ៍ចំពោះខ្ញុំ” ។ ទី៥ “បញ្ហាខ្ញុំទៅដេកពេទ្យ កាលនោះឈ្មោះ ពិន ឲ្យឈ្មោះ ព្រួញ ជូនខ្ញុំទៅសម្រាកពេទ្យ ក៏ ព្រួញ សម្រាកជាមួយបានមួយយប់ ហើយអង្គការក៏ចាប់ឈ្មោះ ព្រួញ ហើយក្រោយមកអង្គការចាប់អារម្មណ៍ខ្ញុំដែរ ដែលទៅសម្រាកពេទ្យជាមួយឈ្មោះ ព្រួញ ចាប់អារម្មណ៍ខ្លាំងមែនទែនចំពោះខ្ញុំ” ។ ទី៦ “បញ្ហាខ្ញុំធ្វើប្រវត្តិរូបពីមុនខ្ញុំដាក់ស្នងការកងតូច ក្រោយមកគឺខ្ញុំធ្វើដាក់អនុបញ្ជាការស្នងកងធំ” ។ ម៉ន ក៏បានបន្តទៀតថា “ចំពោះសកម្មភាពដែលខុះខាតទាំងប៉ុន្មានគឺខ្ញុំស្មោះត្រង់ហើយ ហេតុដូច្នេះ គឺខ្ញុំសារភាពទាំងអស់ចំពោះការខុះខាតរបស់ខ្ញុំទាំងប៉ុន្មានមានខាងលើ ហើយបញ្ហាខុះខាតអ្វីទៀតដូចជាបំផុសបំផុលប្រក្បត់ធំៗគឺខ្ញុំគ្មានដែរ ។ ខ្ញុំសូមសម្តែងការស្មោះត្រង់ចំពោះបងទាំងអស់គឺអត់មានទេ មានតែប៉ុណ្ណឹងឯង” ។ ទាំងនេះគឺប្រហែលជាមូលហេតុនៃការចាប់ខ្លួន ម៉ន យកទៅឃុំឃាំងនៅមន្ទីរស-២១ និងចុងក្រោយ ត្រូវបានយកទៅសម្លាប់ចោលដោយគ្មានការវិនិច្ឆ័យទោសកំហុស ។ អ៊ីព្រហ៊ីម ក៏បានដឹងអំពីការចាប់ខ្លួនរបស់ ម៉ន ដែរ “គាត់ (ម៉ន) មកមន្ទីរពេទ្យ មកលេងជាមួយខ្ញុំ ពេលនោះខ្ញុំទៅដេកពេទ្យនៅមន្ទីរពេទ្យកេតុមាលា ។ ហើយពេលខ្ញុំត្រឡប់ទៅវិញគេប្រាប់ខ្ញុំថាគេចាប់ ម៉ន បាត់ទៅហើយ...គេចាប់ ម៉ន យកទៅដាក់នៅមន្ទីរស-២១” ។

ម៉ន បានចូលបម្រើបដិវត្តន៍របស់ខ្មែរក្រហម នៅឆ្នាំ១៩៧០ នៅភូមិកំណើតគឺភូមិព្រែកបាក់ ឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ដល់ឆ្នាំ១៩៧៣ ម៉ន បានទទួលឋានៈជាអនុក្រុមនៅកងវរសេនាតូចលេខ៤០៨ តំបន់៣១ ។ នាពាក់កណ្តាល ឆ្នាំ១៩៧៤ ម៉នបានឡើងឋានៈជាស្នងការអនុសេនាតូចទី៣ អនុសេនាធំលេខ៣ វរៈ៧៣៦ ក្នុងកងពលទី២ ភូមិភាគឧត្តរ ។ ឆ្នាំ១៩៧៥ ម៉ន ត្រូវរបួសពិការនៅសមរភូមិភ្នំប្រសិទ្ធិ ។ ពេលចេញពីមន្ទីរព្យាបាលមកវិញ អង្គការចាត់តាំង ម៉ន ឲ្យនៅពាណិជ្ជកម្មរដ្ឋផ្សារថ្មី (ភ្នំពេញ) រហូតបានឡើងឋានៈជាប្រធានក្រុមទី៣ ក្នុងសមាជិកកងអនុសេនាតូចទី១ ។ លុះដល់ខែតុលា ឆ្នាំ១៩៧៥ អង្គការចាប់ខ្លួន ម៉ន ។

ម៉ន មានឈ្មោះដើម ម៉ាត់ អាយុ២៦ឆ្នាំ (១៩៧៥) ជាកូនគ្រួសារក្រីក្រមួយរស់នៅភូមិ ព្រែកបាក់ ឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ទូល័ស និងម្តាយឈ្មោះ ហាល់ម៉ាស់ ឪពុកស្លាប់ចោលតាំងពី ម៉ន នៅអាយុ៤ឆ្នាំ ។ ម៉ាន បន្តជីវិតកុមារភាពដ៏កម្សត់របស់ខ្លួនដល់អាយុ២១ឆ្នាំ ទើបព្រាត់ប្រាសពីម្តាយរហូតមកដល់សព្វថ្ងៃនេះ ។ ម្តាយ ម៉ន ពេលនេះស្ថិតក្នុងវ័យជរា ហើយពេលចុងក្រោយនៃការសម្ភាសជាមួយខ្ញុំ គាត់បានទាមទារសុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យកូនប្រុសគាត់ផង ។

**អ៊ីសា ឧស្មាន**

**(តពីលេខមុន)** ការបោសសម្អាតក៏បានបង្ហាញអំពីយុទ្ធនាការប្រឆាំងនឹងអ្នកចេះដឹងនៅក្នុងជួរបក្សដែលមានកម្លាំងខ្លាំងនៅពាក់កណ្ដាលឆ្នាំ១៩៧៧ ។ នៅក្នុងខែកុម្ភៈ បញ្ញវន្តពីររូបគឺលោក កុយ ធួន និង តូច ភឿន ត្រូវបាននាំយកមកដាក់នៅមន្ទីរស-២១ ។ ជាសមាជិកគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តទាំងពីររូបគឺជាកម្មាភិបាលជំបូងក្នុងជួរកំណើតនេះដែលត្រូវបានបោសសម្អាត ។ មុខសញ្ញាសន្តិបាលបន្ទាប់គឺកម្មាភិបាលយោធានិងកម្មាភិបាលស៊ីវិលធ្វើការនៅភូមិភាគឧត្តរជាកន្លែងដែល កុយ ធួន ធ្វើជាលេខារហូតដល់ដើមឆ្នាំ១៩៧៦ ព្រមទាំងអ្នកចេះដឹងដទៃទៀតនៅក្នុងបក្សកុម្មុយនិស្តកម្ពុជាដែលជាប់ពាក់ព័ន្ធជាមួយនឹងអ្នកទោសទាំងពីរនាក់នេះ ។ នៅក្នុងអត្ថន័យ "ដែនការចុងក្រោយ" បុគ្គលដែលជាមុខសញ្ញាទាំងអស់នេះគឺជា "អ្នកដែលបន្ទំខ្លួនជ្រៀតចូលនៅក្នុងបដិវត្តន៍និងពង្រីកខ្លួនដើម្បីស៊ីបការណ៍" ។




**សម្លេងពីមន្ទីរ ស-២១**
**ខគ្គទី៣: ការជ្រើសរើសសត្រូវ**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

កុយ ធួន កើតនៅក្នុងឆ្នាំ១៩៣៣ ហើយចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិនៅក្នុងឆ្នាំ១៩៤៩ ។ ក្រោយពីបញ្ចប់ការសិក្សា កុយ ធួន បានចាប់យកអាជីពជាគ្រូបង្រៀន ។ នៅឆ្នាំ១៩៥៩ ឬ ឆ្នាំ១៩៦០ ដោយមានការបញ្ចុះបញ្ចូលពីសំណាក់ ទីវ អុល ដែលធ្វើគ្រូបង្រៀនជាមួយគ្នា មានទំនាក់ទំនងដូចជាបងប្អូន កុយ ធួន ក៏ជឿស្ងប់ទៅលើមនោគមវិជ្ជាបដិវត្ត ។ ដោយមានការធានាពីគ្រូបង្រៀនម្នាក់ទៀតឈ្មោះ សុន សេន ពេលនោះ កុយ ធួន ក៏បានចូលជាសមាជិកបក្សកុម្មុយនិស្តកម្ពុជា ។ នៅក្នុងឆ្នាំ១៩៦០ កុយ ធួន ធ្វើការជាមួយ ខៀវ សំផន មួយរយៈខ្លីនៅសារព័ត៌មានប្រចាំសប្តាហ៍ ឈ្មោះ "អ៊ុបសែរវ៉ាទ័រ" ។ កុយ ធួន បានរត់ចូលព្រៃម៉ាកគីស ក្រោយពីបង្រៀនសិស្សអស់មួយរយៈនៅក្នុងខេត្តកំពង់ចាម ដែលនៅទីនោះគាត់បានកសាងកម្លាំងមួយចំនួនដូចជា សួស វ៉ាស៊ី ហៅ ឌឿន និងអ្នកផ្សេងៗទៀតចូលក្នុងបក្ស ។ នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល កុយ ធួន ជាជនសកម្មនៅក្នុងភូមិភាគឧត្តរដែលនៅទីនោះគាត់បានទទួលកេរ្តិ៍ឈ្មោះជាអ្នកមានស្រីច្រើននិងជាអ្នករស់នៅស្អាតស្អំ ។ នៅក្នុងអត្ថន័យ "ដែនការចុងក្រោយ" ក្រុមដែលនៅកៀកៗនឹង កុយ ធួន បានបង្កើតបរិយាកាសសន្តិភាពនិយមហ៊ឺហា សប្បាយ និងយកសិល្បៈនិងយកស្ត្រីជាការសប្បាយ...បង្កជាមុខមាត់បុណ្យស័ក្តិ និងមានទំនាក់ទំនងជាមួយខ្មាំង" ។

ចម្លើយសារភាពយ៉ាងលម្អិតក្បោះក្បាយនិងមានរបៀបរៀបរយរបស់ កុយ ធួន បានឆ្លើយដាក់មនុស្សផ្សេងទៀតជាច្រើនរយនាក់ ។ បុគ្គលទាំងនេះរួមបញ្ចូលទាំងមន្ត្រីជាន់ខ្ពស់របស់បក្សកម្មាភិបាលយោធានិងស៊ីវិលដែលធ្លាប់ធ្វើការជាមួយគាត់នៅក្នុងភូមិភាគឧត្តរព្រមទាំងបក្ខពួកដែលធ្វើការជាមួយគ្នានៅគណៈពាណិជ្ជកម្ម ។ ចម្លើយសារភាពរបស់ កុយ ធួន ក៏មានពាក់ព័ន្ធដល់ក្រុមគ្រូបង្រៀនមួយក្រុមដូចជារដ្ឋមន្ត្រីក្រសួងព័ត៌មាន ឈ្មោះ ហ៊ូ នឹម គណៈមន្ទីរ៨៧០ ឈ្មោះ សួស វ៉ាស៊ី, ភោគ ឆាយ អតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឈ្មោះ ហ៊ូ យន់ (បោសសម្អាតនៅក្នុងឆ្នាំ១៩៧៥) និងអ្នកណែនាំ កុយ ធួន ឲ្យចូលបក្សឈ្មោះ ទីវ អុល ដែលធ្វើការជាមួយ ហ៊ូ នឹម នៅក្នុងឆ្នាំ១៩៧៧ ។ កុយ ធួន ក៏បាននិយាយពាក់ព័ន្ធដល់ប្រពន្ធរបស់ ទីវ អុល ឈ្មោះ ឡេង ស៊ីមហាក់ ដែរ ប៉ុន្តែ ស៊ីមហាក់ មិនទាន់ត្រូវបានចាប់ខ្លួននៅឡើយទេ នៅក្នុងរយៈពេល៦ខែបន្ទាប់ពីការចាប់ខ្លួនប្តីរបស់នាង ។ នៅចុងបញ្ចប់នៃចម្លើយសារភាពមានរាយឈ្មោះ "កម្លាំងក្បត់" នៅក្នុងភូមិភាគឧត្តរ ពាយ័ព្យ ផែកំពង់សោម និងនៅភ្នំពេញ ។

នៅក្នុងចម្លើយសារភាព កុយ ធួន ត្រូវបានបង្ខំឲ្យនិយាយ

បន្ទាប់អាជីពរបស់ខ្លួន ហើយបកអាក្រាតអ្នកដែលធ្លាប់ធ្វើការជាមួយគ្នា លើកលែងតែអ្នកដែលធ្វើការនៅមជ្ឈិមបក្ស ។ មិត្តភក្តិជាច្រើននាក់ទៀតក៏ក្លាយជាមុខសញ្ញាថ្មីរបស់បក្សដែរ ។ ការបោសសម្អាតបក្ខពួករបស់ កុយ ធួន បានចាប់ផ្តើមក្រោយការចាប់ខ្លួន កុយ ធួន តែបន្តិចប៉ុណ្ណោះ ។ ក្រោយពីមានការបញ្ចេញយោបល់របស់អ្នកស្រី ឡូរ៉ា សាំម័រ លោក ស្ទីវ ហេឌ័រ បានហៅមិត្តភក្តិរបស់ កុយ ធួន ទាំងអស់ថាជា "សកម្មជនប្រជាធិបតេយ្យ" ហើយចាត់ទុកថាជា "អតីតអនុធនថ្នាក់ក្រោម" ដែលទាក់ទងជាមួយនឹង សុន សេន ដោយផ្ទាល់ឬតាមរយៈ កុយ ធួន ។ លោក ហេឌ័រ រកឃើញលក្ខណៈប្រឆាំងមានចរិតដូចៗគ្នាចំពោះនយោបាយរបស់ ប៉ុល ពត នៅក្នុងសម័យខ្មែរក្រហម ក្នុងចំណោមក្រុមរបស់ កុយ ធួន ដែលលើកឡើងខាងលើ ។

ការឃុំខ្លួន កុយ ធួន បានធ្វើឡើងស្របជាមួយនឹងការងើបបះបោរដ៏ខ្លាំងក្លាប្រឆាំងនឹងរបបដែលដួលរលំនៅជីក្រែង ជិតខេត្តសៀមរាបនៅក្នុងខែមីនា ។ ជនភៀសខ្លួនដែលបានរត់ទៅប្រទេសថៃ ក្រោយមកបានរាយការណ៍ថាមានការបះបោរនៅគ្រប់ទីកន្លែងក្នុងភូមិភាគឧត្តរនិងការផ្លាស់ប្តូរកម្មាភិបាលថ្នាក់មូលដ្ឋាន ហើយជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតី ។ ជនសង្ស័យនៅភូមិភាគឧត្តរ និងកងកម្លាំងយោធានៅក្នុងតំបន់មានជាអាទិ៍ដូចជាកងពលធំ៣១០និងកងពល៤៥០ ត្រូវបានបោសសម្អាតស្ទើរគ្មានសល់ ។ បណ្ណសារនៅមន្ទីរស-២១មានផ្ទុកនូវចម្លើយសារភាពជាងបីរយរបស់បុគ្គលនៅក្នុងអង្គភាពទាំងពីរនេះ ហើយឯកសារចំនួន១១៧៨សន្លឹកមានលាយឡំជាមួយនឹងឯកសារទាក់ទងនឹងទាហាននៅក្នុងកងពលធំ៣១០ ដែលមានលើកឡើងនៅគ្រប់ចម្លើយសារភាព ។ គ្រាន់តែនៅក្នុងខែមីនា ឆ្នាំ១៩៧៧ប៉ុណ្ណោះ មានមនុស្សចំនួនប្រមាណ១០៥៩នាក់បានមកដល់មន្ទីរស-២១ ។ បុគ្គលភាគច្រើនលើសលប់នៃចំនួននេះគឺសុទ្ធតែមានទំនាក់ទំនងជាមួយនឹងភូមិភាគឧត្តរ ។

នៅក្នុងការសួរចម្លើយ កុយ ធួន អ្នកសួរចម្លើយបានរិះរកវិធីបង្កើតទំនាក់ទំនងជាច្រើនជាមួយនឹងមនុស្សដែលត្រូវបានបោសសម្អាតរួចហើយ ។ អ្នកទោសឈ្មោះ កុយ ធួន បានសារភាពថាបានជួបជាមួយភ្នាក់ងារសេ.អ៊ី.អា របស់អាមេរិកដែលប្រកាសខ្លួនថាជា "ហ៊ីឃ្វី" និង "ស៊ីរូទី" បានជួបជាមួយ "ភ្នាក់ងារ" វៀតណាមនិងបក្ខពួកជនជាតិខ្មែរមិនមែនកុម្មុយនិស្តតាំងពីទសវត្សរ៍ឆ្នាំ១៩៦០ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ។

កុយ ធួន ធ្វើឲ្យអ្នកសួរចម្លើយពិបាកស្តាប់និងចាប់បាននូវអ្វីដែលគាត់និយាយណាស់ ។ នៅថ្ងៃទី២ ខែមីនា ឌុច បានសរសេរសំបុត្រមួយមកគំរាម កុយ ធួន ។ នៅចុងបញ្ចប់ ឌុចសរសេរថា *"ហេតុអ្វីបានជាឯងមានជំនឿខ្លាំងក្លាដល់ម្ល៉ឹង? ពួក សេ.អ៊ី.អា វៀតណាមនិងខ្មែរសេរី សុទ្ធតែមានក្លិនអសោចអស់ហើយ ហើយកម្លាំងរបស់វាត្រូវបានធ្វើឲ្យបែកខ្ញែកដោយសារការវាយប្រហារមួយដែលឯងមិនដែលនឹកស្មានដល់ ។ ចំពោះបញ្ហានេះឯងមិនទាន់បានរាយការណ៍ឲ្យបានត្រឹមត្រូវនៅឡើយទេ ។ នេះជាបញ្ហាដែលឯងកំពុងតែគេច"* ។

ពីរថ្ងៃក្រោយមក កុយ ធួន បានសរសេរចម្លើយដោយគ្មានមូលដ្ឋានច្បាស់លាស់មួយដើម្បីឆ្លើយតបទៅនឹងការទាមទារនេះ ។ មួយខែក្រោយមកគឺមុនពេលគាត់ត្រូវបានយកទៅសម្លាប់ កុយ ធួន បានរៀបរាប់ឈ្មោះមនុស្សរាប់រយនាក់ ព្រមទាំងលម្អិតសកម្មភាព



កុយ ធួន

ក្បត់របស់គាត់ផ្ទាល់និងរបស់អ្នកដទៃទៀតយ៉ាងល្អិតល្អន់ ។

ចម្លើយសារភាពរបស់ កុយ ធួន ជាកញ្ចក់ឆ្លុះបញ្ចាំង អំពីដំណើររឿងផ្លូវការរបស់បក្ស ។ នៅគ្រប់ចំណុចទាំងអស់ដូចជា "គម្រោងការ" គ្មានបានការក្នុងការធ្វើឃាត ប៉ុល ពត "ប្រមូលកម្លាំង" បង្កើតបក្សប្រឆាំង ប្រមូលជំនួយ និងការគាំទ្រពីប្រទេសថៃ អាមេរិកកាំង និងវៀតណាម ប្រមូលកម្លាំងទ័ពរបស់ខ្លួននិង "បង្កឲ្យមានភាពច្របូកច្របល់" ដោយបើកឲ្យមានឡើងវិញនូវកម្មសិទ្ធិបុគ្គល គឺគ្មានន័យអ្វីទាំងអស់ ។ "សកម្មភាពក្បត់" របស់ កុយ ធួន ដែលអាចមានលក្ខណៈគ្រប់គ្រាន់ធ្វើឲ្យប៉ះពាល់និងកម្ទេចរបបកាន់អំណាច មិនមានឥទ្ធិពលទៅលើកម្ពុជាប្រជាធិបតេយ្យឡើយ ។ ប៉ុន្តែផ្ទុយមកវិញ ភាពគ្មានអំណាចនិងចម្លើយសារភាពគ្មានមូលដ្ឋានច្បាស់លាស់របស់ កុយ ធួន អាចផ្តល់ជាភ័ស្តុតាងថែមទៀតដែលបង្ហាញឲ្យឃើញប្រផ្នូលនៅថ្ងៃអនាគតរបស់បក្ស ។

ដោយមានអត្ថន័យដូចអត្ថបទនៅក្នុងឯកសារទង់បដិវត្តន៍ វគ្គសិក្សានៅមន្ទីរស-២១ នៅពេលនេះអាចទាញសេចក្តីសន្និដ្ឋានថាការចាប់ខ្លួន កុយ ធួន និងទិន្នន័យនៅក្នុងចម្លើយសារភាពរបស់គាត់បានកាត់បន្ថយភាពតានតឹងនៅក្នុងប្រទេសយ៉ាងច្រើន ។ អ្នកសួរចម្លើយថ្នាក់លើម្នាក់ឈ្មោះ ទុយ បានសរសេរថា "នៅក្នុងតំបន់ឧត្តរចាស់ មុនពេលដែលបញ្ហា "ខ្សែ" និង "បណ្តាញ" របស់ កុយ ធួន ត្រូវបានដោះស្រាយរួច មានបញ្ហាកើតឡើងជាច្រើនទាក់ទងនឹងការការពារកសាងនិងបញ្ហាផ្សេងៗដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន ។ ក្រោយពី "ខ្សែ" អាកុយ ធួន ចេញមុខច្បាស់ (ចលនាបដិវត្តន៍) អាចឈានទៅមុខគ្រប់វិស័យ" ។

ពីរសប្តាហ៍ក្រោយពីការចាប់ខ្លួនរបស់ កុយ ធួន ឈ្មោះ ខឿន ត្រូវបាននាំយកមកដាក់នៅមន្ទីរស-២១ ។ ខឿន បានធ្លាប់ធ្វើការយ៉ាងជិតស្និទ្ធជាមួយ ធួន នៅក្នុងអំឡុងសង្គ្រាម ស៊ីវិលនិងបានជំនួស កុយ ធួន ធ្វើជាលេខាផ្នែកពាណិជ្ជកម្មយ៉ាងឆាប់រហ័ស ។ នៅឆ្នាំ១៩៧៥ ខឿន បានក្លាយជាប្រធានរដ្ឋបាលនៃមន្ទីរ-៨៧០របស់គណៈមជ្ឈិម ។ នៅក្នុងចន្លោះឆ្នាំ១៩៧៦-៧៧ ខឿន បានជួបជាមួយនឹង កុយ ធួន ជាញឹកញាប់ដើម្បីពិភាក្សាកិច្ចការក្រសួងពាណិជ្ជកម្ម ។ រាល់ជំនួបជាមួយ កុយ ធួន សុទ្ធតែមានការអនុញ្ញាតពីថ្នាក់លើជាមុន ប៉ុន្តែនៅពេល ខឿន ត្រូវបានចាប់ខ្លួន រាល់កិច្ចជួបពិភាក្សាទាំងអស់កើតមានតែម្តងម្កាលនិងក្នុងលក្ខណៈជាការឃុបឃិតប៉ុណ្ណោះ ។ ក្នុងខណៈដែល "ទោសកំហុស" របស់បុគ្គលទាំងពីរនាក់អាចបណ្តាលមកពីការសង្ស័យរបស់មជ្ឈិមបក្ស លទ្ធភាពនៃការឃុបឃិតច្បាស់លាស់រវាងមិត្តចាស់ពីរនាក់នេះ ដែលម្នាក់ជាអ្នកមានភក្តីភាពជាមួយនឹងមជ្ឈិមបក្ស និងម្នាក់ទៀតជាអ្នករក្សាការពង្រីក "បណ្តាញ" របស់ខ្លួននៅតាមជនបទ មិនអាចគិតថាមិនសំខាន់នោះទេ ។

ដោយនឹករកអ្វីដែលជាបទល្មើសរបស់ខ្លួន ខឿន បាននិយាយថា ខ្លួនបានរត់ចោលជួរពេលប្រយុទ្ធនៅក្នុងសង្គ្រាមស៊ីវិល បំផុសឲ្យកូនចៅឲ្យ "បាត់បង់ជំនឿទៅលើបដិវត្តន៍" និងដាំដំណាំដោយគ្មានការអនុញ្ញាត ។ ខឿន បានបន្តសារភាពថាបានទាក់ទងយ៉ាងសកម្មជាមួយនឹងកម្មាភិបាលជាច្រើននៅសម័យសង្គ្រាម (ស៊ីវិល) និងប៉ុនប៉ងប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងចំណោមអ្នកទោសដែលត្រូវបានចាប់ខ្លួនមកដល់ពេលនេះលើកលែងតែ ណៃ សារ៉ន ឈ្មោះ ខឿន គឺជាអ្នកធ្វើការនៅកៀកនឹងមជ្ឈិមបក្សជាងគេបង្អស់ ហើយគាត់ត្រូវ



តូច ភឿន

បានដឹងថាមានតួនាទីសំខាន់នៅពេលដែលតួនាទីនេះត្រូវបានចូលមកជំនួសដោយ ខៀវ សំផន ដែលជាប្រធានរដ្ឋមានតែឈ្មោះរបស់កម្ពុជាប្រជាធិបតេយ្យ ។ វាអាចជាការពិតដូចដែលលោក ស៊ីវ ហេង៉ រ បានទាញហេតុផលថា ខៀវ សំផន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការទម្លាក់ ឡឿន ចេញពីតំណែង ។ ខៀវ សំផន ជាអ្នកបានទទួលផលប្រយោជន៍ច្រើនជាងគេ ។ ចម្លើយសារភាពរបស់ កុយ ធួន ក៏និយាយពាក់ព័ន្ធដល់ ហ៊ូ នឹម ហៅ ភាស់ ដែលជារដ្ឋមន្ត្រីក្រសួងពត៌មាននិងឃោសនាការ និងជាជំនួយការរបស់ ខៀវ សំផន ជាយូរណាស់មកហើយដែរ ។ ហ៊ូ នឹម ត្រូវបានចាប់ខ្លួននៅក្នុងខែមេសា ឆ្នាំ១៩៧៧ ។ ហ៊ូ នឹម ជាកូនកសិករក្រខ្សត់ កើតនៅឆ្នាំ១៩៣០ក្នុងខេត្តកំពង់ចាម ។ គាត់រៀនជាមួយ ខៀវ សំផន (មិនបានរៀនជាមួយសាឡុត ស ទេ) នៅក្នុងខេត្តកំពង់ចាម ។ ហ៊ូ នឹម ទៅសិក្សានៅប្រទេសបារាំងចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៥៧ នៅពេលដែល ខៀវ សំផន កំពុងស្ថិតនៅប្រទេសបារាំង មុនពេលមកកាន់តំណែងក្នុងជួររដ្ឋាភិបាលនៅទីក្រុងភ្នំពេញ ។ ហ៊ូ នឹម បានបម្រើការនៅក្នុងសភាជាតិរបស់របប សីហនុ ជាមួយនឹង ខៀវ សំផន និង ហ៊ូ យន់ រហូតដល់ថ្ងៃមួយដែលសម្តេចមានព្រះទ័យក្រេវក្រោធចំពោះការនិយាយចេញមុខគាំទ្រគំនិតរបស់ចិន ។ ដោយសារមានការគំរាមចាប់ខ្លួននៅក្នុងឆ្នាំ១៩៦៧ ហ៊ូ នឹម បានរត់គៀសខ្លួនចេញពីទីក្រុង ។ ពេលនោះ ហ៊ូ យន់ និង ខៀវ សំផន ក៏រត់ទៅបន្តបន្ទាប់គ្នា ។ អស់រយៈពេលជាច្រើនឆ្នាំមិនមានលេចឮដំណឹងពីបុគ្គលទាំងបីរូបនេះឡើយ ។ អ្នកគាំទ្ររបស់អ្នកទាំងបីនឹកស្មានថាមេដឹកនាំរបស់ខ្លួនស្លាប់បាត់ទៅហើយ ។ ចាប់ពីពេលនោះមក អ្នកទាំងបីត្រូវបានហៅថា «ខ្មោចទាំងបី» ។

ក្រោយរដ្ឋប្រហារខែមីនា ឆ្នាំ១៩៧០ភ្លាម ខ្មោចទាំងបីបានលេចមុខជាថ្មីតាមរយៈរលកធាតុអាកាសវិទ្យុអំពាវនាវកៀងគរប្រជាជនឲ្យក្រោកឡើងតស៊ូ ។ នៅក្នុងអំឡុងពេល



សង្គ្រាមស៊ីវិលអ្នកទាំងបីបានកាន់កាប់មុខតំណែងក្នុង "គណៈរដ្ឋមន្ត្រី" នៅក្នុងរដ្ឋាភិបាលរណសិរ្សរួបរួមជាតិដោយបង្កើតឡើងនូវទម្រង់ដឹកនាំក្លែងក្លាយមួយដែលទាត់ចោលអ្នកកាន់អំណាចពិតប្រាកដនៅក្នុងមជ្ឈិមបក្ស ។

ហ៊ូ នឹម គឺជាអ្នកបដិវត្តដាច់ខាតមួយរូប ។ សូម្បីតែមកដល់មន្ទីរស-២១ហើយក៏ដោយ ក៏គាត់នៅតែរៀបចំខ្លួនដើម្បីទទួលយកនូវបញ្ញារបស់បក្សដែរ ។ នៅក្នុងសំណេរផ្ទាល់ដៃរបស់គាត់ ហ៊ូ នឹម បានរៀបរាប់អំពីសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ប៉ុន្តែដោយសារអាជីពជាអ្នកបដិវត្តរបស់គាត់ត្រូវបានលេចឮសុសសាយពេក ភាគច្រើននៃសកម្មភាពក្បត់របស់គាត់ដែលត្រូវចោទឡើង ត្រូវក្លាយជាកត្តាអត្តនោម័តិនិងមានចរិតគហបតី ។

អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ជាតិហុល្លង់ម្នាក់ ឈ្មោះលោក ប៊ែរ ឃ្វ័រ បានអះអាងថា នៅក្នុងចម្លើយសារភាពរបស់ ហ៊ូ នឹម មានការបង្កើបថាគាត់មានការជំទាស់ខ្វះចំពោះនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ហើយបានដឹងការជំទាស់ពីមនុស្សដទៃទៀត ។ យោងតាមសម្តីរបស់ ប៉ែន យៀនិន បានឲ្យដឹងថា ហ៊ូ នឹម បានស្នើឲ្យប្រើរូបិយប័ណ្ណឡើងវិញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងចម្លើយសារភាពរបស់ខ្លួន ហ៊ូ នឹម និយាយថា រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យបានរិះគន់នយោបាយ "ម្ចាស់ការដោយប្រើកម្លាំងពលកម្មជាមូលដ្ឋាននិងប្រើគ្រឿងចក្រជាទ្រង់ទ្រាយតូច" របស់មជ្ឈិមបក្ស ។ ហ៊ូ នឹម និយាយថា សោ ភឹម ក៏មានទស្សនៈប្រឆាំងប្រហាក់ប្រហែលគ្នានេះដែរ ។ រស់ ញឹម បានរិះគន់ថាការតស៊ូប្រដាប់អាវុធនៅក្នុងភូមិភាគពាយ័ព្យក្នុងទសវត្សរ៍ឆ្នាំ៦០ ដែលចាប់ផ្តើមឡើងដោយមានការបះបោរដោយឯកឯងជាទ្រង់ទ្រាយតូចនៅសំឡូតនៅក្នុងឆ្នាំ១៩៦៧ ដែលត្រូវបានវាយបង្ក្រាបយ៉ាងឃោរឃៅ មិនត្រូវបានកត់ចូលនៅក្នុងប្រវត្តិរបស់បក្សឡើយ ។

ចម្លើយសារភាពរបស់ ហ៊ូ នឹម បានបង្ហាញអំពីការចាប់ខ្លួនដែលរាលដាលយ៉ាងរហ័សទៅដល់ភូមិភាគពាយ័ព្យ ។ តាមពិតការបោសសម្អាតគឺបណ្តាលមកពីវិបត្តិខ្វះស្បៀងអាហារដែលយាយីមកលើភូមិភាគពាយ័ព្យជាកន្លែងដែលមានប្រជាជនជម្លៀសមកថ្មីៗពីទីក្រុងនានា រាប់ពាន់នាក់ត្រូវស្លាប់ដោយការខ្វះជីវជាតិអាហារគ្រប់គ្រាន់និងការធ្វើការបាក់កម្លាំង និងជាកន្លែងដែលមានការចែករបបអង្ករនិងធញ្ញជាតិមិនគ្រប់គ្រាន់តាមការកំណត់ និងផែនការបួនឆ្នាំរបស់បក្ស ។ ហេតុនេះហើយបានជាបណ្តាលឲ្យមានគ្រោះទុរ្ភិក្សកើតឡើង ។

ការបោសសម្អាតបានក្លាយទៅជាករណី "ស៊ាស៊ីបាយរួចលាបមាត់ពពែ" របស់បក្ស ដែលកម្មវិធីរបស់ខ្លួនមិនអាចទទួលបានជោគជ័យឡើយប្រសិនបើមានអ្នកខ្វះអនុវត្តតាមផ្លូវផ្សេងនោះ ។ តាមរយៈសម្តីរបស់ រស់ ញឹម ដែលដកស្រង់ចេញពីចម្លើយសារភាពរបស់ ហ៊ូ នឹម បានបញ្ជាក់ថា "នៅឆ្នាំ១៩៧៦ បក្សបានចាត់តាំងឲ្យយើងសម្រេចផែនការបង្កបង្កើនផលស្រូវក្នុងមួយហិកតាឲ្យបានបីតោន...ចំពោះភូមិភាគពាយ័ព្យវិញ... បក្សបានចាត់តាំងឲ្យសម្រេចបានបួនតោនក្នុងមួយហិកតា...តើទៅម៉េចរួចបើមិនដោះស្រាយបញ្ហាម៉ាស៊ីននោះ? យើងធ្វើមិនបានទេ ។ នេះមិនមែនជាកំហុសរបស់ខ្ញុំទេ វាជាកំហុសរបស់គណៈកម្មាធិការអចិន្ត្រៃយ៍" ។

ដើម្បីឲ្យ ហ៊ូ នឹម អាចសរសេរប្រយោគចុងក្រោយនៅក្នុងចម្លើយសារភាពរបស់ខ្លួន ទោះជាមានការទម្លាក់កំហុសទៅលើអ្នកដទៃក៏ដោយ គឺវាត្រូវការសេចក្តីក្លាហានមិនធម្មតាមួយ ។ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៧ ហ៊ូ នឹម បានសរសេរនៅក្នុងចម្លើយសារភាពជាលើកចុងក្រោយរបស់គាត់ថា "អស់រយៈពេលជាង២៥ឆ្នាំហើយដែលខ្ញុំបានបន្ទាបខ្លួនបម្រើសកម្មភាពខ្លាំង ។ ទម្លាប់ កម្មសិទ្ធិ ទ្រព្យសម្បត្តិឯកជនដែលត្រូវបានបំពាក់មកលើខ្ញុំដោយវណ្ណៈសក្តិភូមិនាយទុន និងពួកចក្រពត្តិបានគ្របសង្កត់និងបង្ខំខ្ញុំឲ្យក្លាយជាភ្នាក់ងារខ្មាំង ។ ខ្ញុំបានបម្រើ...ភ្នាក់ងារសេ.អ៊ី.អានិងចក្រពត្តិអាមេរិកដែលមកដល់ឥឡូវនេះត្រូវបានវាយឲ្យបរាជ័យយ៉ាងអាម៉ាស់ និងបានទទួលវាសនាដូចសព្វថ្ងៃនេះ ។ ខ្ញុំបានទទួលការអប់រំពីបក្សអស់រយៈពេលមួយខែកន្លះកន្លងទៅហើយ ។ ខ្ញុំគ្មានអ្វីពឹងពាក់ទេ មានតែបក្សកុម្មុយនិស្តកម្ពុជាតែមួយគត់ ។ សូមបក្សមេត្តាទុកជីវិតឲ្យខ្ញុំផង ។ ជីវិតខ្ញុំគឺអាស្រ័យលើបក្សទាំងស្រុង" ។

**(នៅមានត)**

# ជនដៃដល់ ឬ ជនរងគ្រោះ?

## កសិណរបស់យុទ្ធជនវ័យក្មេងនៃមន្ទីរស-២១



ដោយៈ អៀ ម៉េងទ្រី

**(តពីលេខមុន)** អ្នកឯកទេសខាងបញ្ហាខួរក្បាលធ្វើការសន្និដ្ឋានថា ការចាប់ខ្លួនឃុំឃាំងក្នុងជំរំកែប្រែក៏ដូចជាកន្លែងផ្សេងទៀតគឺ បណ្តាលឲ្យបញ្ហាផ្លូវចិត្តកើតមានឡើង ។ បញ្ហានេះកើតឡើងហើយជួនកាលអូសបន្លាយរយៈពេលយូររហូតមិនអាចព្យាបាលបានតាមវិធីដែលក្រុមអ្នកឯកទេសធ្លាប់ធ្វើកន្លងមកជាពិសេសចំពោះប្រជាជននៅអាស៊ីដែលរួមមានទាំងប្រជាជនកម្ពុជាដែរ ។ យោងតាមលទ្ធផលនៃការសិក្សាដែលបានបង្ហាញថាបញ្ហាប្រភេទនេះកើតមានឡើងចំពោះជនដៃដល់ ដូច្នេះជនដៃដល់ទាំងនោះក៏ជាជនរងគ្រោះដែរ ពិសេសជនដៃដល់ដែលមានវ័យក្មេង ។ បន្ទាប់ពីនេះយើងក្រឡេកមើលអំពីមូលហេតុដែលនាំឲ្យអតីតយុទ្ធជនវ័យក្មេងមន្ទីរស-២១ក្លាយខ្លួនជាជនរងគ្រោះដែលបណ្តាលមកពីការចូលរួមក្នុងចលនាបម្រើបដិវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យវិញម្តងថាតើមានលក្ខណៈបែបណា ។

អ្នកនិពន្ធ និងអ្នកប្រវត្តិសាស្ត្រជាច្រើនបានធ្វើការសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសិក្សាបង្ហាញថា ខ្មែរក្រហមមានចេតនាប្រើប្រាស់និងបានរំលោភធ្វើបាបយុទ្ធជនវ័យក្មេងក្នុងអំឡុងពេលដែលយុទ្ធជនទាំងនោះស្ថិតក្នុងចលនាបម្រើបដិវត្តន៍តាមការទាមទាររបស់ខ្មែរក្រហម ។ ដូចដែលលោក ហង់រី ឡូកា ដកស្រង់សម្តីរបស់មេដឹកនាំទីមួយ ប៉ុល ពត អំពីចេតនាប្រើប្រាស់យុទ្ធជនវ័យក្មេងក្នុងចលនាបម្រើបដិវត្តមួយឃ្លាថា «ការកសាងសង្គមថ្មីត្រូវការមនុស្សថ្មី» ។ ប្រវត្តិវិទូ ប៉ែន យៀនិន សង្កេតឃើញថា “យុទ្ធជនក្មេងៗត្រូវខ្មែរក្រហមចាប់បង្ខំឲ្យធ្វើជាឈ្លប គិញសម្ងាត់ឃ្លាំចាំមើលកំហុសឪពុកម្តាយរបស់ខ្លួននិងជាឃាតករសម្លាប់មនុស្ស ។ ខ្មែរក្រហមប៉ុនប៉ងប្រើប្រាស់យុទ្ធជនវ័យក្មេងជាមូលដ្ឋានគ្រឹះក្នុងការកសាងសង្គមថ្មីមួយ ។ ប្រវត្តិវិទូ ប៉ែន យៀនិន ពន្យល់ថាដើម្បីបង្កើតសង្គមថ្មីមួយ ខ្មែរក្រហមបានដើរតួជាអ្នកបីបាច់ថែរក្សាកុមារ “គ្រួសារភាគច្រើនត្រូវព្រាត់ប្រាសកូន ព្រោះកូនទាំងនោះត្រូវអង្គការប្រមូលផ្តុំតាមជំរំកុមារឬតាមការដ្ឋានឆ្ងាយរៀងខ្លួន” ។

លោកស្រីអេលីហ្សាប៉ែត ប៉ែកយ័រ បានបង្ហាញករណីភ្ញាក់

ផ្អើលចំពោះយុទ្ធជនក្មេងៗ ខ្មែរក្រហមដែលចូលរួមក្នុងសង្គ្រាម ។ កងទ័ពស្រីវ័យក្មេងរបស់ខ្មែរក្រហមម្នាក់ត្រូវទាហាន លន់ ណុល ចាប់ខ្លួនបានក្នុងសង្គ្រាមឆ្នាំ១៩៧៣ ។ «ទាហានក្មេងទាំងនេះបានចាកចេញពីគ្រួសារផ្ទះសម្បែងតាំងពីអាយុ១២ឆ្នាំ ហើយមិនដែលបានវិលត្រឡប់ទៅជួបជុំឪពុកម្តាយឬបងប្អូនឡើយ ។ យុទ្ធជនវ័យក្មេងទាំងនេះត្រូវបានបីបាច់ថែរក្សានិងអប់រំដោយអង្គការបដិវត្តន៍» ក្រោយពីឡើងកាន់អំណាចខ្មែរក្រហមបានជំរុញឲ្យយុទ្ធជនវ័យក្មេងទាំងនោះទទួលភារកិច្ចមើលថែរក្សាយុវជនបដិវត្តន៍ ។ វាជាការលំបាកយ៉ាប់យ៉ឺនមួយសម្រាប់កុមារដែលមានអាយុចាប់ពី៦ឆ្នាំឡើងទៅដែលរស់នៅក្នុងជំរំ ព្រោះកុមារទាំងនោះគ្មានការលេងកម្សាន្ត សម្អិតសម្អាង ឬមានការលូតលាស់ចម្រើនឡើយ ដូច្នេះជីវិតរបស់កុមារទាំងនោះត្រូវរងនូវការលំបាក កំព្រីកំព្រាគ្មានអាណាព្យាបាលឬគ្រូបាធ្យាយថែរក្សានិងប្រៀនប្រដៅឡើយ ។ ការនេះបណ្តាលឲ្យយុទ្ធជនក្មេងៗខ្លះប្រែធាតុទៅជាសាហាវឃោរឃៅ ។ ទីបំផុតយុទ្ធជនវ័យក្មេងទាំងនោះត្រូវឯកោក្នុងសង្គម ដោយសារបាត់ក្តីប៉ងស្រឡាញ់ពីអ្នកដទៃ ។

បណ្ឌិត ក្រេក អេចឆេសាន់ ពន្យល់ពីមូលហេតុដែលនាំឲ្យខ្មែរក្រហមចង់ប្រើប្រាស់យុទ្ធជនវ័យក្មេងដើម្បីជាមូលដ្ឋានកសាងសង្គមថ្មីរបស់ខ្លួនថា÷ ខ្មែរក្រហមយល់ឃើញថា យុទ្ធជនវ័យក្មេងគឺជាឧបករណ៍សំខាន់មួយក្នុងចលនាបម្រើបដិវត្តព្រោះស្ថិតនៅវ័យក្មេងខ្ចី យុទ្ធជនវ័យក្មេងៗមិនអាចយល់ដឹងអំពីអ្វីដែលត្រូវនិងអ្វីដែលខុសទេ រួមនឹងការឃ្លាតឆ្ងាយពីការប្រៀនប្រដៅអប់រំអំពីការរស់នៅនិងលក្ខណៈសម្បត្តិល្អក្នុងជីវិតនោះ យុទ្ធជនវ័យក្មេងមានផ្លូវជ្រើសរើសសំខាន់តែមួយគត់សម្រាប់ខ្លួន គឺការប្រែក្លាយខ្លួនទៅជាសរសរទ្រូងរបស់បក្ស ។ ខ្មែរក្រហមយល់ថាមជ្ឈិមវ័យគឺជាវ័យដែលលំបាកក្នុងការអូសទាញនិងអាចបង្កឲ្យមានបញ្ហាច្រើនក្នុងដំណើរការកសាងបដិវត្តន៍ ។ ប្រទេសកុម្មុយនិស្តជាច្រើនបានឆ្លៀតឱកាសយកចំណេញពីភាពងាយស្រួលនិងតម្លៃរបស់វ័យកុមារនេះដោយបានរៀបចំឡើងនូវកម្មវិធីប្រមូលផ្តុំយុទ្ធជនទាំងនោះ ហើយបំពាក់បំប៉នមនោគមវិជ្ជាដើម្បីឲ្យយុទ្ធជនទាំងនោះជឿស្រឡាញ់ និងអនុវត្តតាមលទ្ធិរបស់ខ្លួន ។

លោក មេ អេប៊ីហារា ក៏បានធ្វើការសន្និដ្ឋានលើហេតុផលដូចគ្នានេះដែរដោយអះអាងនូវមូលហេតុថា ដោយសារភាពបរិសុទ្ធងាយស្រួលក្នុងការបត់បែនតាមចិត្តប្រាថ្នា ខ្មែរក្រហមមានចេតនាចង់ប្រើប្រាស់កុមារក្នុងការបន្តវេនបដិវត្តន៍ ។ លោកបង្ហាញថា «ក្រោយអាយុ៧ឆ្នាំ កុមារត្រូវខ្មែរក្រហមបំបែកចេញពីក្រុមគ្រួសារទៅរស់នៅក្នុងជំរំប្រមូលផ្តុំនិងបញ្ចូលជាកម្លាំងក្នុងកងកុមារដើម្បីធ្វើការងារ ។ ចំណែកយុវជនត្រូវបញ្ជូនទៅធ្វើការនៅកន្លែងឆ្ងាយពីភូមិស្រុក ផ្ទះសម្បែង ។ ដោយឡែកលទ្ធផលសម្ភាសន៍ជាមួយនឹងអតីតយុទ្ធជនមន្ទីរស-២១ ខាងក្រោមនេះនឹងរឹតតែជួយបង្ហាញកាន់តែច្បាស់ថែមទៀត ។ លោក អេប៊ីហារា ប្រាប់ហេតុផលចំពោះចេតនារបស់ខ្មែរក្រហមក្នុងការអូសទាញយុទ្ធជនក្មេងៗឲ្យចូលបម្រើក្នុងចលនាបដិវត្តខ្មែរក្រហមថា យុទ្ធជនវ័យក្មេងគឺជាកម្លាំងដ៏ចាំបាច់និងពិសេសមួយក្នុងការបំពាក់បំប៉នមនោគមវិជ្ជាបដិវត្ត ព្រោះយុទ្ធជនទាំងនោះស្ថិតក្នុងវ័យងាយអូសទាញបំផុត ។ មនោគមវិជ្ជាអូសទាញដើម្បីប្រើប្រាស់ក្នុងបុព្វហេតុចលនាបដិវត្តនោះរួមមានដូចជាការបង្កើតក្រុមនិងកងចល័តក្នុងការធ្វើការងារ និងការរស់នៅឆ្ងាយពីឪពុកម្តាយ ។ មនោគមវិជ្ជានេះធ្វើឲ្យចំណងរវាងយុទ្ធជននិងក្រុមគ្រួសារត្រូវឃ្លាតឆ្ងាយបន្តិចម្តងៗ ប៉ុន្តែទំនាក់ទំនងរវាងយុទ្ធជនទាំងនោះជាមួយអង្គការនិងថ្នាក់ដឹកនាំកាន់តែស្អិតល្អូតឡើង ។ ជារួមយើងឃើញថាក្នុងវ័យមួយដ៏ក្មេងខ្ចីដែលយុទ្ធជនទាំងនោះមិនអាចរស់នៅក្រោមអាណាព្យាបាលឪពុកម្តាយបាន ដូច្នោះយុទ្ធជនទាំងនោះត្រូវតែបង្ខំចិត្តចូលរួមក្នុងក្រុមណាមួយច្បាស់លាស់ក្នុងចលនាបម្រើបដិវត្តខ្មែរក្រហម ។

ដូច្នេះហើយបានជាកុមារកម្ពុជាជាច្រើនត្រូវខ្មែរក្រហមបញ្ចូលមនោគមវិជ្ជាឲ្យក្លាយទៅជាអ្នកទទួលបញ្ជានិងអនុវត្តបញ្ជាដ៏សាហាវនិងយង់ឃ្នងបាន ។ **លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ដែលធ្លាប់ជាអតីតទាហានដ៏ក្មេងម្នាក់របស់ខ្មែរក្រហមយល់ឃើញយ៉ាងច្បាស់អំពីល្បិចកលនិងដំណើរការប្រែក្លាយកុមារទាំងនោះរបស់ខ្មែរក្រហមដូចដែលសៀវភៅរបស់គាត់ដែលមានចំណងជើងថា «ធាតុពិតនៃរបបកម្ពុជាប្រជាធិបតេយ្យ» បង្ហាញយ៉ាងច្បាស់នូវល្បិចកលប្រើប្រាស់យុទ្ធជនខ្មែរក្រហម ហើយគាត់បានហៅយុទ្ធជនវ័យក្មេងដែលចូលរួមក្នុងចលនាខ្មែរក្រហមថាជាឃាតករដ៏សាហាវផង និងជាជនរងគ្រោះដ៏កម្សត់នៃរបបបរិច្ចេទកម្មនោះផង ។**

តាមការបកស្រាយរបស់អ្នកឯកទេសដែលបានសិក្សាលើចិត្តសាស្ត្ររបស់ជនរងគ្រោះ និងតាមការសិក្សារបស់អ្នកស្រាវជ្រាវលើកុមារឃើញថា វ័យកុមារគឺជាវ័យដែលងាយស្រួលក្នុងការបង្ហាត់បង្រៀន និងលាបពណ៌ជាទីបំផុត ។ ខ្មែរក្រហមបានយល់ដឹងពីភាពងាយស្រួលនិងមានប្រយោជន៍របស់វ័យកុមារនេះ ហើយខ្មែរក្រហមឆ្លៀតឱកាសយកចំណេញដោយអូសទាញយុទ្ធជនវ័យក្មេងឲ្យចូលរួមបម្រើចលនាបដិវត្តដើម្បីកសាងសង្គមថ្មីមួយរបស់ខ្លួន ។ អ្នកប្រវត្តិសាស្ត្រផ្នែកចិត្តសាស្ត្រនិងស្នាដៃរបស់អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រទាំងនេះហើយដែលជាកត្តាជំរុញឲ្យខ្ញុំចាប់អារម្មណ៍ថាយុទ្ធជនវ័យក្មេងដែលបម្រើក្នុងចលនាបដិវត្តខ្មែរក្រហមគឺជាទាសករនិងជាជនរងគ្រោះនៃចលនាបុព្វហេតុបម្រើបដិវត្តន៍ខ្មែរក្រហម ។

ខាងក្រោមនេះខ្ញុំនឹងបង្ហាញភ័ស្តុតាងជាក់ស្តែងដែលយុទ្ធជនវ័យក្មេងមួយក្រុមបានទទួលរងគ្រោះក្នុងចលនាបម្រើបដិវត្តខ្មែរក្រហមនៅមន្ទីរស-២១ ។ ការរងគ្រោះកើតឡើងតាំងពីការចាប់ផ្តើមចូលរួមដំបូងរបស់កុមារក្នុងចលនាបម្រើបដិវត្តខ្មែរក្រហមក្នុងតំបន់៣១ ខេត្តកំពង់ឆ្នាំង មានភារកិច្ចជាឈ្លបភូមិឃុំរហូតជាបន្តបន្ទាប់ក្លាយខ្លួនជាយុទ្ធជនវ័យក្មេងបម្រើ



ក្រុមកងការពារមន្ទីរស-២១ហាត់ក្បាច់ប្រយុទ្ធ

ការងារក្នុងមន្ទីរស-២១ ។ ការបង្ហាញនេះគឺតាមរយៈបទសម្ភាសផ្ទាល់ជាមួយអតីតយុទ្ធជនវ័យក្មេងមន្ទីរស-២១ ចំនួន ១៨នាក់និងបងប្អូនឪពុកម្តាយរបស់អតីតយុទ្ធជនមន្ទីរស-២១ ចំនួន២៨នាក់ដែលស្លាប់បាត់បង់ជីវិតក្នុងចលនាបុព្វហេតុកសាងបដិវត្តន៍ខ្មែរក្រហមនៅមន្ទីរស-២១ ។

**ការចូលរួមក្នុងចលនាបដិវត្ត**

ការចូលរួមបម្រើក្នុងចលនាបដិវត្តរបស់កុមារខ្លះដោយដោយការស្ម័គ្រចិត្ត ហើយមិនបានពិចារណានិងដោយភាពល្ងង់ខ្លៅ ។ សមមិត្ត គង់ និងសមមិត្ត ដៃ មានចិត្តសប្បាយត្រេកអរយ៉ាងខ្លាំង នៅពេលបានចូលបម្រើជាកងឈ្លបឃុំរបស់ខ្មែរក្រហម ។ គាត់ទាំងពីរសប្បាយចិត្តដោយមានកាំភ្លើងកាន់ និងទទួលបាននូវការគោរពកោតក្រែងពីកុមារផ្សេងទៀតនិងប្រជាជនក្នុងភូមិស្រុកជាមួយគ្នា ។ ជាងនេះទៀត គង់ និង ដៃ យល់ឃើញថាការចូលរួមធ្វើកងឈ្លបអាចឲ្យគាត់បានហូបឆ្អាញ់ ហើយការងារក៏មិនស្មុវលំបាក ។ គង់ និង ដៃ បានប្រាប់មូលហេតុនៃការចូលរួមបម្រើក្នុងចលនាបដិវត្តខ្មែរក្រហមរបស់កុមារថាកុមារខ្លះមើលឃើញប្រយោជន៍ចំពោះមុខ ព្រោះនៅពេលដែលបានចូលជាកងឈ្លប ឬសេនាជន កងឈ្លបទាំងនោះនឹងបានគេចផុតពីការងារពលកម្មធ្ងន់ធ្ងរដូចជាការរែកដីលើកទំនប់ជាដើម ។ កងឈ្លបមានភារកិច្ចស្ពាយកាំភ្លើងរបស់ខ្លួនដើរចុះដើរឡើងយ៉ាងសប្បាយចិត្ត ម្យ៉ាងទៀតពេលដែលបានធ្វើជាកងឈ្លបកុមារក៏ដូចជាប្រជាជនក្នុងភូមិមានការកោតញញើត ។ ម្យ៉ាងទៀតកងឈ្លបមានរបបហូបចុកប្រសើរជាងអ្នកភូមិធម្មតា ។



ផ្ទុយទៅវិញ កុមារភាគច្រើនមិនចង់ចូលរួមបម្រើក្នុងចលនាបដិវត្តធ្វើជាសេនាជនឬកងឈ្លបខ្មែរក្រហមឡើយ ។ ទោះបីជាកុមារទាំងនោះមិនពេញចិត្តក្នុងការចូលរួមជាមួយខ្មែរក្រហមយ៉ាងណាក៏ដោយ ក៏ទីបំផុតកុមារទាំងនោះត្រូវតែចូលរួមដោយការទាល់ច្រកនិងគ្មានផ្លូវផ្សេងសម្រាប់ជ្រើសរើស ។ កុមារទាំងនោះត្រូវប្រធានភូមិឃុំ ឬលេខាស្រុក បង្ខំឲ្យចូលបម្រើបដិវត្តន៍ដោយមិនអាចប្រឆាំងនឹងអង្គការបាន ។ ក្រោយពីចូលជាសេនាជនភូមិឃុំឬឈ្លបស្រុកអស់មួយរយៈហើយមកនោះ កងឈ្លបកុមារទាំងអស់ត្រូវប្រធានឃុំ ឬលេខាស្រុក ចាត់តាំងឲ្យធ្វើដំណើរចេញពីភូមិស្រុកទៅបម្រើបដិវត្តន៍នៅកន្លែងផ្សេងទៀត ។ មិនខុសពីលើកមុន កងឈ្លបកុមារនៅតែគ្មានផ្លូវដើរក្រៅពីការគោរពតាមការចាត់តាំងនិងបញ្ជារបស់អង្គការ ។ កងឈ្លបកុមារឃុំឬស្រុកត្រូវចាកចេញពីភូមិស្រុកទាំងអល់អែក ។ កងឈ្លបកុមារត្រូវឃ្លាតឆ្ងាយពីឪពុកម្តាយនិងបងប្អូន ។ ទោះជាចង់ឬមិនចង់ កងឈ្លបកុមារទាំងនោះត្រូវតែគោរពតាមបញ្ជាអង្គការនិងការចាត់តាំង គួបផ្សំនឹងល្បិចបោកប្រាស់របស់គណៈឃុំនិងគណៈស្រុក ។ ការបោកប្រាស់នោះមានការរៀបរាប់អំពីការងារហូបចុកនិងអំពីអនាគតផលប្រយោជន៍ដ៏ល្អទៅថ្ងៃមុខនៅពេលកងឈ្លបកុមារបានចូលរួមក្នុងចលនាបម្រើបដិវត្តនៅមជ្ឈិមជាដើម ។ **(នៅមានត)**

# ការស្រាវជ្រាវតាមរយៈរូបថតជនរងគ្រោះ មិនរិន ហៅ យ៉េត





របបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមបានបន្សល់ទុករូបថតរាប់ពាន់សន្លឹក ។ ប៉ុន្តែភាគច្រើននៃឯកសារចម្លើយសារភាពទាំងនោះពុំសូវឃើញមានរូបថតជនរងគ្រោះដែលត្រូវបានសួរចម្លើយ និងជនរងគ្រោះដែលត្រូវបានយកទៅសម្លាប់ក្រោយពីសួរចម្លើយ ភ្ជាប់ជាមួយនឹងឯកសារចម្លើយសារភាពទាំងនោះទេ ។ រូបថតជនរងគ្រោះមួយចំនួនធំពុំមានអ្វីជាសម្គាល់ដូចជាឈ្មោះ អាយុ កាលបរិច្ឆេទនៃការចាប់ខ្លួន និងកាលបរិច្ឆេទនៃការកម្ទេចជាដើម ។ រូបថតមួយចំនួនតូចត្រូវបានស្រាវជ្រាវរកឃើញពត៌មានពិស្តាររបស់ជនរងគ្រោះ ។ រូបថតលេខ០១៦៨៤ ត្រូវបានរកឃើញជាមួយនិងចម្លើយសារភាពលេខ M២២៦ របស់ឈ្មោះ មិន រិន ហៅ យ៉េត ក្រោមការសួរចម្លើយរបស់ឈ្មោះ វ៉េង វ៉ុយ ។ ចម្លើយសារភាពនេះធ្វើនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ ។ (ឯកសារប្រវត្តិរូបលេខ TSL ០២៥៦) ។

## ប្រវត្តិរូបសង្ខេបរបស់ជនរងគ្រោះ

មិន រិន ហៅ យ៉េត អាយុ២៥ឆ្នាំ ភេទប្រុស ជនជាតិខ្មែរ កើតនៅឆ្នាំ១៩៥២ នៅលើវ មានស្រុកកំណើតនៅភូមិជ្រោយថ្ម ឃុំចំបក់ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។ ឪពុកឈ្មោះ កែវ មិន អាយុ៦០ឆ្នាំ (ស្លាប់) ម្តាយឈ្មោះ ជូ ប៉ាង អាយុ៥៥ឆ្នាំ (នៅរស់) មានបងប្អូនបង្កើតចំនួន៧នាក់ ប្រុស៣នាក់ ស្រីចំនួន៤នាក់ ហើយបានចូលធ្វើបដិវត្តន៍ចំនួន៣នាក់ និងធ្វើនៅសហករណ៍ចំនួន៤នាក់ ។ មិន រិន ចូលធ្វើបដិវត្តន៍នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧០ ។ នៅឆ្នាំ១៩៧៥ ជាអនុក្រុមនៃកងពលលេខ៣១០ ឬ៤០៦ ប្រចាំតំបន់៤២ ។ នៅឆ្នាំ១៩៧៧ មិន រិន ជាយុទ្ធជនកងតូចទី២ កងធំទី២នៃវរសេនាតូចលេខ៣១៧ រស់នៅភូមិជ្រោយថ្ម ឃុំជ្រោយថ្ម ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ហើយបានសារភាពថាបានចូលធ្វើសេ.អ៊ី.អា នៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៤ ។ មិន រិន ត្រូវបានឃាត់ខ្លួននៅកងពលលេខ៣១០ នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៧ ។

## ការចូលបដិវត្តន៍និងមូលហេតុរបស់ជនរងគ្រោះប្រឆាំងនឹងបដិវត្តន៍

តាំងពីដើមរហូតមកដល់ថ្ងៃចូលបដិវត្តន៍ មិន រិន បានឆ្លើយសារភាពថា "ចំពោះខ្ញុំចាប់តាំងពីជីវិតក្តីកាលណាមក ខ្ញុំរស់នៅជាមួយឪពុកម្តាយខ្ញុំ រហូតខ្ញុំមានអាយុ១៦ឆ្នាំ ទើបឪពុកម្តាយខ្ញុំគាត់ឲ្យខ្ញុំទៅនៅជាមួយម្តាយធំនៅភូមិក្រវ៉ា សង្កាត់ដងក្តារ ស្រុកស្ទឹងត្រង់ (ខេត្តកំពង់ចាម) ។ ចំពោះរូបខ្ញុំរស់នៅជាមួយម្តាយធំខ្ញុំបានប្រហែល៣ឆ្នាំត្រូវនឹងឆ្នាំ១៩៦៨ ខ្ញុំក៏សុំម្តាយធំខ្ញុំមកនៅជាមួយម្តាយខ្ញុំនៅភូមិកំណើតវិញ ។ ខ្ញុំមកនៅជាមួយម្តាយខ្ញុំបាន១ឆ្នាំ ខ្ញុំក៏ទៅស៊ីឈ្នួលចិញ្ចឹមត្រីឲ្យចិននៅភូមិរបស់ខ្ញុំ ។ ខ្ញុំស៊ីឈ្នួលគេនេះអស់រយៈពេល៦ខែរួចហើយ ខ្ញុំក៏មកនៅជាមួយម្តាយខ្ញុំវិញ ។ រហូតមកដល់ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧០ ទើបខ្ញុំសុំឪពុកម្តាយរបស់ខ្ញុំចូលធ្វើបដិវត្តន៍តែម្តង" ។ ក្នុងការចូលធ្វើបដិវត្តន៍ មិន រិន បានទាក់ទងជាមួយឈ្មោះ ចិត្ត ជាប្រធានឃុំជ្រោយថ្ម បន្ទាប់ពីធ្វើការនៅទីនោះបានរយៈពេល៤ខែ ។ មិន រិន ត្រូវបានឈ្មោះ ចិត្ត បញ្ជូនឲ្យទៅនៅអង្គភាពស្រុកព្រែកប្រសព្វក្រោមការដឹកនាំរបស់ឈ្មោះ ចាន់ ធី និង ខិម ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៣ មិន រិន ត្រូវបានចាត់តាំងឲ្យមកនៅអង្គភាពវរសេនាតូចលេខ៤០៦ ប្រចាំតំបន់៤២ ក្រោមការដឹកនាំរបស់ឈ្មោះ ណន សែម និងដៃ ដែលអ្នកទាំងបីនេះជាគណៈវរសេនាតូចលេខ៤០៦ ។

ចម្លើយសារភាពនេះបានបង្ហាញពីមូលហេតុដំបូងនៃការប្រឆាំងបដិវត្តន៍ថា"មិត្តធ្វើបដិវត្តន៍យូរហើយ មិត្តឃើញទេ មិត្តនៅតែជាយុទ្ធជនដដែល មិនដែលបានទទួលនាទីអ្វីសោះ បើមិត្តតាមខ្ញុំ មិត្តនឹងមានមុខមាត់បុណ្យស័ក្តិនឹងគេ ហើយរស់នៅសប្បាយហ៊ឺហាមានស្រីស្រាគ្រប់សារពើទាំងអស់ ។" នេះជាសម្តីរបស់ ណន ដែលបានអប់រំ មិន រិន នៅខែមីនា ឆ្នាំ១៩៧៤ ។ ដោយសារតែការអប់រំរបស់ ណន ចំពោះ មិន រិន ឲ្យមើលឃើញបដិវត្តន៍ខ្មោងងឹតបែបនេះទើប មិន រិន សុខចិត្តចូលរួមក្នុងចលនា សេ.អ៊ី.អា ដើម្បីប្រឆាំងនឹងបដិវត្តន៍វិញ ។

## ប្រវត្តិសង្ខេបនៃសកម្មភាពរបស់ជនរងគ្រោះក្នុងការប្រឆាំងនឹងបដិវត្តន៍

ក្រោយពីបានចូលបម្រើកម្លាំងសេ.អ៊ី.អា រួចមក មិន រិន

បានខិតខំយកចិត្តទុកដាក់ក្នុងការកសាងកម្លាំងឲ្យបានកាន់តែច្រើនឡើងដើម្បីវាយបដិវត្តន៍ធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍គ្រប់រូបភាពទាំងអស់ ហើយបានបំផុសយុទ្ធជននៅក្នុងអង្គភាពឲ្យសេរីបន្តុំនាស់រវាងអង្គភាពមួយទៅអង្គភាពមួយទៀតនិងទាក់ទងខ្សែរយៈដើម្បីធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ ។ នៅសមរភូមិកំពង់ចាម មិន រិន បានបំផុសយុទ្ធជនដែលរួមអាវុធជាមួយគ្នាថា «អង្គការឲ្យយើងវាយនៅសមរភូមិនេះ វាយខ្មាំងមិនឈ្នះទេ ពីព្រោះកម្លាំងខ្មាំងច្រើនជាងយើងឆ្ងាយណាស់ បើខ្មាំងវាយបុកមកលើខ្សែត្រៀមខ្មាំង យើងត្រូវនាំគ្នារត់ចោលខ្សែត្រៀមទៅបានរួចខ្លួន» ។ នៅសមរភូមិ ភូមិមេម៉ាយ មិន រិន ត្រូវបានចាត់ឲ្យធ្វើខាងសេដ្ឋកិច្ចដើម្បីផ្គត់ផ្គង់យុទ្ធជននៅសមរភូមិមុខ ។ ប៉ុន្តែក្នុងរយៈពេលនោះ មិន រិន បានធ្វើសកម្មភាពក្បត់ដូចជាបំផ្លាញឆ្នាំងចាន បំផ្លាញកាំបិតពូថៅ ដាំបាយឲ្យឆៅ និងខ្ជប់បាយមិនដាក់ម្ហូបគ្រប់កញ្ចប់ជាដើម ។

ខែមេសា ឆ្នាំ១៩៧៥ មិន រិន ត្រូវបានផ្លាស់មកនៅអង្គភាពវរសេនាតូច៤០៦ ក្រោមការដឹកនាំរបស់ឈ្មោះ ណាន សែម និងដៃ ដដែល ។ មិន រិន បានធ្វើសកម្មភាពក្បត់បដិវត្តន៍ដូចជាសេរីក្នុងការដើរហើរ សប្បាយហ៊ឺហា ភ្លើតភ្លើនពីជ័យជម្នះគិតតែពីលេងល្បែងពាលាអាវាសែ លេងបៀអាប៉ោងជាប្រចាំ ស្លៀកពាក់ខ្ជះខ្ជាយ ស៊ីចុកតាមអំពើចិត្ត មិនស្តាប់តាមការណែនាំរបស់អង្គការ ។ (អង្គភាពលេខ៤០៦ ត្រូវបានផ្លាស់ប្តូរទៅជាអង្គភាពលេខ១១៣ នៅខែឧសភា ឆ្នាំ១៩៧៥) ។ ក្រោយមកអង្គភាពរបស់ មិន រិន ត្រូវបានចាត់ឲ្យទៅធ្វើស្រែនៅស្រុកព្រៃឈរ ខេត្តកំពង់ចាម នៅក្នុងពេលនោះ មិន រិន បានធ្វើសកម្មភាពបំផ្លាញដំណាំស្រូវតាមគ្រប់រូបភាព ។ ក្នុងខែមិថុនា ឆ្នាំ១៩៧៥ មិន រិន ត្រូវបានចាត់តាំងឲ្យទៅនៅអង្គភាពពិសេសនៃអនុវរសេនាតូចប្រចាំវរសេនាធំលេខ១១ ដែលស្ថិតនៅក្រោមការដឹកនាំរបស់ គន និង សាម ។ មិន រិន បានបន្តធ្វើសកម្មភាពសេរីដូចជាលួចបេះផ្លែដូងជាញឹកញាប់និងមិនប្រុងប្រយ័ត្នក្នុងការយាមកាម ។ នៅខែកក្កដា ឆ្នាំ១៩៧៥ មិន រិន ត្រូវមានភារកិច្ចហាត់រៀនបច្ចេកទេស ។ មិន រិន បានអនុវត្តសកម្មភាពក្បត់ដោយខ្លួនឯងជាបន្តបន្ទាប់ ដូចជាលួចអង្ករយកមកដាំបាយឯកជន ដើរហើរសេរីក្នុងការទាក់ទង និងលួចសម្ភាររបស់អង្គភាពខ្ជិលហាត់រៀនបច្ចេកទេសធ្វើពុតជាឈឺមិនស្តាប់តាមការណែនាំរបស់កម្មាភិបាល ។ នៅខែវិច្ឆិកា ឆ្នាំ ១៩៧៥ អង្គការបានចាត់ឲ្យទៅថែស្រូវនៅឈ្នួញហើយ មិន រិន នៅតែធ្វើសកម្មភាពក្បត់ជាបន្តទៀត ។

ចូលដល់ខែមករា ឆ្នាំ១៩៧៦ អង្គការបានចាត់ មិន រិន ឲ្យទៅដឹកប្រឡាយនៅអូរកុង ។ នៅទីនោះ មិន រិន បានបំផ្លាញសម្ភារដឹកប្រឡាយអស់មួយចំនួន ពុតត្បុតខ្ជិលធ្វើការងារដើរហើរទាក់ទងសេរីជាមួយប្រជាជន ។ ក្នុងការបំផុសប្រជាជន មិន រិន បានលើកឡើងថា «សព្វថ្ងៃយើងធ្វើការងារយ៉ាប់ណាស់ ឯបាយវិញលាយជាមួយត្រកួនដូចជ្រូក» ។ សកម្មភាពក្បត់របស់ មិន រិន ត្រូវបានរាយការណ៍ឲ្យទៅកម្មាភិបាលហើយត្រូវបានចាប់ចងដាក់ប្រវាក់អស់រយៈពេលកន្លះខែ ប៉ុន្តែត្រូវបានដោះលែងវិញនៅខែមីនា ឆ្នាំ១៩៧៦ ។ នៅខែឧសភា ឆ្នាំ១៩៧៦ អង្គភាពរបស់ មិន រិន ត្រូវបានផ្លាស់ពីតាមោគមកធ្វើស្រែនៅកប់ស្រូវ ហើយ មិន រិន បានបន្តសកម្មភាពក្បត់ក្នុងការបំផ្លាញខាងកសិកម្មថែមទៀត ។

នៅខែកក្កដា ឆ្នាំ១៩៧៦ អង្គភាពរបស់ មិន រិន ត្រូវបានអង្គការចាត់កម្លាំងមួយចំនួនទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង និងមួយចំនួនទៀតត្រូវបានចាត់ឲ្យទៅធ្វើសំណង់នៅប្រាំងចំរេះ ។ ពេលនោះ មិន រិន បានធ្វើសកម្មភាពបំផ្លាញក្នុងការសាងសង់ ។ នៅខែសីហា ឆ្នាំ១៩៧៦ មិន រិន ត្រូវបានផ្លាស់ទៅធ្វើស្ពាននៅព្រែកព្នៅ ហើយបានបន្តសកម្មភាពក្បត់ជាបន្តបន្ទាប់រហូតដល់ខែតុលា ឆ្នាំ១៩៧៦ ទើបអង្គការចាត់តាំងឲ្យទៅដាំបន្លែនិងដាំស្រូវនៅប្រាំងចំរេះវិញ ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ មិន រិន ត្រូវបានចាត់ឲ្យទៅដាក់មងនៅបឹងតាមោគ នៅក្នុងរយៈពេលនោះ មិន រិន បានធ្វើសកម្មភាពបំផ្លាញគ្រប់រូបភាពតាមដែលអាចធ្វើទៅបាន ហើយថែមទាំងបានបំផុសប្រជាជនថា «យ៉ាប់ណាស់អ៊ំអើយ ហូបបបរព្រឹកហូបបបរល្ងាច ហើយធ្វើការងារទាំងយប់ទាំងថ្ងៃទៀត ឯម្នាក់ៗស្គមអស់ហើយ» ។ ការនិយាយបែបនេះក្នុងគោលបំណងធ្វើឲ្យខូចខាតគោលនយោបាយរវាងកងទ័ពនិងប្រជាជន ។

ឆ្នាំ១៩៧៧ មិន រិន ត្រូវបានចាត់ឲ្យមកឲ្យដាំបន្លែវិញ ហើយសកម្មភាពក្បត់បានអនុវត្តតាមដែលអាចធ្វើទៅបាន ។ នៅខែមីនា ឆ្នាំ១៩៧៧ អង្គភាពរបស់ មិន រិន ត្រូវបានផ្លាស់ទៅស្ទូងស្រូវនៅទួលសង្កែ ។ សកម្មភាពបំផ្លាញផ្នែកកសិកម្មចេះតែបន្តធ្វើទៀតហើយលើសពីនេះ មិន រិន បានបំផុសយុទ្ធជននៅសមរភូមិថា "បដិវត្តន៍ធ្វើការទាំងយប់ទាំងថ្ងៃនៅតែស៊ីមិនគ្រប់គ្រាន់ បើយើងត្រឡប់ទៅផ្ទះវិញ យើងសប្បាយចិត្តមិនលំបាកដូចបដិវត្តន៍ទេ" ។ ការបំផុសនេះសំដៅធ្វើឲ្យយុទ្ធជនរត់ចោលជួរទ័ពដើម្បីកសាងកម្លាំងក្បត់ប្រឆាំងនឹងបដិវត្តន៍ ។

ជាមួយគ្នានោះដែរ ពេលដែលអង្គការចាប់បានកម្លាំងក្បត់ដែលជាមេដឹកនាំ មិន រិន បាននិយាយបំភ័យយុទ្ធជនថា "មិត្តឯងមើលប្រហែលកងវរសេនាតូចម៉េចនៅអង្គការចាប់ខ្លួន ចុះបើយើងជាយុទ្ធជនមិនដឹងយ៉ាងម៉េចដែរទេ" ។ នៅខែឧសភា ឆ្នាំ១៩៧៧ ខ្សែរបស់ មិន រិន ត្រូវបានអង្គការចាប់ខ្លួនអស់ចំណែក មិន រិន ត្រូវផ្អាកសកម្មភាពមួយរយៈព្រោះភ័យខ្លាចអង្គការចាប់ខ្លួនបាន ។ នៅខែមិថុនា ឆ្នាំ១៩៧៧ អង្គការបានចាត់តាំងអង្គភាពរបស់ មិន រិន ទៅរៀននយោបាយនៅសាលាវត្តភ្នំចំនួន៣ថ្ងៃ ។ ពេលរៀននយោបាយចប់ មិន រិន ត្រូវបានអង្គការចាត់ឲ្យទៅនៅក្នុងអង្គភាពវរសេនាតូចលេខ១១២ ក្រោមការដឹកនាំរបស់ឈ្មោះ ផល និង ស្រុន ។ បន្ទាប់មកអង្គការបានចាត់តាំងអង្គភាពនោះឲ្យទៅធ្វើស្រែនៅទួលសង្កែ ប៉ុន្តែ មិន រិន មិនបានធ្វើសកម្មភាពធ្វើទេ ដោយមូលហេតុមានការផ្លាស់ប្តូរកម្មាភិបាលថ្មី ហើយម្យ៉ាងទៀតដោយសារមិនទាន់ស្គាល់កម្មាភិបាលទាំងនោះ ។ ខែកក្កដា ឆ្នាំ១៩៧៧ មិន រិន បានចាប់ផ្តើមធ្វើសកម្មភាពក្បត់បន្តទៀត ប៉ុន្តែត្រូវបានចាប់ខ្លួនបញ្ជូនមកឲ្យឈ្មោះ ផល ប៉ុន្តែ ផល បានទុក មិន រិន ឲ្យនៅធ្វើដីជាមួយមិនឲ្យទៅណាឆ្ងាយឡើយ ។ ពេលនោះ មិន រិន ត្រូវផ្អាកសកម្មភាពប្រឆាំងមួយរយៈសិន ព្រោះអង្គការកំពុងតែតាមដាន ។

ខែតុលា ឆ្នាំ១៩៧៧ មិន រិន ត្រូវបានអង្គការចាត់ឲ្យទៅនៅក្នុងកងវរសេនាតូចលេខ៣១៧ ក្រោមការដឹកនាំរបស់ ហៀង សុក និង ផល ។ មិន រិន បានបន្តសកម្មភាពក្បត់របស់ខ្លួនទៀតរហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៧ ត្រូវបានចាប់បង្ខំខ្លួន៣ថ្ងៃនៅអង្គភាពរបស់ ផល ហើយត្រូវបាន ផល បញ្ជូនមកកន្លែងមួយទៀត (មន្ទីរស-២១) ។

និយាយឲ្យខ្លីទៅ រាល់សកម្មភាពដែល មិន រិន ហៅ យ៉េត បានឆ្លើយសារភាពនិងធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហមកើតចេញពីភាពអស់សង្ឃឹមការមិនជឿទុកចិត្តនិងការមិនពេញចិត្តនឹងបដិវត្តខ្មែរក្រហមដែលអង្គការបានបញ្ជាឲ្យធ្វើការមិនស្គាល់យប់ថ្ងៃ ប៉ុន្តែមានការហូបចុកមិនគ្រប់គ្រាន់ដូចដែល មិន រិន បានលើកឡើងថា "បដិវត្តន៍ធ្វើការទាំងយប់ទាំងថ្ងៃនៅតែស៊ីមិនគ្រាប់គ្រាន់ បើយើងត្រឡប់ទៅផ្ទះវិញ យើងសប្បាយចិត្តមិនលំបាកដូចបដិវត្តន៍ទេ" ។ ដោយសារតែភាពជាក់ស្តែងទាំងនេះហើយបានជា មិន រិន និងបក្ខពួកអាចអូសទាញបានកម្លាំងបានចំនួនទាំងអស់៣២នាក់ ។ ប៉ុន្តែទោះជាមានកម្លាំងយ៉ាងនេះក្តីក៏កម្លាំងក្បត់បដិវត្តន៍មួយភាគច្រើនត្រូវបានអង្គការចាប់ខ្លួននិងបញ្ជូនមកមន្ទីរស-២១ដែលជាគុក និងកន្លែងពិឃាតមនុស្សដ៏គួរឲ្យភ័យខ្លាចបំផុតហើយជនរងគ្រោះទាំងអស់ដែលជាប់ឃុំឃាំងនៅមន្ទីរស-២១នោះមានតិចតួចបំផុត ដែលមានជីវិតរស់រួចផុតពីការយកទៅសម្លាប់ចោល ។

**វ៉ាង សុភារិទ្ធ**

# សេចក្តីកែតម្រូវ

អត្ថបទដែលមានចំណងជើងថា "គំរូមួយនៃភ័ស្តុតាងឯកសារភ្ជាប់មេដឹកនាំ..." នៅក្នុងទស្សនាវដ្តីលេខ៩ ទំព័រទី៣១ កូឡោនទី១ បន្ទាត់ទី២ ត្រង់ឃ្លា "ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៧" សូមកែតម្រូវមក "ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧" វិញ ។

សូមអរគុណ

# ពាក្យស្លោកខ្មែរក្រហម

◆ **ប្តេជ្ញាបន្តពង្រីងនិងពង្រីកគោលជំហរ តស៊ូវណ្ណៈដាច់ខាត ក្នុងរយៈកាលបដិវត្តន៍ បច្ចុប្បន្ននិងអនាគត។**

(ដកស្រង់ចេញពីសៀវភៅ យស់សុ)

# វង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងប្រទេសកម្ពុជា

**(តពីលេខមុន)** ដើម្បីរស់អ្នកទោសខ្លះត្រូវបង្ខំចិត្តធ្វើអ្វីៗដែលអាក្រក់គួរស្អប់ខ្ពើម ។ ដូចដែល យូឌីត ហ័រមែន បានធ្វើការកត់សម្គាល់ទាក់ទងនឹងជនរងគ្រោះរបស់គេរវកម្មផ្នែកនយោបាយដែរថា "ប្រសិនបើស្ថិតនៅក្រោមការគាបសង្កត់ នាងក្បត់គោលការណ៍របស់ខ្លួនឯងឬក៏លះបង់មនុស្សផ្សេងទៀត មកដល់សព្វថ្ងៃនេះនាងត្រូវតែរស់នៅជាមួយនឹងរូបភាពរបស់ខ្លួនឯងដែលជាអ្នកសមគំនិតជាមួយជនដៃដល់ជាមនុស្ស "ត្រូវបានខកខុសខ្លួន" ។ ចំពោះជនរងគ្រោះភាគច្រើនលទ្ធផលគឺអត្តសញ្ញាណមួយដែលភាពល្អក់កករ ។

តែផ្ទុយទៅវិញប្រហែលជាអាចថាការបែកបាក់រវាងជីវិតអ្នកទោសមុន និងក្រោយពេលខ្លួនត្រូវបង្ខំឲ្យចូលទៅក្នុងមន្ទីរសន្តិសុខខ្មែរក្រហមមានភាពធ្ងន់ធ្ងរនិងដាច់ខាតពេករហូតដល់ធ្វើឲ្យអ្នកដែលមានវាសនានៅរស់គ្មានពាក្យអ្វីនឹងថ្លែងអំពីអ្វីដែលកើតឡើងចំពោះខ្លួន ។ ប៉ុន្តែទោះជាជីវិតបែកបាក់ឬមិនបែកបាក់ មិនអាចពុ ឬក៏អាចពុ ក៏ជនរងគ្រោះទាំងនេះបានរួចខ្លួនពីសេចក្តីស្លាប់នៅក្នុងខណៈដែលមានប្រជាជនកម្ពុជាយ៉ាងច្រើនក្រាស់ក្រែលបានស្លាប់បាត់បង់ជីវិត ។ ធាតុពិត ថាតើមានប្រជាជនកម្ពុជាប៉ុន្មាននាក់មិនបានចាកផុតពីក្រញាំដៃខ្មែរក្រហមគឺជាសំណួរមួយដែលយើងនឹងងាកមកធ្វើការពិភាក្សា ។

**ការពិនិត្យទៅលើទិន្នន័យស៊ីជម្រៅដែលធ្វើឡើងអស់រយៈពេលប្រាំឆ្នាំ**

ស្ទើរតែជារឿងពិតទៅហើយដែលប្រជាជនកម្ពុជាជាច្រើន



យល់ថាខ្មែរក្រហមបានសម្លាប់ប្រជាជនខ្មែរអស់ជាងបីលាននាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលទិន្នន័យប៉ាន់ស្មានពីចំនួនមនុស្សស្លាប់ក្រោមស្នាដៃខ្មែរក្រហមត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ អ្នកវិភាគលោកខាងលិច ស្ទើរតែទាំងអស់បានច្រានចោលនូវការអះអាងនេះថាជា "ការឃោសនារបស់វៀតណាម" ហើយគឺជាតួលេខប្រឌិតធ្វើឡើងជាពិសេសដើម្បីបម្រើផ្នែកនយោបាយ ។ នៅក្នុងឆ្នាំបន្តបន្ទាប់ៗមកទៀតអ្នកវិភាគនានាដែលមិនធ្វើការបញ្ចេញបញ្ចូលទៅលើតួលេខបីលាននាក់ បានបញ្ចុះចំនួននេះដោយផ្អែកលើការប៉ាន់ស្មានចំនួនមនុស្សស្លាប់ទៅលើទិន្នន័យដែលបានមកដោយកិច្ចសម្ភាសន៍ការវិភាគផ្នែកភូមិសាស្ត្រនិងវិធីសាស្ត្រផ្នែកស្ថិតិជាច្រើនផ្សេងទៀត ។

ប៉ុន្តែតួលេខចំនួនមនុស្សស្លាប់៣លាននាក់មិនមែនជាការកំណត់ជាក់លាក់ឡើយ ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ រដ្ឋអំណាចរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើការស្រង់ស្ទង់ជាលក្ខណៈជាតិដោយមានបំណងធ្វើសម្ភាសន៍ជាមួយរាល់មេគ្រួសារនៅទូទាំងប្រទេសអំពីអ្វីដែលកើតឡើងចំពោះគ្រួសារគាត់នៅក្នុងរបប ប៉ុល ពត ។ នាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៨៣ "គណៈកម្មការស្រាវជ្រាវពីអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ពួក ប៉ុល ពត" បានចេញផ្សាយនូវរបាយការណ៍សម្រេចចុងក្រោយរបស់ខ្លួនមួយរួមមានទិន្នន័យមួយខេត្តៗដាច់ពីគ្នា ។ នៅក្នុងចំណោមរឿងផ្សេងៗទៀតទិន្នន័យនេះបង្ហាញថាមានមនុស្សចំនួន ៣ ៣១៤ ៧៦៨ នាក់ (បីលានបីសែនមួយម៉ឺនបួនពាន់ប្រាំពីររយហុកសិបប្រាំបីនាក់) បានបាត់បង់ជីវិតនៅក្នុងជំនាន់ ប៉ុល ពត ។ ប៉ុន្តែតួលេខនេះត្រូវបានបំភ្លេចនៅក្នុងប្រទេសកម្ពុជា ហើយមិនដែលមានការដឹងឮនៅក្រៅប្រទេសកម្ពុជាឡើយរហូតមកដល់ឆ្នាំ១៩៩៥ ។

អស់រយៈពេលជាងមួយទសវត្សរ៍ក្រោយពីការចេញផ្សាយនូវរបាយការណ៍របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា អ្នកសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញនូវឯកសារជាច្រើនទាក់ទងរបាយការណ៍នោះ ។ ឯកសារទាំងអស់ធ្វើឲ្យអ្នកសិក្សាស្រាវជ្រាវនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជាអាចរៀបចំជាថ្មីឡើងវិញនូវរចនាសម្ព័ន្ធវិធីសាស្ត្រនៃគណៈកម្មការសិក្សាស្រាវជ្រាវរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយកំហុសមួយចំនួនត្រូវបានតាមដានឃើញក្នុងការសិក្សាស្រាវជ្រាវនោះ ។ វាជាកំហុសដែលនាំដល់ការប៉ាន់ស្មានលើសនូវចំនួនមនុស្សស្លាប់ ។ អ្នកធ្វើសម្ភាសន៍របស់គណៈកម្មការនៅក្នុងដើមទសវត្សរ៍ឆ្នាំ១៩៨០ បានដើរពីផ្ទះមួយទៅផ្ទះមួយ ពីភូមិមួយទៅភូមិមួយ ដើម្បីប្រមូលពត៌មានទាក់ទងនឹងការស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមកាន់កាប់ ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាហាក់ដូចជាថា អ្នកធ្វើសម្ភាសន៍មិនបានគិតដល់ចំនួនគ្រួសារដែលមានសមាជិកច្រើនរស់នៅបែកផ្ទះឬក៏នៅភូមិផ្សេងៗពីគ្នាឡើយ ។ ដូច្នេះនាំឲ្យមានការរាប់ត្រួតគ្នាពីរដងចំពោះជនរងគ្រោះដែលជាក្រុមគ្រួសារតែមួយប៉ុន្តែរស់នៅកន្លែងផ្សេងគ្នា ។

លើសពីនេះក៏នៅមានកំហុសផ្សេងៗទៀតដែរនៅក្នុងគម្រោងស្រាវជ្រាវនេះ ។ ឧទាហរណ៍បន្ថែមទៅលើការសិក្សាស្រាវជ្រាវអ្នកដើរសុើបសួររបស់គណៈកម្មការ ថែមទាំងបានចំណាយពេលវេលាសំខាន់មួយផ្នែកក្នុងការប្រឹងប្រែងពិនិត្យផ្ទាល់ទៅលើរណ្តៅសាកសពដែលនៅសេសសល់ពីជំនាន់ខ្មែរក្រហមកាន់កាប់ ។ គណៈកម្មការភាគច្រើន បានធ្វើការជីករណ្តៅសាកសពរួមដែលត្រូវបានរកឃើញនៅតាមកន្លែងផ្សេងៗដែលជាការបង្ហាញពីចំនួនមនុស្សស្លាប់នៅតាមរណ្តៅតូចធំដែលត្រូវបានជីកគាស់ ។ ចំនួននេះត្រូវបានបញ្ចូលបន្ថែមទៅលើចំនួនដែលបានមកពីការសម្ភាសជាហេតុនាំឲ្យមានចំនួនមនុស្សស្លាប់ទៅដល់៣លានបីសែននាក់បែបនេះ ។ ប៉ុន្តែវាជាការពិបាក ប្រសិនបើមិនអាចទៅរួចក្នុងការបញ្ជាក់ច្បាស់អំពីករណីទាំងនេះដែលថាបុគ្គលម្នាក់ៗដែលត្រូវបានរាយការណ៍ថាស្លាប់ គឺជាបុគ្គលតែមួយដែលត្រូវបានរកឃើញតាមរយៈការជីកគាស់រណ្តៅសាកសព ។

មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការសន្និដ្ឋានជាបន្តបន្ទាប់ថា តួលេខបីលានបីសែនដែលរាយការណ៍ដោយគណៈកម្មការស្រាវជ្រាវរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាអាចជាចំនួនរាប់លើសដល់ទៅ៥០ភាគរយ ហើយបញ្ជាក់ថា ចំនួនមនុស្សស្លាប់ពិតប្រាកដនៅកន្លែងនានាមានជិត ១លាន ៧ សែននាក់ ។ ក៏ប៉ុន្តែទោះបីជាមានកំហុសជាក់ស្តែងខាងវិធីសាស្ត្រស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏ការងារស្រាវជ្រាវដោយគណៈកម្មការនេះអាចផ្តល់ជាជំនួយបង្ហាញផ្លូវដល់អ្នកសុើបសួរពត៌មានក្រោយៗទៀត

ដែរ ។ ឧទាហរណ៍ កិច្ចសម្ភាសន៍ធ្វើឡើងដោយគណៈកម្មការស្រាវជ្រាវមានលក្ខណៈលម្អិតទាក់ទងដល់ព្រឹត្តការណ៍ផ្សេងៗនៅផ្នែកមួយចំនួនរបស់ប្រទេសកម្ពុជា និងមានបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកធ្វើការនៅក្នុងខ្សែសង្វាក់បញ្ជាថ្នាក់ក្រោមរបស់ខ្មែរក្រហម ។ ការងារមួយចំណែកទៀតដែលគួរឲ្យចាប់អារម្មណ៍ដែរគឺការប្រមូលញត្តិរបស់ «ប្រជាជន» ផ្ញើជូនអង្គការសហប្រជាជាតិទាមទារឲ្យនាំយកមេដឹកនាំនៃរបបខ្មែរក្រហមមកកាត់ទោសនៅចំពោះមុខជនរងគ្រោះដែលខ្លួនបានប្រព្រឹត្តមកលើ ។ ហត្ថលេខា (ឬស្នាមមេដៃ) ជាងមួយលានត្រូវបានប្រមូលមកពីកន្លែងផ្សេងៗនៅទូទាំងប្រទេសដើម្បីធ្វើជាញត្តិ ហើយទោះបីជាញត្តិជាច្រើនជាសំណេរដែលមានតួលេខធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចនៃរបបថ្មីយ៉ាងណាក៏ដោយ ក៏បណ្ណសារទាំងនេះរួមមានពត៌មានលម្អិតជាច្រើនស្តីអំពីអំពើឃោរឃៅដែលប្រព្រឹត្តទៅលើប្រជាជនកម្ពុជានៅទូទាំងប្រទេស ។ ឯកសារទាំងអស់នេះ ឬអ្វីដែលនៅសេសសល់ គឺជាកម្មសិទ្ធិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

## វិធីសាស្ត្រថ្មី

ចាប់តាំងពីឆ្នាំ១៩៩៥ អ្នកសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានបន្តសិក្សាយ៉ាងស្ញៀមស្ញាត់និងជាលក្ខណៈប្រព័ន្ធទៅលើរឿងអាថ៌កំបាំងនៃ «រង្វាស់» នេះ ។ កិច្ចខិតខំប្រឹងប្រែងនេះបានប្រើប្រាស់នូវវិធីសាស្ត្រថ្មីមួយទៀតហៅថា «ការសិក្សាស្រាវជ្រាវអំពីរណ្តៅសាកសពរួម» ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែដំណើរការស្វែងរកទីតាំងនិងធ្វើផែនទីលើរណ្តៅសាកសពនីមួយៗនៅក្នុងប្រទេសកម្ពុជា ។ វិធីសាស្ត្រប្រើនៅក្នុងគម្រោងការធ្វើផែនទីគឺជាការផ្គួបផ្សំគ្នារវាងបច្ចេកវិទ្យាខ្ពស់ៗដូចជាការធ្វើផែនទីតាមរយៈផ្កាយរណបជាដើមនិងការងារចុះស្រាវជ្រាវផ្ទាល់តាមភូមិស្រុកដែលជាវិធីចាស់បន្តិចទៅហើយ ដូចជាអ្នកស៊ើបសួរពត៌មានដែលដើរកាត់គ្រប់ទីតាំងនៅទូទាំងជនបទនៃប្រទេសកម្ពុជាពីភូមិមួយទៅភូមិមួយដើម្បីស្វែងរកវាលពិឃាត ។ ដោយមានការជួយជ្រោមជ្រែងពីសំណាក់អ្នកផ្តល់ពត៌មាន ក្រុមចុះធ្វើផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញកន្លែងកប់ខ្មោចជាក់ស្តែងនៅគ្រប់ស្រុកដែលក្រុមស្រាវជ្រាវផ្នែកផែនទីនេះបានទៅដល់ ។

នៅស្ទើរគ្រប់ទីតាំងសម្លាប់ទាំងអស់ ក្រុមផែនទីបានរកឃើញនិងធ្វើសម្ភាសន៍សាក្សីនៅតាមមូលដ្ឋានដែលអះអាងថាខ្លួននៅចាំបាននូវប្រភេទជនរងគ្រោះ នៅក្នុងរណ្តៅសាកសពនីមួយៗ ។ នៅពេលដែលក្រុមផែនទីទៅដល់ទីតាំងគុក ឬមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ក្រុមនេះតែងតែប្រើម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រដើម្បីកំណត់ទីតាំងនីមួយៗ ។ ឧបករណ៍អេឡិចត្រូនិកកំណត់ទីតាំងភូមិសាស្ត្រ ដែលប្រើដោយមជ្ឈមណ្ឌលឯកសារកម្ពុជាអាចកត់ត្រានូវទីកន្លែងផ្សេងៗដែលខុសត្រូវគ្នាយ៉ាងច្រើនពីរបីម៉ែត្រប៉ុណ្ណោះ ។ ពត៌មានដែលថតបានត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធផ្ទុកពត៌មានភូមិសាស្ត្រដែលអាចបង្កើតជារូបផែនទីទីតាំងសម្លាប់យ៉ាងច្បាស់សម្រាប់ការប្រើប្រាស់ ។

ទោះបីជាការងារនេះមិនទាន់បានបញ្ចប់សព្វគ្រប់យ៉ាងណាក៏ដោយ ប៉ុន្តែលទ្ធផលមកដល់ឥឡូវនេះគួរឲ្យភ្ញាក់ផ្អើល ។ រហូតមកដល់ពេលនេះមានរណ្តៅសាកសពចំនួន ២០ ៤៩២ (ពីរម៉ឺនបួនរយកៅសិបពីរ) បន្សល់ទុកដោយរបបខ្មែរក្រហមនៅទូទាំងប្រទេសកម្ពុជាត្រូវបានរកឃើញនិងសិក្សា ។ យោងតាមទិន្នន័យនេះ រណ្តៅ



សាកសពទាំងអស់មានជនរងគ្រោះស្លាប់អស់ ១ ១១២ ៨២៩ (មួយលានមួយសែនមួយម៉ឺនពីរពាន់ប្រាំបីរយម្ភៃប្រាំបួននាក់) ។

ឥឡូវយើងនាំគ្នាពិនិត្យឲ្យកាន់តែច្បាស់ទៅលើចំនួននេះ ។ ក្នុងចន្លោះឆ្នាំ១៩៩៥ ដល់ចុងឆ្នាំ១៩៩៩ ក្រុមដែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅដល់ខេត្តចំនួន២០ក្នុងចំណោមខេត្តក្រុងទាំង២១របស់ប្រទេសកម្ពុជា ។ នៅក្នុងចំណោមស្រុកទាំង១៧០របស់កម្ពុជា ក្រុមដែនទីបានទៅដល់ស្រុកយ៉ាងហោចណាស់ចំនួន១៥០ស្រុក ។ នៅក្នុងដំណើរការងារនេះ យើងបានចុះស្រាវជ្រាវនៅក្នុងស្រុកចំនួនជាង២ភាគ៣នៃស្រុករបស់ប្រទេសកម្ពុជា ។ ស្រុកជាច្រើននៅក្នុងភូមិភាគខត្តរនិងពាយ័ព្យមិនទាន់ត្រូវបានចុះទៅពិនិត្យឲ្យបានហ្មត់ចត់នៅឡើយទេ ដោយសារមានបញ្ហាអសន្តិសុខ(ចម្ការមីន) ។ ក្រុមដែនទីមិនទាន់បានចុះទៅសិក្សានៅខេត្តព្រះវិហារនៅឡើយទេ ។ មានខ្មែរក្រហមមួយចំនួននៅតែមានការប្រឆាំងប្រដាប់អាវុធនៅក្នុងតំបន់ទាំងនេះនៅឡើយ រហូតដល់ដើមឆ្នាំ១៩៩៩ទើបស្ងប់ស្ងាត់ ។ ហើយទោះបីជាការវាយប្រហារប្រដាប់អាវុធត្រូវបានបញ្ចប់តាំងពីពេលនោះក៏ដោយ ប៉ុន្តែប្រជាជនមូលដ្ឋាននៅតែរស់នៅទីនោះ ហើយបំពាក់ទៅដោយអាវុធយ៉ាងព្រោងព្រាតទៀតផង ។

ដោយសារតែភ័ស្តុតាងជាក់ស្តែងដែលនាំទៅដល់ការសង្ស័យថាខេត្តនៅតាមភូមិភាគពាយ័ព្យដូចជាខេត្តបាត់ដំបងនិងបន្ទាយមានជ័យមានការសម្លាប់មនុស្សយ៉ាងច្រើននៅក្នុងអំឡុងពេលដែលខ្មែរក្រហមកាន់កាប់នោះ ចំនួនប៉ាន់ស្មានត្រូវបានរំពឹងទុកថាមានការកើនឡើងយ៉ាងខ្លាំង នៅពេលដែលការសិក្សាស្រាវជ្រាវធ្វើដែនទីត្រូវបានបញ្ចប់ ។ ដូច្នេះចំនួនជនរងគ្រោះដែលស្លាប់និងរកឃើញនៅក្នុងរណ្តៅសាកសពអាចកើនឡើងកាន់តែខ្ពស់ អាចទៅដល់១លាន៥សែននាក់ ។

រណ្តៅសាកសពរួមជាងពីរម៉ឺនដែលមកដល់ពេលនេះត្រូវបានធ្វើដែនទីរួចហើយគឺស្ថិតនៅមន្ទីរសន្តិសុខឬកន្លែងក្បែរៗនោះ ។ សាក្សីឃើញហេតុការណ៍ផ្ទាល់នឹងភ្នែកនៅឯរណ្តៅសាកសពភាគច្រើនស្ទើរតែទាំងអស់បញ្ជាក់ថារណ្តៅសាកសពរួមមានផ្ទុកជនរងគ្រោះដែលត្រូវបានសន្តិសុខខ្មែរក្រហមនាំយកមកសម្លាប់ ហើយថាជនរងគ្រោះត្រូវបានសម្លាប់នៅកន្លែងជាប់នឹងគុកឬនៅកន្លែងរណ្តៅតែម្តង ។ ដូច្នេះអាចសន្និដ្ឋានថារណ្តៅសាកសពផ្ទុកទៅដោយជនរងគ្រោះដែលសម្លាប់ដោយកម្មាភិបាលខ្មែរក្រហម ។

តារាងទី១ (តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា) បង្ហាញថាក្រុមធ្វើដែនទីបានចុះពិនិត្យដល់ «ទីតាំងប្រល័យពូជសាសន៍» សរុបចំនួន៤៣២កន្លែង ដែលរួមមានទីតាំងគុក រណ្តៅសាកសពរួម និងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុ ។ ទីតាំងទាំងអស់មានប្រភេទ និងទំហំខុសៗគ្នា ដូចជារណ្តៅធម្មតារណ្តៅដី និងប្រភេទផ្សេងៗទៀតដែលមិនមានលក្ខណៈធម្មតាដូចជាអណ្តូងទឹក រូងភ្នំ ឡ និងដីវាលស្រែធម្មតា ។ តារាងទីពីរ (តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា) បង្ហាញថា ជាមធ្យមមានជនរងគ្រោះចំនួន១៦៩នាក់ក្នុងមួយរណ្តៅ ។ ប្រសិនបើយើងមិនរាប់បញ្ចូលខេត្តក្រចេះដែលមានទិន្នន័យចម្លែកពីខេត្តផ្សេងៗ តួលេខនេះនឹងថយទៅតាមលំដាប់ដែរ គឺប្រហែលនៅសល់ត្រឹម៩៧នាក់ប៉ុណ្ណោះក្នុងមួយរណ្តៅ ។ ប៉ុន្តែស្ថិតិនេះគឺមិនទាន់ត្រឹមត្រូវទាំងអស់ទេដោយហេតុថារណ្តៅសាកសពមាន «ទម្រង់» ខុសៗគ្នា ។ មានរណ្តៅសាកសពតូចៗជាច្រើន ហើយក្នុងរណ្តៅនីមួយៗមានជនរងគ្រោះស្លាប់ប្រហែល ៥នាក់ ដែលភាគច្រើនជាសមាជិកគ្រួសារទាំងមូលដែលមានសមាជិកតិចរួមដូចជា ប្រពន្ធ ប្តី និងកូនពីរឬបីនាក់ ។ ក្រុមដែនទីនៅបានរកឃើញទម្រង់រណ្តៅធំជាងនេះជាច្រើនទៀតដែលរណ្តៅនីមួយៗផ្ទុកជនរងគ្រោះចាប់ពី១០០នាក់ទៅរាប់រយនាក់ ។ កសិណសាក្សីបង្ហាញថា រណ្តៅសាសពប្រភេទនេះត្រូវបង្កើតឡើងភាគច្រើននៅពេលដែលមន្ទីរសន្តិសុខបញ្ចេញអ្នកទោសយកទៅសម្លាប់ដើម្បីដាក់អ្នកទោសមួយក្រុមផ្សេងទៀត ។ ហើយប្រភេទរណ្តៅសាកសពទីបីគឺរណ្តៅសាកសពរួមខ្នាតធំដែលអាចផ្ទុកជនរងគ្រោះរហូតដល់រាប់ពាន់នាក់ ។ រណ្តៅសាកសពដែលមានសណ្ឋានបែបនេះ ហាក់ដូចជាមានលក្ខណៈទូទៅទៅហើយនៅតាមខេត្តមួយចំនួនដូចជាខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តកំពង់ចាមនិងតាមកន្លែងផ្សេងៗទៀតនៅទូទាំងប្រទេស ។ រណ្តៅសាកសពប្រភេទនេះមានការទាក់ទងគ្នាជាមួយនឹងការបោសសម្អាតដោយមិនរើសមុខដែលមានទ្រង់ទ្រាយធំ ដូចជាករណីដែលមានបញ្ជាថាត្រូវសម្លាប់ប្រជាជនក្នុងស្រុកមួយឲ្យអស់ ។ **(នៅមានត)**

**របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា**

# គំរូមួយនៃភស្តុតាងឯកសារដែលភ្ជាប់មេដឹកនាំថ្នាក់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (តចប់)

ទាំង នួន និង វ៉ាន់ សុទ្ធតែបានទទួលនូវឯកសារចម្លង ដែលចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ ផ្ញើមកពីគណៈកងពលមជ្ឈិមលេខ២៦០ ដែលស្នើថា «បក្សថាបញ្ហាគោក្របី និងជ្រូកមាន់ នៅតំបន់ឲ្យយកទៅក្រោយច្រើនដងណាស់តែគេមិនតាម ឥឡូវយួនយកអស់ជាង៩៥ភាគរយហើយ សូមបក្សជួយមានវិធានការ» ។ មួយសប្តាហ៍ក្រោយមក លេខាភូមិភាគឧត្តរឈ្មោះ វី បានរាយការណ៍ថា «ការកសាងកម្លាំងបានសម្រិតសម្រាំង ។ សមាសភាពមួយចំនួនកាន់តែស្វាត់ អាខ្លះបញ្ចេញបានត្រូវឯកោ និងសម្អាត» ។ ទូរលេខមួយទៀតផ្ញើមកក្រោយពីរថ្ងៃមកពីភូមិភាគបស្ចិមបានរាយការណ៍ទាក់ទងនឹង «បញ្ហាសភាពការណ៍ផ្ទៃក្នុងបក្សគឺមានសមមិត្ត សុទ្ធ ប្រធានរោងចក្រជួសជុល បានប៉ះពាល់សីលធម៌ជាមួយនារី ឥឡូវនេះគឺបានចាប់ហើយ គឺចាប់ទាំងបុរសទាំងនារី មិត្តនេះកាលមុនមានជាប់ចម្លើយពួកអាក្បត់ អាជួន» ។ ទូរលេខបានបញ្ចប់សេចក្តី «ឯបញ្ហានេះសូមជួយយោបល់ ត្រូវទុកដាក់កម្រិតណា ឬក៏ឲ្យជូនទៅណោះ» ។

ក្រោយពីមានជម្លោះប្រដាប់អាវុធយ៉ាងធ្ងន់ធ្ងរនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម នៅក្នុងឆ្នាំ១៩៧៧ នួន និង វ៉ាន់ ត្រូវបានចម្លងឯកសារជូន ។ ឯកសារនោះគឺនិយាយអំពីរបាយការណ៍ពីសមរភូមិមុខដែលចេះតែកើនឡើងដែលពាក់ព័ន្ធនឹងការប្រមូលជនស៊ីវិលវៀតណាមនិងយុទ្ធជនវៀតណាមដែលត្រូវបានចាប់ជាឈ្លើយ និងពិភាក្សាអំពីការវាយប្រហារទៅលើជនស៊ីវិលវៀតណាម ។ ទូរលេខចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៧ ផ្ញើមកពីភូមិភាគបូព៌ាជូនចំពោះមន្ទីរ៨៧០ បានស្នើសុំ «មតិរបស់ ម.៨៧០ ពីបញ្ហាយួនដែលយើងចាប់បាននៅភូមិតាដេវ លើផ្ទះប្រជាជននោះ បើ ម.៨៧០ ត្រូវការយើងខ្ញុំនឹងផ្ញើមកជូន បច្ចុប្បន្នយើងរក្សាទុកកំពុងសួរចម្លើយ» ។ ទូរលេខមួយទៀត ផ្ញើមកពីភូមិភាគបូព៌ាចុះថ្ងៃទី១៨ ខែវិច្ឆិកា បានរាយការណ៍អំពីការវាយប្រហារមុខព្រួញផ្សារទ្រៀងក្នុងទឹកដីវៀតណាម ដែលនៅក្នុងអំឡុងពេលវាយប្រហារនោះកងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ «បានដុតផ្ទះសម្បែងនិងជង្រុំខ្ទាំងអស់៩៨ខ្នង ហើយព្រមទាំងកម្ទេចសម្អាតខ្ទាំងអស់ពីផ្សារចាប់ពីភាគខាងជើងមក» ។ ទោះបីជាសារបញ្ជាក់ថា «លទ្ធផលសម្លាប់និងរឹបអូសយកជយភណ្ឌក្តាប់មិនបាន» យ៉ាងណាក៏ដោយ ក៏ទូរលេខមួយចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ផ្ញើមកពី សុន សេន បានរាយការណ៍អំពីការចាប់ជនជាតិវៀតណាមបាន «បីក្បាល» ដែលក្នុងនោះមានពីរនាក់ត្រូវបានបាញ់ចោលនៅពេលព្យាយាមរត់គេចខ្លួន ហើយម្នាក់ទៀតត្រូវបានបញ្ជូនមកកាន់ ស-២១ ពោលគឺប្រហែលជា «មន្ទីរស-២១» ។ របាយការណ៍សង្ខេបផ្ញើមកពីលេខាកងពល១៦៤ ឈ្មោះ មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ បានបញ្ជាក់ថា «ចំនួនយួនដែលខ្លួនបានចាប់ ហើយបាញ់សម្លាប់ចាប់តាំងពីថ្ងៃ២៧ ខែមីនា ឆ្នាំ១៩៧៨ មកដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៨ គឺមាន ១២០ក្បាល» ។

នួន និង វ៉ាន់ ត្រូវបានចម្លងជូននូវរបាយការណ៍ដូចគ្នាស្តីអំពីការចាប់ខ្លួនជនជាតិថៃកំពុងតែនេសាទត្រី និងកាណូតមួយចំនួនទៀតនៅក្នុងសមុទ្រថៃ ។ ឧទាហរណ៍នៅថ្ងៃទី៣១ ខែមីនា លេខាកងពលភូមិភាគបស្ចិមឈ្មោះ សៀង (ដែលក្រោយមកត្រូវបានបោសសម្អាតនិងសម្លាប់ចោល) បានរាយការណ៍ថាចាប់បានជនជាតិថៃមួយនាក់ដែរ ។

មិនតែប៉ុណ្ណោះចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៧ នួន និងវ៉ាន់ ត្រូវបានចម្លងជូននូវទូរលេខផ្សេងៗផ្ញើមកពីឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសវៀតណាម ឈ្មោះ សុខ ឈាន (ក្រោយមកត្រូវបានបោសសម្អាតនិងសម្លាប់ចោល) ដែលរាយការណ៍ថានៅតែមានជនជាតិវៀតណាមតវ៉ាប្រឆាំងនឹងអំពើឃោរឃៅរបស់កម្ពុជាប្រជាធិបតេយ្យនៅតាមព្រំដែនកម្ពុជា-វៀតណាម ។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ឈាន បានរំឭកដល់ទស្សនកិច្ចរបស់មន្ត្រីវៀតណាមដែលបានប្តឹងអំពីការវាយប្រហាររបស់

កងកម្លាំងកម្ពុជាប្រជាធិបតេយ្យនាថ្ងៃទី១៤ ខែមិថុនា ដោយបានរាយការណ៍ថា មន្ត្រីរូបនោះនិយាយអំពីការវាយប្រហារនោះមានការ «កាប់សម្លាប់» ជនជាតិវៀតណាមនិង «ដុតផ្ទះសម្បែង» ព្រមទាំងបណ្តាលឲ្យមានការខូចខាតយ៉ាងដំណំទៀតផង» ។ មន្ត្រីនោះបញ្ជាក់ទៀតថា «ការដែលថាកងទ័ពកម្ពុជារំលោភខុសច្បាប់ទាំងនេះមិនមែនខាងវៀតណាមចេះតែ «និយាយតាមរបាយការណ៍នោះទេ ប៉ុន្តែវាជាភ័ស្តុតាងជាក់ស្តែងដែលមិនអាចប្រកែកបាន ហើយសុំឲ្យថតរូបទុកជាភ័ស្តុតាង» ។

នៅថ្ងៃទី១៤ ខែសីហា ឈាន បានរាយការណ៍អំពីការចោទប្រកាន់មួយចំនួនលេចឮនៅមជ្ឈដ្ឋានទីក្រុងហាណូយថា «កងទ័ពកម្ពុជាសម្លាប់រង្គាលអស់ប្រជាជនវៀតណាមចំនួន ១ ០០០នាក់ (មួយពាន់នាក់) នៅ ហា ជៀន ខេត្ត គៀនយ៉ាង» ។ នៅចុង ខែសីហា ឈាន បានលើកឡើងអំពីការតវ៉ាមួយទៀតរបស់មន្ត្រីវៀតណាមដែលចោទថាមាន «ប្រជាជនសាមញ្ញ» ១០នាក់ផ្សេងទៀតត្រូវបានសម្លាប់នៅក្នុងការវាយប្រហារក្រោយទៀត ។

នៅខែមីនា ឆ្នាំ១៩៧៨ មន្ត្រីជាន់ខ្ពស់នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវកំពុងចាប់ផ្តើមតវ៉ាជាលក្ខណៈឯកជនចំពោះការគំរាមថាសម្លាប់ប្រជាជនសាមញ្ញឡាវ នៅតាមបណ្តោយព្រំដែនឡាវ-កម្ពុជា ហើយករណីនេះក៏ត្រូវបានរាយការណ៍ដល់ទីក្រុងភ្នំពេញដែរ ។ ទូរលេខមួយផ្ញើមកពីឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យឈ្មោះ សន សំ ហៅ រដ្ឋ ទៅកាន់ «បងជាទីគោរពស្នេហា» និងចម្លងជូន នួន និង វ៉ាន់ បានរាយការណ៍អំពីការជិតាស់របស់មន្ត្រីជាន់ខ្ពស់ឡាវដែលថាកងទ័ពកម្ពុជាប្រជាធិបតេយ្យបាន «ប្រកាសហាមមិនឲ្យប្រជាជនប្រើប្រាស់ទឹកក្នុងអូរឡាំដៅ បើហ៊ានចុះដងទឹកនឹងត្រូវបាញ់សម្លាប់ចោលតែម្តង» ។

ទន្ទឹមគ្នានេះដែរ នៅចុងខែមករា ឆ្នាំ១៩៧៨ សារមកពីភូមិភាគបូព៌ាដែលត្រូវបានចម្លងជូន នួន និង វ៉ាន់ បានរាយការណ៍ទាំងការវាយប្រហារនៅសមរភូមិនិងការបោសសម្អាតផ្ទៃក្នុង ។ សាររបស់បក្សកុម្មុយនិស្តកម្ពុជាទាំងនេះហាក់ដូចជាត្រូវគ្នាទៅនឹងគម្រោងចោទប្រកាន់ធំៗជាផ្លូវការរបស់វៀតណាមដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈរួចមកហើយ ។ ឧទាហរណ៍ទូរលេខចុះថ្ងៃទី១៩ ខែមករា និយាយថា ក្នុងអំឡុងពេលវាយប្រហារចូលទៅក្នុងទឹកដីវៀតណាមពីរគីឡូម៉ែត្រ កម្លាំង «យើងកម្ទេចផ្ទះយោធាខ្មាំងចំនួន៣០ខ្នង ដុតផ្ទះប្រជាជនមួយចំនួនទៀត ។ យើងកម្ទេចកាណូតខ្មាំងបានពីរគ្រឿង ក្នុងកាណូតនេះគឺសុទ្ធតែប្រជាជនវាទៅ ធ្វើឲ្យប្រជាជនវានៅក្នុងកាណូតខ្ទេចខ្ទីអស់ ។ សរុប យើងកម្ទេចខ្មាំងនៅថ្ងៃទី១៨ ខែមករា នេះបាន៣០ក្បាល ។ យើងបាញ់កាំជ្រួច១០៧ ចូលផ្សារហុកងឺ លទ្ធផលយើងក្តាប់មិនបានតែឃើញឆេះ ។ ចំពោះការរៀបរយប្រជាជនដែលអាខ្មាំងយួនវាកៀរទៅគ្រប់គ្រងបណ្តោះអាសន្ន និងមួយ



ខៀវ សំផន អៀង សារី



នួន ជា

ចំនួនតិចជឿតាមយួន ត្រូវយើងប្រមូលបានវិញមួយភាគធំ បច្ចុប្បន្នយើងរៀបចំយកមកក្រោយអស់ អប់រំ និងបែងចែក សម្រិតសម្រាំង» ។ ទូរលេខក្រោយមួយទៀតផ្ញើមកពីភូមិភាគបូព៌ាបានពន្យល់ថា «សភាពការណ៍ប្រជាជនបានរៀបរយ ប្រជាជនដែលនៅក្បែរព្រំដែនឲ្យថយមកស្នាក់នៅខាងក្រោយអស់ហើយ ហើយប្រជុំរៀនសូត្រអប់រំជាប់ ម្យ៉ាងសម្រិតសម្រាំងសមាសភាពខ្សែខ្មាំងយួនមិនឲ្យនៅប្របូកប្របល់នឹងប្រជាជនល្អទេ តាមដានអប់រំដោយឡែក» ។

សារមួយទៀតចុះថ្ងៃទី២០ ខែមេសា បានរាយការណ៍ថា ការវាយប្រហាររបស់វៀតណាមហាក់ដូចជាផ្តោតសំខាន់ទៅលើកម្លាំងមួយចំនួននៅភូមិភាគបូព៌ាដែល «អា» កម្មាភិបាលដឹកនាំបានប្រាប់ការណ៍សម្ងាត់ទៅឲ្យវៀតណាម ហើយថា «កំពុងតែមានការចាត់វិធានការចំពោះអ្នកសមាសភាពមិនល្អនៅក្នុងចំណោមពួកទាំងនេះនៅក្នុងកងកម្លាំងតំបន់» ។

សារមួយចំនួនទៀតត្រូវបានចម្លងជូនចំពោះ នួន តែប៉ុណ្ណោះ ហើយមិនបានជូនដល់ វ៉ាន់ ទេ ។ ឧទាហរណ៍ជាក់ស្តែងគឺទូរលេខចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៨ ដែលប្រាកដជាផ្ញើមកពី សុន សេន បានរាយការណ៍អំពីការចាប់ខ្លួនជនជាតិវៀតណាមពីរនាក់ ដោយគណៈកងពល១៨០ ។ លេខាកងពលឈ្មោះ សម ហួយ ហៅ មាស តាល់ (ក្រោយមកត្រូវបានបោសសម្អាតនិងសម្លាប់) ត្រូវបានណែនាំឲ្យបញ្ជូនអ្នកទោសទៅកាន់មន្ទីរស-២១ ។ សារមួយទៀតចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨ មកពីលេខាភូមិភាគកណ្តាលឈ្មោះ ពក បានរាយការណ៍អំពីការឃាត់ខ្លួនយុទ្ធជនពីរនាក់ដោយយោធាតំបន់៤១ ។ យុទ្ធជនពីរនាក់នោះនិយាយថាខ្លួនជាយុទ្ធជននៅគណៈកងពលមជ្ឈិមលេខ៥០២ ។ នៅក្នុងសារដដែលនេះ ពក បានស្នើអង្គការសាកសួរពិនិត្យប្រវត្តិអ្នកទោសពីរនាក់នេះ ជាមួយនឹងលេខាកងពល៥០២ ឈ្មោះ ម៉េត ហើយសូមតបដំណឹង ។

មានឯកសារមួយចំនួនទៀតត្រូវបានចម្លងជូន អៀង សារី ប៉ុន្តែមិនជូនដល់ នួន ទេ ។ ឧទាហរណ៍ជាក់ស្តែង ទូរលេខចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៨ ដែលច្បាស់ជាផ្ញើមកពី សុន សេន រាយការណ៍ថាលេខាគណៈកលពលមជ្ឈិមលេខ៧០៣ឈ្មោះ ពីន (ដែលក្រោយមកត្រូវបានសម្អាតនិងសម្លាប់) ត្រូវគ្រោះថ្នាក់ដោយខ្មាំងផ្ទៃក្នុង ។ ឡានគាត់ជាន់មីនរថក្រោះដែលខ្មាំងដាក់ ។ ជាលទ្ធផល កិច្ចប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បី «ពិនិត្យស្រាវជ្រាវរកខ្មាំងផ្ទៃក្នុងដើម្បីមានវិធានការបន្តបន្ទាប់និងមានវិធានការប្រុងប្រយ័ត្នបដិវត្តឲ្យហ្មត់ចត់ថែមទៀតក្នុងការចេញចូលនិងដើរចុះឡើងធ្វើការ» ។ សារមួយទៀតផ្ញើមកនៅថ្ងៃតែមួយបានរាយការណ៍ថាកងទ័ពកម្ពុជាប្រជាធិបតេយ្យបាន «វាយចូលទីប្រជុំជនដុងថាប់ និងផ្សារខាងត្បូងត្រពាំងព្រាហ្មណ៍ និង គីងចូវ ធ្វើឲ្យវាងាប់និងរបួសជាច្រើនរយក្បាល និងឆេះផ្ទះរាប់រយខ្នង» ។ ទូរលេខនេះក៏បានរាយការណ៍ដែរថា កងទ័ពកម្ពុជាប្រជាធិបតេយ្យ «កំពុងតែបន្តបាញ់វាទៀតដោយ១០៧ និងដេកា៧៥ ចូលគីងចូវ» ។ សារនេះដែលត្រូវបានចម្លងជូនវ៉ាន់បន្ថែមទៀតថា «សភាពការណ៍ខាងមូលដ្ឋានយើងបន្តសម្រិតសម្រាំងជាបន្តបន្ទាប់ទៀត» ។ **ចប់**

**ស៊ីវ ហេង៉រ**

# ការរើសអើងប្រឆាំងនឹងជនជាតិភាគតិច និងការធ្វើទុក្ខបុកម្នេញលើសាសនា

## ក) ការរើសអើង

សិទ្ធិទាំងឡាយដែលចែងនៅក្នុងសេចក្តីប្រកាសសកលស្តីអំពីសិទ្ធិមនុស្សសំខាន់បំផុតក្នុងចំណោមសិទ្ធិទាំងនោះគឺសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលការការពារប្រឆាំងនឹងទាសភាព ការធ្វើទារុណកម្ម និងការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្សនិងសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ពុំអាចត្រូវបានរំលោភបំពានដោយឈរលើមូលដ្ឋានថាអ្នកនោះជាជនជាតិភាគតិច ឬជាក្រុមសាសនាឡើយ ។ មាត្រា១ នៃសេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្សចែងថា “មនុស្សគ្រប់រូបកើតមកមានសិទ្ធិសេរីភាពនិងសមភាពក្នុងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ” មាត្រា២ចែងថា “មនុស្សគ្រប់រូបមានសិទ្ធិទទួលនូវសិទ្ធិទាំងឡាយនិងសេរីភាពដែលបានចែងក្នុងសេចក្តីប្រកាសនេះ ដោយពុំមានការបែងចែកឬរើសអើងចំពោះពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬទស្សនៈដទៃទៀត ប្រជាជាតិ ឬដើមកំណើតសង្គម ទ្រព្យសម្បត្តិ កំណើត ឬឋានៈក្នុងសង្គមដទៃទៀតឡើយ” ។

មាត្រា១នៃអនុសញ្ញាអន្តរជាតិស្តីអំពីការលុបបំបាត់ចោលគ្រប់ទ្រង់ទ្រាយនៃអំពើរើសអើងប្រកាន់ពូជសាសន៍ឆ្នាំ១៩៦៦ អនុសញ្ញាស្តីអំពីការរើសអើងប្រកាន់ពូជសាសន៍ថាជា “ការបែងចែកឲ្យដាច់ពីគ្នាការបដិសេធ ការរឹតត្បិត ឬសេចក្តីស្រឡាញ់ចូលចិត្តដោយផ្អែកលើជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើត ឬសញ្ជាតិ ឬកំណើតជាជនជាតិភាគតិចដែលមានគោលបំណង ឬឥទ្ធិពលនៃការលុបបំបាត់ចោល ឬធ្វើឲ្យមានមហន្តរាយដល់ការទទួលស្គាល់ ការទទួលបាន ឬការអនុវត្តលើភាពស្មើគ្នា ការអនុវត្តនៃជំនួយមនុស្សធម៌និងសេរីភាពជាមូលដ្ឋានក្នុងវិស័យ នយោបាយ សេដ្ឋកិច្ចសង្គម វប្បធម៌ឬវិស័យផ្សេងៗទៀតនៃជីវិតសាធារណៈ” ។ និយមន័យនេះអាចត្រូវបានអនុវត្តប្រហាក់ប្រហែលគ្នាទៅនឹងទ្រង់ទ្រាយផ្សេងទៀតនៃអំពើ





ទិដ្ឋភាពខូចខាតសល់តែផ្ទៃដីនៃវិហារកាតូលិកបារាំងនៅខាងជើងមហាវិទ្យាល័យពេទ្យ

រើសអើង ។ អនុសញ្ញានេះដាក់បន្ទុំឲ្យរដ្ឋាភិបាលអនុវត្តកាតព្វកិច្ចជាវិជ្ជមានមួយដើម្បីលុបបំបាត់ចោលនូវការរើសអើងប្រកាន់ពូជសាសន៍ដោយសាធារណៈនិងដោយបុគ្គល ។ មិនតែប៉ុណ្ណោះ កតិកាសញ្ញានេះតម្រូវឲ្យរដ្ឋាភិបាលទាំងឡាយហាមឃាត់អាជ្ញាធរ ឬស្ថាប័នសាធារណៈកុំឲ្យជំរុញឬញុះញង់ ការរើសអើងប្រកាន់ពូជសាសន៍ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អនុសញ្ញានេះបានធ្វើការបែងចែកមួយដាច់ស្រឡះដោយឈរលើមូលដ្ឋានភាពជាពលរដ្ឋ ហើយអនុញ្ញាតឲ្យភាគីរដ្ឋាភិបាលទាំងឡាយធ្វើការបែងចែក ឬរើសអើងនឹងជនទាំងឡាយណាដែលមិនមែនជាពលរដ្ឋ ។ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីការរើសអើងក្នុងឆ្នាំ១៩៦៦ ហើយបានតម្កល់ភ័ស្តុតាងបញ្ជាក់អំពីការឲ្យសច្ចាប័នជាផ្លូវការរបស់ខ្លួនក្នុងឆ្នាំ១៩៨៣ទៀតផង ។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយសំដៅលើការរើសអើងពីរប្រភេទ គឺការរើសអើងប្រកាន់ជនជាតិភាគតិច និងសាសនា ។ មាត្រា១៨បានបន្ទុំឲ្យអនុវត្តឲ្យខាងតែបាននូវសិទ្ធិដែលពុំអាចធ្វើបដិបញ្ញបាន គឺសិទ្ធិសេរីភាពក្នុងការគិតពិចារណា មនសិការ និងសាសនា ។ មាត្រា២០ បញ្ជាក់ច្បាស់ថា ការគាំទ្រទាំងឡាយចំពោះការស្អប់ខ្ពើម ប្រកាន់ពូជសាសន៍ប្រជាជាតិ ឬសាសនា ដោយមានការញុះញង់ឲ្យមានការរើសអើង ឲ្យមានភាពប្រទូសរ៉ាយឬអំពើហិង្សា ត្រូវហាមឃាត់ដោយច្បាប់ ។ មាត្រា២៦នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបញ្ជាក់ថា “នៅចំពោះមុខច្បាប់ មនុស្សគ្រប់រូបមានសិទ្ធិស្មើៗគ្នា ហើយក៏មានសិទ្ធិទទួលការការពារអំពីច្បាប់ស្មើគ្នាដោយឥតប្រកាន់ពូជសាសន៍ ឬពណ៌សម្បុរឡើយ ។ ក្នុងករណីនេះច្បាប់ហាមមិនឲ្យមានការប្រកាន់ពូជសាសន៍ ហើយច្បាប់ធានាជូនបុគ្គលគ្រប់រូបនូវបញ្ញត្តិការពារយ៉ាងស័ក្តិសិទ្ធិ ភេទ សាសនា ភាសា ជំហរ នយោបាយ ការបញ្ចេញមតិនានា កំណើត ជាតិ ឬសង្គមឋានៈ វណ្ណៈ ឬអ្វីផ្សេងទៀតឡើយ” ។ មាត្រា២៧ ចែងថា “នៅក្នុងសាសនាទាំងឡាយដែលមានជនជាតិភាគតិច មានសាសនាឬភាសារបស់ខ្លួនដោយឡែកសមាជិករបស់ក្រុមនេះមិនត្រូវបានទទួលការបដិសេធនូវសិទ្ធិទំនាក់ទំនងនឹងគ្នានៅក្នុងក្រុមរបស់ខ្លួនសិទ្ធិគោរពវប្បធម៌ ឬប្រើប្រាស់ភាសារបស់ខ្លួនផ្ទាល់ឡើយ” ។

ការហាមឃាត់ប្រឆាំងនឹងអំពីរើសអើងប្រកាន់ពូជសាសន៍ សាសនា វប្បធម៌ និងអំពើរើសអើងទៅលើនារីភេទ ត្រូវបានពង្រឹងថែមទៀតនិងចងក្រងដោយអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់ចោលអំពើរើសអើងប្រកាន់ពូជសាសន៍ សេចក្តីថ្លែងការណ៍ស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សា និងការរើសអើងក្នុងវិស័យសាសនា ឬជំនឿ អនុសញ្ញាស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងអនុសញ្ញាស្តីពីសិទ្ធិនៃកុមារ ។

សូមមើលឧទាហរណ៍លិខិតូបករណ៍ខាងក្រោមនេះ÷

- សេចក្តីប្រកាសស្តីអំពីសិទ្ធិមនុស្ស មាត្រា៧ និង ១៤
- កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា២.២, ១៥.១, ១៥.២ ។

លិខិតូបករណ៍ទាំងនេះបានចែងរួមគ្នាអំពីៈ

១) ការហាមឃាត់អំពើរើសអើង

២) សិទ្ធិជាវិជ្ជមានដើម្បីថែរក្សា និងគោរពវប្បធម៌ជំនឿនិងសាសនារបស់ខ្លួន

៣) កាតព្វកិច្ចរបស់រដ្ឋជាហត្ថលេខីដើម្បីធានាឲ្យបានប្រាកដថាសិទ្ធិទាំងនេះពុំត្រូវបានរំលោភបំពាន ហើយថាមធ្យោបាយទាមទារសំណងដ៏មានប្រសិទ្ធភាពនានាត្រូវបានផ្តល់ឲ្យនៅពេលដែលមានការរំលោភបំពានបែបនេះកើតឡើង ។

អំពើរើសអើងពុំមានលក្ខណៈជាអំពើឧក្រិដ្ឋដែលបុគ្គលម្នាក់ៗត្រូវបានទទួលខុសត្រូវនោះទេ ។ ទោះជាយ៉ាងណាក្តី អំពើរើសអើងអាចជាភ័ស្តុតាងនៃសកម្មភាពនៃការធ្វើទុក្ខបុកម្នេញដែលត្រូវបានរាប់បញ្ចូលនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

អំពើរើសអើងក៏អាចជាភស្តុតាងបញ្ជាក់ពីចេតនាឬការប៉ុនប៉ងដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែរ ។

## ១) ការធ្វើទុក្ខបុកម្នេញ

ការធ្វើទុក្ខបុកម្នេញជាទ្រង់ទ្រាយដ៏ធ្ងន់ធ្ងរនៃអំពើរើសអើង ។ ដោយហេតុនេះការធ្វើទុក្ខបុកម្នេញរំលោភលើ «១» ទាំងឡាយនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលហាមឃាត់អំពើរើសអើង ។ ការធ្វើទុក្ខបុកម្នេញពុំបានហាមឃាត់ឲ្យបានច្បាស់លាស់ឡើយនៅក្រោមមាត្រារួម៣នៃអនុសញ្ញាក្រុងហ្សឺណែវ ។ «ការធ្វើទុក្ខបុកម្នេញដោយមានមូលដ្ឋានលើនយោបាយ ជាតិសាសន៍និងសាសនា» ត្រូវបានហាមឃាត់ក្រោមនិយមន័យទាំង៤នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ «គឺមាត្រា៦នៃតុលាការយោធាអន្តរជាតិនៅនូរិមប៊ឺក ក្រុមប្រឹក្សាត្រួតពិនិត្យច្បាប់លេខ១០ មាត្រា៥នៃលក្ខន្តិកៈតុលាការនៅយូហ្គោស្លាវី និងមាត្រា៣នៃតុលាការរ៉្វាន់ដា ។ ទោះជាយ៉ាងនេះក្តី គ្មាននិយមន័យដែលអាចយកជាការបានចំពោះពាក្យ «ការធ្វើទុក្ខបុកម្នេញ» ដូចនិយមន័យដែលមានខាងលើចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ ។

ជាអប្បបរមា សកម្មភាពនៃការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមានសកម្មភាពទាំងឡាយណាដែលពិតជាធ្វើឲ្យអន្តរាយដល់មូលដ្ឋានជាមនុស្សជាតិរបស់មនុស្សដូចជាការមិនឲ្យក្មេងចូលសាលារៀន ការបង្ខំឲ្យស្លៀកពាក់ផ្សេងពីគ្នា ការហាមឃាត់មិនឲ្យស្លៀកពាក់ផ្សេងពីគ្នា (ឧទាហរណ៍ការបង្ខំឲ្យព្រះសង្ឃដោះស្បង់ចីវរ) ការបិទស្ថាប័នសាសនា និងការរារាំងមេដឹកនាំសាសនា ។

ក្នុងករណីជាច្រើន អំពើទារុណកម្ម អំពើមនុស្សឃាត ការបញ្ជូនខ្លួនមនុស្ស និងសកម្មភាពទាំងឡាយផ្សេងទៀតដែលរួមបញ្ចូលទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចត្រូវបានអនុវត្តឡើងក្នុងរបៀបការធ្វើទុក្ខបុកម្នេញលើក្រុមជាតិសាសន៍ ក្រុមសាសនា និងក្រុមនយោបាយ ។ ទោះជាយ៉ាងណាក្តី អំពើទាំងនោះត្រូវតែបានប្រព្រឹត្តឡើងក្នុងរបៀប «រីករាលដាលឬជាប្រព័ន្ធ» ទើបមានលក្ខណៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ជាឧទាហរណ៍ក្នុងករណីពយ៉ាងដាច់ដោយឡែកពីគ្នា មេដឹកនាំរបបណាហ្ស៊ីត្រូវបានដាក់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំពោះការហូតយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ជនជាតិជ្វីហ្វការរឹបអូសយកទ្រព្យសម្បត្តិដែលបានធ្វើឲ្យប៉ះពាល់ដល់«ជីវិតនិងសេរីភាព» នៃជនជាតិជ្វីហ្វ និងការរឹបអូសយកទ្រព្យសម្បត្តិរបស់អ្នកជាប់ឃុំឃាំងដ៏ច្រើនសន្ធឹកសន្ធាប់ ។ នៅក្នុងការកាត់ក្តីលោក អេចក្មាន់ តុលាការប្រចាំតំបន់របស់អ៊ីស្រាអែលបានសម្រេចថា ការរឹបអូសទ្រព្យសម្បត្តិមានលក្ខណៈជាអំពើអមនុស្សធម៌ ប្រសិនបើបានប្រព្រឹត្តដោយមានការគាបសង្កត់ឲ្យមានការភ័យរន្ធត់ជាខ្លាំងទៅលើជនស៊ីវិល ឬទាក់ទងទៅនឹងសកម្មភាពហិង្សាទាំងឡាយផ្សេងទៀតដែលបានកំណត់ដោយច្បាប់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬក៏ជាលទ្ធផលនៃសកម្មភាពទាំងឡាយនេះ «ដូចជាអំពើមនុស្សឃាត ការចាប់ជម្រិតយកប្រាក់ ការបង្អត់អាហារ ឬការបញ្ជូនខ្លួន» ។ ការធ្វើទុក្ខបុកម្នេញ ប្រសិនបើធ្វើដោយមានចេតនាទៅលើក្រុមដែលទទួលការការពារដើម្បីបំផ្លាញក្រុមនោះចោល អាចជាសកម្មភាពដែលត្រូវបានហាមឃាត់ក្រោមមាត្រា២នៃអនុសញ្ញាក្រុងហ្សឺណែវ ។

**អេលីហ្សាប៊ែត វ៉ាន់ស្កាក់**





# ខៀវ សំផនៈ សង្គមបាក់បែក

***សេចក្តីបន្ថែមទី៩ ទំព័រ៣២៨ៈ ការទាក់ទងជាមួយ ខៀវ សំផន***

***សំណួរៈ*** *មេដឹកនាំខ្មែរក្រហមមិនចង់សារភាពកំហុសរបស់ខ្លួនក្នុងការធ្វើមហាមនុស្សឃាតចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ ។ នៅក្នុងឆ្នាំ១៩៧៩ មេដឹកនាំទាំងនោះទទួលស្គាល់ថាខ្លួនបានប្រព្រឹត្តកំហុសជាច្រើន ប៉ុន្តែគឺជាអ្វីដែលខ្លួនកំពុងតែបដិសេធសព្វថ្ងៃនេះ ។ ឥរិយាបថបែបនេះហាក់ដូចជាមិនធ្វើឲ្យមានការទុកចិត្តចំពោះក្រុមខ្មែរក្រហម ឬមតិអន្តរជាតិឡើយ ។ តើលោកបម្រុងគិតឡើងវិញអំពីអតីតកាល ហើយសារភាពពីភាពដាច់ខាតនៃបដិវត្តន៍របស់លោកដែរឬទេ? ប្រសិនបើនៅតែព្យាយាមបដិសេធថាវាមិនពិត តើលោកមានមធ្យោបាយណាដែលអាចបញ្ជាក់ពីអត្ថិភាពនៃគុកទួលស្លែង (មន្ទីរស-២១) ដែលមានខ្សែរយៈជាប់គ្នាដោយផ្ទាល់ទៅនឹងក្រសួងការបរទេសដែរឬទេ?*

***ចម្លើយៈ*** *(ខៀវ សំផន) មុនដំបូងខ្ញុំសូមរំឭកថា យើងបក្សកុម្មុយនិស្តកម្ពុជា គិតថា ភារកិច្ចរបស់យើងគឺមិនផ្តោតសំខាន់ទៅលើរឿងអតីតកាលនៅក្នុងអំឡុងពេលនៃចលនាតស៊ូប្រឆាំងនឹងពួកឈ្លានពានវៀតណាមដែលមានមកដល់សព្វថ្ងៃនេះទេ ។ មូលហេតុគឺថាដូចលោកដឹងស្រាប់ហើយថា រឿងរ៉ាវពីអតីតកាលបង្កជាបញ្ហាចម្រូងចម្រាសជាច្រើននៅក្នុងខណៈនេះ ដូច្នេះវាសំខាន់ណាស់ ហើយរាល់ការវិភាគទៅលើប្រធានបទ*

នេះមានគ្រោះថ្នាក់ណាស់ចំពោះការពិភាក្សាពិតៗក្នុងក្របខ័ណ្ឌជាតិកម្ពុជានិងសហគមន៍អន្តរជាតិ ដែលអាចមានផលប៉ះពាល់ដល់កិច្ចគាំទ្រពីសំណាក់ជាតិនិងអន្តរជាតិដែលយើងកំពុងតែត្រូវការយ៉ាងខ្លាំងក្នុងចលនាតស៊ូរបស់យើង ។ ដូច្នេះខ្ញុំជឿជាក់ថា ដើម្បីផលប្រយោជន៍របស់ចលនាតស៊ូយើងដែលអាចនិយាយថាជាចលនាមួយក្នុងចំណោមចលនាទាំងអស់នៅក្នុងពិភពលោកដែលឈរខាងសន្តិភាព យុត្តិធម៌ និងការគោរពច្បាប់រវាងរដ្ឋនិងរដ្ឋ យើងគួរតែផ្តោតការយកចិត្តទុកដាក់យកអស់កម្លាំងកាយទៅលើបច្ចុប្បន្នកាលនិងអនាគត ។ ចំពោះអតីតកាលប្រវត្តិសាស្ត្រនឹងបំភ្លឺឲ្យហើយ ពីព្រោះមានតែគិតអំពីពេលវេលាតែប៉ុណ្ណោះទេដែលអាចសន្និដ្ឋានអំពីបរិបទនិងបន្តបន្ទាប់មកទៀតពីសារសំខាន់របស់វា ។

**ទំព័រ៣២៩**

**ចម្លើយៈ** (ខៀវ សំផន) "ចំពោះបញ្ហាដែលលោកសួរទាក់ទងនឹងបច្ចុប្បន្នកាលនិងអនាគតនៃប្រទេសរបស់ខ្ញុំ ខ្ញុំសូមលើកយកចម្លើយទាក់ទងនឹងផ្លូវលោកដើម្បីស្រាយបំភ្លឺចំណុចសំខាន់ៗជាច្រើនដែលអាចជួយឲ្យលោកក្តាប់បានកាន់តែណែនថែមទៀតនូវសារជាតិ បរិបទ និងទំហំនៃការតស៊ូជាតិរបស់យើង...ដំបូងខ្ញុំសូមសង្កត់ធ្ងន់ថា ចំណុចវិជ្ជមាននិងអវិជ្ជមាននៃការប្រព្រឹត្តរបស់មនុស្សគឺមានលក្ខណៈដូចជាកាក់អីចឹង ហើយដូចពាក្យស្លោកពោលថា"អ្នកធ្វើកំហុសគឺមនុស្ស" ។ បញ្ហាសំខាន់គឺត្រូវមើលថា តើកំហុសត្រូវបានធ្វើឡើងដោយចេតនាប្រមួយក៏ជាលទ្ធផលមិននឹកស្មានដល់នៃការខិតខំប្រឹងប្រែងប្រកបដោយសុឆន្ទៈ ។

សរុបមក យើងតែងតែស្មោះត្រង់ចំពោះប្រជាជននិងប្រទេសរបស់យើង ។ យើងតែងតែតស៊ូដើម្បីភាពថ្លៃថ្នូររបស់ជាតិ ។ យើងមិនបានធ្វើឲ្យប្រទេសកម្ពុជាជួបសំណាងអាក្រក់ដូចប្រទេសឡាវដែលសព្វថ្ងៃនេះក្លាយជាទឹកដីពឹងផ្អែកលើប្រទេសវៀតណាមឡើយ ។ ប៉ុន្តែប្រជាជនយើងទូទៅដឹងថា យើងជាអ្នកស្នេហាជាតិដែលលះបង់ចិត្តនិងស្មារតីចំពោះកម្ពុជា...នេះគឺជាគំនិតរបស់ខ្ញុំផ្ទាល់ស្តីអំពីសភាពការណ៍នៅកម្ពុជានិងគំនិតពិចារណាសំខាន់ៗចាំបាច់ផ្សេងទៀតដែលជំរុញឲ្យមាននយោបាយមហាសាមគ្គីជាតិនៅក្នុងបច្ចុប្បន្នកាល និងទៅអនាគត ។ ចំពោះគោលការណ៍ដែលកំពុងតែត្រូវបានដាក់ចុះបញ្ហានីមួយៗនឹងអាចត្រូវបានដោះស្រាយតាមពេលវេលារបស់វាដោយផ្អែកលើគោលការណ៍នេះ និងស្របតាមសភាពការណ៍ជាក់ស្តែង" ។

◆ សេចក្តីដកស្រង់ខាងក្រោមនេះត្រូវបានដកស្រង់ចេញពីការទាក់ទងរបស់អ្នកនិពន្ធជាមួយនឹង ខៀវ សំផន នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨៦ និងចម្លើយរបស់ ខៀវ សំផន ដែលធ្វើឡើងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៦÷

មកពី ខាល ដែកសុន "**មនោគមវិជ្ជានៃបដិវត្តន៍ផ្តាច់ការ**" នៅក្នុងកម្ពុជា ១៩៧៥-១៩៧៨ៈ "**ការណាត់ស្លាប់**" សាកលវិទ្យាល័យព្រីនតុន ឆ្នាំ១៩៨៩ ។

**ទំព័រ៧៤ៈ** នៅក្នុងការថ្លែងសុន្ទរកថាមួយនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ខៀវ សំផន និយាយថា "តើរាល់សមិទ្ធផលទាំងអស់នេះផលិតដោយគ្រឿងចក្រឬ? ទេ! យើងគ្មានគ្រឿងចក្រទេ ។ យើងធ្វើអ្វីៗគ្រប់យ៉ាងដោយពឹងផ្អែកលើកម្លាំងប្រជាជនយើង ។ យើងធ្វើការងារដោយស្វ័យម្ចាស់ការ ។ នេះសបញ្ជាក់ពីវីរភាពខ្លាំងក្លារបស់ប្រជាជនយើង ។ ហើយនេះក៏បង្ហាញពីកម្លាំងខ្លាំងក្លារបស់ប្រជាជនយើងដែរ ។ ទោះបីមានតែបាតដៃទទេក៏ប្រជាជនធ្វើអ្វីៗកើតដែរ" ។

**ទំព័រទី៧៤ៈ** នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៧ៈ "នៅក្នុងរបបចាស់តើកូនសិស្សសាលាទូទៅនិងនិស្សិតសាកលវិទ្យាល័យបានដឹងពីធាតុពិតនៃវិទ្យាសាស្ត្រទេ? តើគេអាចប្រាប់ពីភាពខុសគ្នារវាងស្រូវស្រាលនិងស្រូវធ្ងន់ទេ? តើគេដឹងថាកន្លែងណាជាកន្លែងព្រោះស្រូវ ហើយកន្លែងណាជាកន្លែងដកស្ទូងស្រូវទេ? គ្មានអ្នកណាដឹងទេ ។ ដូច្នេះយើងអាចនិយាយបានថា សិស្សទាំងអស់នោះស្ថិតនៅឆ្ងាយពីការពិត ។ ជាផលវិបាក សិស្សទាំងអស់នោះមិនអាចធ្វើអ្វីបានពិតប្រាកដឡើយ ។ សិស្សទាំងអស់ពឹងទាំងស្រុងទៅលើពួកបរទេស សង្ឃឹមថានឹងបានរបស់របរពីបរទេសនិងសូម្បីតែអ្នកជំនាញការបរទេស ។ អ្វីៗគ្រប់យ៉ាងត្រូវបានធ្វើឡើងដោយផ្អែកលើសៀវភៅបរទេសនិងគំរូបរទេស ។ ដូច្នេះវាគ្មានប្រយោជន៍មិនអាចបំពេញសេចក្តីត្រូវការរបស់ប្រជាជននិងមិនអាចរួមចំណែកកសាងជាតិយើងឡើយ" ។ **ម៉ារី ម៉ាធីន**

# កំណត់ហេតុស្ដីអំពីអង្គប្រជុំរបស់សភាជាតិនៃព្រះរាជាណាចក្រកម្ពុជា លើសេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**(តពីលេខមុន)** **សម្ដេចក្រុមព្រះ :** *សូមអញ្ជើញឯកឧត្ដមតំណាង ។*

**ឯកឧត្ដម សុខ អាន:** *ទូលបង្គំសូមក្រាបថ្វាយបង្គំសម្ដេចព្រះប្រធានជាថ្មីម្ដងទៀត និងសុំគោរពសម្ដេចអនុប្រធានសូមគោរព ឯកឧត្ដមអនុប្រធានទីពីរ និងសូមថ្វាយបង្គំគោរពអង្គសភាទាំងមូល ទូលបង្គំខ្ញុំបាទគ្រាន់តែសុំព្រះរាជានុញ្ញាតសុំអនុញ្ញាតបញ្ជាក់បន្ថែមអំពីគោលគំនិតដែលរៀបចំជំពូកទីមួយនេះ ។ នេះជាបទបញ្ញត្តិទូទៅដែលមានមាត្រាទោលតែមួយគឺមាត្រាមួយ មាត្រាមួយនេះដូចដែលឯកឧត្ដម ប៉ែន បញ្ញា លោកបានមានប្រសាសន៍អម្បាញ់មិញគឺថាខ្លីមែន ប៉ុន្តែបញ្ជាក់នូវគោលការណ៍ច្បាស់លាស់ចំនួនបីគឺនៅជំពូកទីពីរគឺយើងនិយាយពីសមត្ថកិច្ច ប៉ុន្តែការពិតមាត្រាទីមួយនេះគឺក៏បែកអំពីវង្វង់សមត្ថកិច្ចនៃការអនុវត្តច្បាប់នេះ ។ វង្វង់សមត្ថកិច្ចនេះគឺកំណត់ទៅលើទិដ្ឋភាពបីយ៉ាងសំខាន់ខាងផ្នែកច្បាប់ទីមួយគឺអ្វីដែលយើងហៅថាទិដ្ឋភាពនៃសមត្ថកិច្ចខាងបុគ្គល La Compétence personelle គឺកំណត់ទៅលើមុខសញ្ញាដែលត្រូវជាកម្មវត្ថុនៃការវិនិច្ឆ័យទោសរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ អ្វីចឹងគឺបានកំណត់ច្បាស់ហើយគឺមានតែមេដឹកនាំជាន់ខ្ពស់និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតដូច្នេះគឺសំដៅលើមុខសញ្ញាមួយចំនួន តូចចង្អៀតទេ ដែលអាចនិយាយបានថាជាអ្នកដែលធ្វើខុសច្រើនជាងគេបំផុតហើយនៅក្នុងស្មារតីនៃមាត្រាមួយ យើងឃើញហើយគឺថាមុខសញ្ញានេះមិនច្រើន មិនទូលាយមិនរាលដាលនោះទេ គឺស្មារតីគឺចង់បាន បង្រួញមុខសញ្ញានេះឲ្យច្បាស់លាស់ឲ្យជាក់ស្ដែងឲ្យតិចបំផុត ។ ចំណុចមួយទៀតដែលជាទិដ្ឋភាពទីពីរដែលយើងហៅថា La Compétence matérielle បានន័យថាមាត្រាខ្លីនេះមាត្រាទោលនេះខិតខំបញ្ជាក់អំពីបទល្មើស បទល្មើស ដូច្នេះនៅក្នុងនេះគឺមាននិយាយហើយពីឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌ ហើយនិងការរំលោភទៅលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ទម្លាប់អន្តរជាតិ រំលោភលើអនុសញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់ ចំណុចទីបីដែលជាទិដ្ឋភាពសំខាន់ដែរគឺការកំណត់អំពីសមត្ថកិច្ចខាងពេលវេលា La Compétence Temporelle គឺបញ្ជាក់ច្បាស់នៅក្នុងនេះថា យើងយកតែពីកាលបរិច្ឆេទ ១៧ មេសា ឆ្នាំ ១៩៧៥ ទៅដល់ ៦ មករា មកដល់៦ មករា ១៩៧៩ ។ ដូច្នេះទូលបង្គំខ្ញុំបាទក៏សុំបញ្ជាក់ទូលថ្វាយជម្រាបជូនម្ដងទៀតថា បទបញ្ញត្តិទូទៅនេះខ្លីមែន មានមាត្រាតែមួយមែន ប៉ុន្តែបញ្ជាក់បាននូវសមត្ថកិច្ចបីយ៉ាង គឺសមត្ថកិច្ចខាងបុគ្គលដែលជាមុខសញ្ញា សមត្ថកិច្ចដែលបញ្ជាក់ពីលើបទល្មើស និងសមត្ថកិច្ចដែលបញ្ជាក់ពីពេលវេលា ទូលបង្គំខ្ញុំបាទសូមមានយោបល់តែត្រឹមណេះ ។*

**សម្ដេចក្រុមព្រះ :** *សូមអង្គសភាលោកអនុម័តនូវជំពូកទីមួយ ។*

**អគ្គលេខាធិការនៃអង្គប្រជុំ:** *សូមគោរពទូលថ្វាយសម្ដេចក្រុមព្រះ ព្រះប្រធាននៃរដ្ឋសភា សូមគោរពសម្ដេចអនុប្រធានទីមួយ ឯកឧត្ដមអនុប្រធានទីពីរ អង្គសភាទាំងមូលមតិគាំទ្រនូវច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យលើជំពូកទីមួយមាន៩៦លើ៩៦ សូមអរព្រះគុណ! សូមអរគុណ! ។*

**សម្ដេចក្រុមព្រះ :** *សភាលោកបានអនុម័តជំពូកទីមួយ ហើយជំពូកទីពីរជាជំពូកវែង ខ្ញុំសុំប្រកាសលើកពេលប្រជុំនៅថ្ងៃនេះ ហើយនៅថ្ងៃអង្គារ ព្រោះថ្ងៃច័ន្ទជាថ្ងៃទីមួយចាស! ថ្ងៃអង្គារយើងបន្តការពិនិត្យនិងពិភាក្សាលើសេចក្ដីព្រាង.....ថ្ងៃអង្គារ ថ្ងៃអង្គារទី២ ខែមករា ក្នុងនាមរូបខ្ញុំជាប្រធានរដ្ឋសភានិងសម្ដេចអនុប្រធានទីមួយ ឯកឧត្ដមអនុប្រធានទីពីរ សុំប្រសិទ្ធិពរថ្វាយនិងជូនដល់អ្នកអង្គម្ចាស់ លោកជំទាវ ឯកឧត្ដមសមាជិក សមាជិកាទាំងអស់ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីសកលនេះសូមមានអាយុយឺនយូរ កម្លាំង ពលំល្អ ហើយឈ្នះមារសត្រូវគ្រប់បែបយ៉ាង ហើយទទួលនូវជោគជ័យកាន់តែធំទៀតក្នុងការបម្រើប្រទេសជាតិមាតុភូមិទៅក្នុងក្របខ័ណ្ឌស្ថាប័នកំពូលគឺរដ្ឋសភាជាតិ ក៏សូមអរព្រះគុណ! សូមអរគុណ!*

**អគ្គលេខាធិការនៃអង្គប្រជុំ:** *សូមគោរពសម្ដេចប្រធានស្ដីទី ឯកឧត្ដមអនុប្រធាន សូមគោរពអង្គសភាទាំងមូល សូមទូលថ្វាយនិងជម្រាបវត្តមានព្រឹកនេះមានចំនួន៩០រូប សូមអរព្រះគុណ អរគុណ ។*

**សម្ដេច ហេង សំរិន :** *សូមគោរពឯកឧត្ដមអនុប្រធានទី២ សូមថ្វាយបង្គំព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ លោកជំទាវ សមាជិកសមាជិកានៃរដ្ឋសភា និងសូមគោរពតំណាងរាជរដ្ឋាភិបាល ។ ថ្ងៃនេះយើងនឹងបន្តពិភាក្សាលើច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់*

សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យជំពូកទី២ ។ អ៊ីចឹង សូមអញ្ជើញប្រធានគណៈកម្មការអាននូវជំពូកទី២ ។

**ឯកឧត្តម ម៉ោញ សាផាន :** ទូលបង្គំខ្ញុំបាទសូមគោរពសម្តេចប្រធានអង្គប្រជុំ សូមគោរពឯកឧត្តមអនុប្រធានទី២ សូមគោរពអង្គសភា ។ ទូលបង្គំខ្ញុំបាទសូមរាជានុញ្ញាតនិងអនុញ្ញាតពីអង្គសភាអាននូវជំពូកទី២ដូចតទៅៈ ជំពូកទី២ សមត្ថកិច្ច មាត្រា២ៈ ត្រូវបានបង្កើតឲ្យមានការអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូលដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើលើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ ។ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះហៅថា «ជនសង្ស័យ» ។ មាត្រា៣ៈ អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ ។ មនុស្សឃាតមាត្រា៥០១ ៥០៣ ៥០៤ ៥០៥ ៥០៦ ៥០៧ និងមាត្រា៥០៨ ។ ទារុណកម្មមាត្រា៥០០ ។ ការវាយប្រហារលើសាសនាមាត្រា២១៤ និងមាត្រា២១០ ។ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើត្រូវបានពន្យារពេលបន្ថែម២០ឆ្នាំទៀតទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ។ មាត្រា៤ៈ អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ក្រាបនិងការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩ ។ អំពើប្រល័យពូជសាសន៍ ដែលគ្មានអាជ្ញាយុកាលគឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោមហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធ៍ ជាតិពន្ធុ ឬពូជសាសន៍ ឬសាសនាណាមួយដូចជាការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយសតិបញ្ញាសមាជិកនៃក្រុម ។ ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរូបរាងកាយទាំងស្រុងឬមួយផ្នែក ។ ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឲ្យមានការផ្តល់កំណើតទារក ។ ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅឲ្យក្រុមមួយ ទៅឲ្យក្រុមមួយផ្សេងទៀត ។ បទល្មើសខាងក្រោមត្រូវផ្តន្ទាទោសដូចបទល្មើសខាងលើដែរ ។ ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ការផ្សំគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ មាត្រា៥ៈ អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩ ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាល ឬអំពើណាមួយដូចខាងក្រោមដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំង ។ ជម្លៀសប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភទៅលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយពូជសាសន៍ឬសាសនាអំពើអមនុស្សធម៌ផ្សេងៗទៀត ។ មាត្រា៦ៈ អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្ត ឬបានបញ្ជាឲ្យប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដូចជាអំពើប្រឆាំងមនុស្ស ឬទ្រព្យសម្បត្តិដែលត្រូវការពារដោយបទបញ្ញត្តិនៃអនុសញ្ញានេះ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩ ។ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការបំផ្លាញ ឬធ្វើឲ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិដោយពុំមានហេតុផលចាំបាច់ខាងយោធាដែលធ្វើឡើងដោយខុសច្បាប់នឹងគ្មានត្រាប្រណី ការបង្ខំឲ្យឈ្លើយសឹក ឬជនស៊ីវិលបម្រើការនៅក្នុងកម្លាំងរបស់គូបដិបក្ខ ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងត្រង់ ការនិរទេស ការជម្លៀសឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការយកជនស៊ីវិលជាចំណាប់ខ្មាំង ។ មាត្រា៧ អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ យោងតាមអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ហើយដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩ ។ មាត្រា៨ អង្គជំនុំជម្រះវិសាមញ្ញ

មានអំណាចវិនិច្ឆ័យទោស ជនសង្ស័យដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ យោងតាមអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូតហើយដែលបានបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩ ។ នៅក្នុងជំពូកទី២នេះគឺនិយាយអំពីសមត្ថកិច្ច ទូលបង្គំខ្ញុំបាទ សូមសង្ខេបពីខ្លឹមសារសំខាន់ពីជំពូកនេះ គឺជំពូកនេះចង់បញ្ជាក់ថាច្បាប់នេះគឺប្រើ គឺមានសុពលភាពប្រើប្រាស់ទាំងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ហើយនិងអនុសញ្ញាឬសិទ្ធិសញ្ញាទាំងឡាយដែលកម្ពុជាបានទទួលស្គាល់ ។ នៅក្នុងនោះក៏មានអនុសញ្ញាទីក្រុងវីយែនដែលនិយាយអំពីការការពារ ផ្នែក...ចំពោះអ្នកការទូតដែរ ។ អ៊ីចឹងគឺនៅក្នុងនេះគឺកើតឡើងយ៉ាងដូច្នេះដើម្បីបើកឲ្យទូលាយ ទូលាយក្នុងការចោទប្រកាន់ គឺបើទោសស្រាល ឬបទឧក្រិដ្ឋធម្មតា យើងប្រើក្រមព្រហ្មទណ្ឌកម្មចាស់យើង ប៉ុន្តែបើចូលទៅក្នុងក្របខណ្ឌនៃអំពើប្រល័យពូជសាសន៍ ឬមនុស្សឃាត ឬ ន៎! ឧក្រិដ្ឋកម្មសង្គ្រាមគឺយើងប្រើតាមអនុសញ្ញា និងសិទ្ធិសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់ ។ អ៊ីចឹងមានខ្លឹមសារសំខាន់ពីរយ៉ាងដូច្នេះ ទូលបង្គំខ្ញុំបាទសូមដាក់ជូននូវជំពូកទី២ថ្វាយ និងជូនអង្គសភាដើម្បីពិនិត្យនិងអនុមត័តាមការគួរ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិន :** សូមអញ្ជើញឯកឧត្តម ជាម យៀប

**ឯកឧត្តម ជាម យៀប:** ខ្ញុំបាទសូមគោរពសម្តេចប្រធានអង្គប្រជុំនៃរដ្ឋសភា សូមគោរពឯកឧត្តម អនុប្រធានរដ្ឋសភា និងសូមគោរពអង្គសភា ។ ខ្ញុំបាទសុំចូលរួមពិភាក្សានៅលើខ្លឹមសារនៃសេចក្តីព្រាងជំពូកទី២ ដែលស្តីពីសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជាដែលមានខ្លឹមសារដូចតទៅនេះ ÷ ជារួមខ្ញុំបាទសូមឯកភាពនៅលើខ្លឹមសារនៃសេចក្តីព្រាងជំពូកទី២នេះ ។ ប៉ុន្តែទន្ទឹមនឹងការឯកភាពនេះ ក៏សូមស្នើថា ដោយថ្ងៃនេះក្នុងនាមតំណាងរាស្ត្រខ្ញុំបាទសូមសម្តែងការអបអរសាទរចំពោះឯកឧត្តមទេសរដ្ឋមន្ត្រីដែលអញ្ជើញមកការពារច្បាប់ហើយមានអមដោយលោកជំទាវជាប្រធានសាលាឧទ្ធរណ៍ ក៏ដូចជាឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋលេខាធិការក្រសួងយុត្តិធម៌ គឺជាសមត្ថកិច្ចគ្រប់គឺសុទ្ធសឹងជាអ្នកច្បាប់ធំៗ ។ អ៊ីចឹងទេ ដើម្បីឲ្យអង្គសភាក៏ដូចជាប្រជាពលរដ្ឋយើងលោកបានយល់កាន់តែច្បាស់ ព្រមទាំងនេះគឺជាសាក្សីសម្រាប់នៅពេលជំនុំជម្រះនៅពេលខាងមុខនេះ គឺថាដល់ចៅក្រមជំនុំជម្រះ ក៏ដូចជាចៅក្រមស៊ើបអង្កេតទាំងជាតិកម្ពុជា ទាំងអន្តរជាតិផងនោះ គឺខ្ញុំបាទសូមលើកឡើងនូវពីរបញ្ហាដែលសុំគ្រាន់តែឆ្លើយបំភ្លឺប៉ុណ្ណោះទេ ។ បញ្ហាទី១ ដោយច្បាប់នេះពុំទាន់បានបញ្ជាក់ពីវិសាលភាពរបស់ខ្លួនច្បាស់លាស់ ពីព្រោះបណ្តាច្បាប់ទាំងឡាយចាំបាច់ បើច្បាប់សាមញ្ញ គឺកំណត់វិសាលភាពសាមញ្ញ ច្បាប់វិសាមញ្ញ ត្រូវកំណត់វិសាមញ្ញនៃច្បាប់នោះ ។ នេះគឺបញ្ហាទី១ ច្បាប់សាមញ្ញរបៀបណា? ច្បាប់សាមញ្ញមានន័យអ៊ីចេះគឺថាមាន គឺថាអានុភាពគតិយុត្តិហ្នឹងរហូតទៅដល់មានច្បាប់ថ្មីមកជំនួស ទើបច្បាប់នេះគឺថាអាចស័ក្តិសមទៅបាន ។ ចំណែកឯច្បាប់វិសាមញ្ញយើងឃើញថាតើច្បាប់នេះ គឺថាកាត់ទោសតែក្នុងរយៈពេលមួយកំណត់តែប៉ុណ្ណោះ ឬយ៉ាងណា? នេះគ្រាន់តែសូមឲ្យអ្នកច្បាប់គឺថាអ្នកច្បាប់មេត្តាបំភ្លឺឲ្យបានច្បាស់លាស់គឺថាដើម្បីឲ្យសភាជួយធ្វើសាក្សី សភាអាណត្តិទី២នេះជួយធ្វើសាក្សីនូវចំពោះការកាត់ក្តីនាពេលខាងមុខនេះ ។ ខ្ញុំបាទសូមជម្រាបផងដែរថា ទន្ទឹមនេះដែរគឺសុំស្នើឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាបញ្ជាក់ផងដែរ ពីព្រោះកន្លងមកនៅបណ្តាច្បាប់និងបទដ្ឋានទាំងឡាយដែលនៅជាគតិយុត្តិ នៅជាគឺថាមានអានុភាពជាគតិយុត្តិ គឺនៅប្រើប្រាស់បានជាធរមាននោះយើងមិនធ្លាប់ដែលប្រើពាក្យថាសាលាដំបូងទេ នៅក្នុងមាត្រា២ នៅបន្ទាត់ទីមួយខាងចុង ។ យើងតែងប្រើថាតុលាការខេត្តក្រុង អ៊ីចឹងទេគឺថាសូមមេត្តាជម្រាបអំពីអត្ថន័យនៃពាក្យថាសាលាដំបូងនេះ ។ នេះសាលាដំបូង? ពីព្រោះថាធម្មតាកម្រិតនៃតុលាការដែលមានជាធរមាននៅក្នុងច្បាប់មានតែបីទេគឺតុលាការខេត្តក្រុង តុលាការសាលាឧទ្ធរណ៍ និងតុលាការកំពូល ។ អ៊ីចឹងទេបានជាខ្ញុំដឹងថានៅពេលខាងមុខនេះរាជរដ្ឋាភិបាលកំពុងតែធ្វើសេចក្តីព្រាងច្បាប់មួយស្តីអំពីប្រពន្ធ័តុលាការក្នុងនោះមានពាក្យថាសាលាដំបូង ។ ប៉ុន្តែពេលនេះយើងមិនទាន់បានប្រើប្រាស់ អ៊ីចឹងទេសូមមេត្តាបញ្ជាក់ពេលនេះឲ្យហើយ ។ នេះបញ្ហាទី១ ។ បញ្ហាទី២ ខ្ញុំបាទឯកភាពហើយ គឺការចង្អុលទិសនៅក្នុងខ្លឹមសារនៃសេចក្តីព្រាងមាត្រា៣នៃច្បាប់នេះគឺចង្អុលទៅលើបណ្តាច្បាប់ដែលនៅជាធរមាន គឺគតិយុត្តិជាធរមាននៅក្នុងនោះគឺឯកឧត្តមប្រធានគណៈកម្មការ នីតិកម្មគាត់បានលើកហើយ ។ ច្បាប់ទាំងឡាយដែលនៅជាធរមានមានដូចតទៅៈ ទី១គឺក្រមព្រហ្មទណ្ឌ ដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ១៩៥៦ ។ ទី២គឺថាគឺក្រឹត្យច្បាប់០២ នៅក្នុងឆ្នាំ១៩៨១ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ទី៣ គឺច្បាប់ស្តីអំពីច្បាប់ព្រហ្មទណ្ឌ គឺថានៅឆ្នាំ១៩៨២ នៃរដ្ឋកម្ពុជា និងទី៤ គឺច្បាប់ស្តីអំពីអន្តរកាលព្រហ្មទណ្ឌអន្តរកាល នៅក្នុងរយៈពេលដែលអង្គការសហប្រជាជាតិចូលមកដោះស្រាយបញ្ហាកម្ពុជា ។ អ៊ីចឹងទេខ្ញុំបាទសូមជម្រាបថានៅក្នុងមាត្រា៣ គឺថាខ្លឹមសារនៃសេចក្តីព្រាងនេះគឺថាបានចង្អុលទៅបណ្តាទោសព្រហ្មទណ្ឌទាំងឡាយនៃបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុងបទព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលមានមាត្រាជាច្រើន ។ ខ្ញុំបាទសូមរំឭកសាឡើងវិញ ក្រមព្រហ្មទណ្ឌ ១៩៥៦ ដូចជាមាត្រា២០៩ស្តីអំពីការប្រព្រឹត្តបទល្មើសលើអ្នកកាន់សាសនា គឺថាធម្មតាកម្រិតនៃតុលាការ ឬក៏ស្ថាប័នតុលាការនៅពេលនោះគឺថាមាន

៣កម្រិតនៃទោសព្រហ្មទណ្ឌគឺមានកម្រិត៣ ។ កម្រិតទី១ គឺលហុ ។ លហុមាន៣កម្រិតទៅទៀត មានស្រាល មានមធ្យម មានធ្ងន់ ។ ទី២គឺមជ្ឈិម មជ្ឈិមហ្នឹងគឺថាមានមជ្ឈិមទី១ ទី២ ទី៣ និងទី៣ គឺឧក្រិដ្ឋ ឧក្រិដ្ឋទី១ ទី២ ទី៣ ។ ខ្ញុំបាទគ្រាន់តែសុំលើកយកតែពាក្យថាទោសឧក្រិដ្ឋទេ ។ ទោសឧក្រិដ្ឋនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦បានចែងច្បាស់ឧក្រិដ្ឋថ្នាក់ទី១ គឺដាក់គុកបង្ខំធ្វើការដោយមានរយៈពេល Peine perpétuelle de l'attente [dans le temp] ។ ទី២ គឺថាឧក្រិដ្ឋថ្នាក់ទី២ គឺថាដាក់គុកបង្ខំឲ្យធ្វើការអស់មួយជីវិតហៅថា Peine perpétuelle à vie ។ និងទី៣ ឧក្រិដ្ឋថ្នាក់ទី៣គឺថាទោសប្រហារជីវិតគឺ Peine capitale ។ អ៊ីចឹងទេទាំងបីនេះ វាមានការទាក់ទាមទៅនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលនៅក្នុងនោះគឺថាមាត្រាទី៣២ ជំពូកទី៣ បានចែងច្បាស់ថាទោសប្រហារជីវិតមិនត្រូវមានទេ ។ អ៊ីចឹងខ្ញុំបាទគ្រាន់តែមានចម្ងល់ទេ ចម្ងល់ពេលនេះគឺថាសូមតែបំភ្លឺទេគឺឯកភាពគឺឯកភាពហើយ ឲ្យតែ រ៉ង់វ័រ (Renvoi) ច្បាប់ចាស់ហ្នឹងដែលនៅជាធរមាន ហ្នឹងហើយ ប៉ុន្តែគ្រាន់តែសុំមេត្តាបំភ្លឺជូនអង្គសភាតែប៉ុណ្ណឹងទេថាតើបណ្ដាច្បាប់ដែលមានការពាក់ពន្ធ័ទៅនឹងមាត្រាស្ដីពីមាត្រា ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧, ៥០៨, ៥០០, ២០៩, ២១០ ដែលចែងនៅក្នុងដែលមានចង្អុលនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦នេះ គឺថាអាចមានការប៉ះពាល់ទៅនឹងរដ្ឋធម្មនុញ្ញយើងទេ នៅពេលដែលបើកសវនាការជំនុំជម្រះនៃច្បាប់នេះ ក្រោយពេលដែលព្រះករុណាជាអង្គម្ចាស់ជីវិតលើត្បូងឡាយព្រះហស្ដលេខាលើព្រះរាជក្រមឲ្យប្រើប្រាស់ ពីព្រោះខ្ញុំបាទយល់ឃើញអ៊ីចេះ យល់ឃើញថាថ្វីដ្បិតតែយើងទាំងអស់គ្នាបានយល់ថាអ៊ីចេះ វាស៊ីសងទៅលើតុលាការទេ តុលាការគឺចៅក្រម ។ ចៅក្រមកាត់ក្ដីវាតែងតែឈរនៅលើទិដ្ឋភាពពីរ ទិដ្ឋភាពទី១គឺនៅលើច្បាប់ដែលមាន ទី២ទៀតទៅលើអង្គគឺថាអង្គហេតុ គឺហេតុដែលបណ្ដាលមកពីហ្នឹង គឺថាគេរកចៅក្រមស៊ើបអង្កេតគេរកអង្គហេតុឲ្យមៅ៉ហេតុហ្នឹងហើយដែលគេយកទៅកាត់ក្ដី យកច្បាប់ណាមកកាត់ អ៊ីចឹងទេបានវាមានការប៉ះពាល់ អ៊ីចឹងបានជាខ្ញុំបាទគ្រាន់តែមេត្តាជួយបំភ្លឺអង្គសភាដើម្បីជួយធ្វើជាសាក្សី នៅពេលដែលអង្គជំនុំជម្រះកាត់ក្ដីនាពេលខាងមុខនេះថាតើបើសិនរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលចែងនៅក្នុងមាត្រា៣២ ជំពូកទី៣ថាទោសប្រហារជីវិតអត់មាន ហើយយើង Renvoi ទៅក្រមព្រហ្មទណ្ឌចាស់ គឺថាទោសប្រហារជីវិតគឺត្រូវមាន អាហ្នឹង Peine capitale ត្រូវមាន ។ មានហ្នឹងមានដូចតទៅ មាត្រា២០៩ មាត្រា៥០០ មាត្រា៥០៦ មាត្រា ៥០៧ គឺថាក្នុង៤មាត្រានេះគឺមានរហូតដល់ឧក្រិដ្ឋថ្នាក់ទី៣ ដែលមានន័យថាកាត់ទោសប្រហារជីវិត ។ នេះខ្ញុំបាទគ្រាន់តែសុំមេត្តាបំភ្លឺនូវការងឿងឆ្ងល់ទេ តាមធម្មតាគឺសុំឯកភាពទាំងស្រុងនៅលើខ្លឹមសារនៃសេចក្ដីព្រាងជំពូកទី២នេះ ។ ខ្ញុំបាទសុំអស់យោបល់ សូមអរគុណអង្គសភានិងគណៈអធិបតី ។

**សម្ដេច ហេង សំរិន:** សូមអញ្ជើញឯកឧត្តម ស៊ុន គឹមហ៊ុន ។

**ឯកឧត្ដម ស៊ុន គឹមហ៊ុន:** ជាបឋមទូលព្រះបង្គំខ្ញុំបាទសូមគោរពសម្ដេចប្រធានស្ដីទីព្រមទាំងសូមគោរពឯកឧត្តមអនុប្រធានទី២ សូមគោរពអង្គសភាទាំងមូល ជាពិសេសសូមគោរពតំណាងរាជរដ្ឋាភិបាល ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាទីគោរព ។ ទូលបង្គំខ្ញុំបាទឡើងមកធ្វើបទអន្តរាគមន៍ថ្ងៃនេះគឺថាសុំឯកភាពទាំងស្រុងក្នុងជំពូកទី២ ស្ដីអំពីសមត្ថកិច្ច អត់មានជំទាស់អ្វីទាំងអស់ ក៏ប៉ុន្តែគ្រាន់តែសុំបន្ថែមពាក្យមួយនៅមាត្រា២ ដើម្បីឲ្យស្របទៅនឹងច្បាប់ដែលអំណាចតុលាការដែលជាស្ថាប័នឯករាជ្យ ហេតុដូច្នេះទូលព្រះបង្គំខ្ញុំបាទសូមបង្កើតពាក្យត្រង់មាត្រាទី២ ថាត្រូវតែបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ ឬឯករាជ្យ ។ សុំបន្ថែមតែប៉ុណ្ណឹងទេ «និងឯករាជ្យ» ហ្នឹងមាត្រាទី២ អត់មានជំទាស់អ៊ីទាំងអស់ សុំបន្ថែមពាក្យតែប៉ុណ្ណឹងទេ ។ ដល់មាត្រាទី៣ មិនបន្ថែមពាក្យទេគឺមានការឆ្ងល់សុំសួរទៅឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មេត្តាបំភ្លឺឲ្យច្បាស់អំពីមាត្រា៣ នៅជំពូកទី២ វាក្យខណ្ឌទី២ទូលព្រះបង្គំខ្ញុំបាទអានដូចតទៅនេះ ÷ អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើត្រូវបានពន្យារពេលបន្ថែម២០ឆ្នាំទៀតទៅលើអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ។ ត្រង់វាក្យខណ្ឌទី២នៃមាត្រាទី៣នេះ សូមឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មេត្តាបំភ្លឺដល់អង្គសភាដូចជួយបំភ្លឺដល់ទូលព្រះបង្គំខ្ញុំបាទ ។ ខ្ញុំសុំឲ្យបំភ្លឺថាតើឃ្លាវាក្យខណ្ឌខាងលើនេះអាចប៉ះពាល់គោលការណ៍ប្រតិសកម្មនៃច្បាប់នីតិវិធីព្រហ្មទណ្ឌដែរឬទេ? សូមអភ័យទោសពាក្យអង់គ្លេសគេថា To infringe on the principle of the retroactif [retroactivity] of the criminal law and procedure គឺថាសុំឲ្យបភ្លឺថាតើអាចប៉ះពាល់លើគោលការណ៍ប្រតិសកម្មនៃច្បាប់នីតិវិធីព្រហ្មទណ្ឌដែរឬទេ? ដែលយើងដាក់ថាអាជ្ញាយុកាលនេះ ហើយបន្តពន្យារពេលរហូតដល់ទៅ២០ឆ្នាំទៀត ។ ទូលព្រះបង្គំខ្ញុំបាទមានយោបល់តែប៉ុណ្ណេះគឺថាក្រៅពីហ្នឹងសុំគាំទ្រមួយរយភាគរយ សូមអរព្រះគុណ សូមអរគុណ ។

**សម្ដេច ហេង សំរិន:** សូមអញ្ជើញទេសរដ្ឋមន្ត្រីតំណាងរាជរដ្ឋាភិបាលឡើងបំភ្លឺ ។

**ឯកឧត្ដម សុខ អាន:** បាទ! ខ្ញុំបាទសូមគោរពសម្ដេចប្រធានអង្គប្រជុំ សូមគោរពឯកឧត្តមអនុប្រធានទី២ និងសូមថ្វាយបង្គំគោរពអង្គសភាទាំងមូល ។ ទូលបង្គំខ្ញុំសុំបាទសុំជាបឋមសុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមជាវាគ្មិនខាងដើមដែលបានលើកឡើងនូវសំណួរដែលមានសារសំខាន់

ទាំងនេះ ។ ទូលបង្គំខ្ញុំបាទសូមឆ្លើយសំណួរ៤នេះ ឯកឧត្តម ជាម យៀប លោកលើកឡើងនូវសំណួរបី ឯកឧត្តម កែ គីមយ៉ាត លោកលើកឡើងនូវសំណួរពីរ ហើយសហការីទូលបង្គំខ្ញុំបាទក៏អាចនឹងបញ្ជាក់ទូលថ្វាយនឹងជម្រាបជូនបន្ថែម ។ ចំណុចទី១ គឺបញ្ហាវិសាលភាព ។ បញ្ហាវិសាលភាពនៃច្បាប់ដែលយើងកំណត់នៅក្នុងមាត្រាតាំងពីមាត្រា១ មាត្រា២ ដែលយើងបានយកចិត្តទុកដាក់ចាប់អារម្មណ៍នេះ គឺជាចំណុចដែលមានលក្ខណៈពិសេសនៃច្បាប់នេះ បាទព្រោះថាធម្មតាច្បាប់គឺយើងអនុវត្តជាទូទៅដែលយើងថាសកម្មភាពនៃច្បាប់ ប៉ុន្តែចំពោះច្បាប់ដែលមានសារសំខាន់នេះ យើងបានលើកឡើងកំណត់នូវសមត្ថកិច្ចនិងវិសាលភាពយ៉ាងច្បាស់លាស់ដូចដែលទូលបង្គំខ្ញុំបាទបានលើកឡើងពីថ្ងៃមុនម្តងរួចមកហើយនេះនៅក្នុងមាត្រាទី១ គឺយើងបានលើកឡើងពីអ្វីដែលហៅថាសមត្ថកិច្ចបុគ្គល ព្រោះថាច្បាប់ធម្មតាតែគេរៀបចំម៉ោ គេអនុវត្តទាំងអស់ចំពោះប្រជាពលរដ្ឋទូទៅ ។ ប៉ុន្តែច្បាប់យើងនេះ គឺយើងបានលើកឡើងហើយ និងកំណត់នូវមុខសញ្ញាបុគ្គលដែលត្រូវជាកម្មវត្ថុដែលច្បាប់នេះរៀបចំឡើងដើម្បីវិនិច្ឆ័យទោស ។ អ៊ីចឹងនេះជាចំណុចទី១ដែលបានបញ្ជាក់ច្បាស់ណាស់អំពីវិសាលភាព ពីសមត្ថកិច្ចដែលយើងហៅថាសមត្ថកិច្ចបុគ្គល ។ ទី២ អ្វីដែលយើងហៅថាបទល្មើសនោះគឺយើងបានកំណត់ច្បាស់លាស់ដែរមានតាំងពីមាត្រាទី១ គឺយើងកំណត់បទល្មើសនេះហើយ ហើយបន្តបន្ទាប់ម៉ោនៅក្នុងជំពូកទី២ គឺលម្អិតថែមទៀតនូវការកំណត់វង្វង់ព្រំដែននេះ ហើយចំណុចទី៣ សមត្ថកិច្ចទី៣នេះដែលយើងហៅថា Compétence Temporelle គឺយើងកំណត់ច្បាស់ណាស់ ហើយយើងចែងនៅក្នុងមាត្រាជាច្រើន ជំពូកទី១ ជំពូកទី២ គឺយើងបញ្ជាក់ហើយ គឺថា ១៧ មេសា ឆ្នាំ១៩៧៥ ដល់ ៦ មករា ឆ្នាំ១៩៧៩ ។ អ៊ីចឹងគឺមានលក្ខណៈវិសាមញ្ញដូចដែលឯកឧត្តម ជាម យៀប លោកបានលើកឡើងគឺកំណត់នូវវង្វង់ព្រំដែនសកម្មភាពយ៉ាងច្បាស់លាស់ ។ នេះបើយើងនិយាយពីវិសាលភាព ។ បន្ថែមលើនេះទៅទៀតនៅក្នុងមាត្រាទី៤៧ មាត្រាទី៤៧ គឺយើងក៏បានបញ្ជាក់ដែរថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវរំលាយខ្លួនជាស្វ័យប្រវត្តិក្រោយពេលដែលការវិនិច្ឆ័យទោសក្នុងរឿងក្តីនេះបានចប់ជាស្ថាពរ ។ នេះជាច្បាប់វិសាមញ្ញមួយទៀតនៃច្បាប់ដែលមានសារសំខាន់របស់យើងនេះ ។ ដូច្នេះហើយទូលបង្គំខ្ញុំបាទក៏សូមបញ្ជាក់ជាថ្មីម្តងទៀតថានេះជាច្បាប់វិសាមញ្ញច្បាស់លាស់ហើយ ហើយជាការកំណត់វិសាលភាពនៃសមត្ថកិច្ចយ៉ាងច្បាស់លាស់ បាទច្រើនប្រភេទ បំភ្លឺដូចដែលទូលបង្គំខ្ញុំបាទបានលើកឡើង ។ ចំណុចទី២ សំណួរទី២ គឺថាពាក្យថាសាលាដំបូង ។ អ៊ីចឹងពាក្យថាសាលាដំបូងនៅក្នុងមាត្រាទី២នេះគឺជាពាក្យដែលយើងអាចនិយាយថាឆ្លុះបញ្ចាំងបាននូវទស្សនៈ នូវគំនិត ជាច្បាប់ជារួមដែលយើងលើកឡើងថានៅកម្ពុជាយើងមានតុលាការបីកម្រិត កម្រិតទី១ កម្រិតទី២ និងកម្រិតទី៣ ។ កម្រិតទី៣ គឺតុលាការកំពូល កម្រិតទី២គឺសាលាឧទ្ធរណ៍ ហើយកម្រិតទី១ដែលយើងប្រើពាក្យនៅក្នុងនេះថាសាលាដំបូងបានន័យថាតុលាការខេត្តក្រុង ។ នៅក្នុងស្មារតីនៃច្បាប់នេះគឺមិនអាចមានការច្រឡំបានទេ ព្រោះយើងបានចែងរួចហើយថា តុលាការគឺជាតុលាការដែលមានស្រាប់ បើអ៊ីចឹងនៅក្នុងច្បាប់យើង យើងបានសរសេរអ៊ីចឹង គឺតុលាការដែលមានស្រាប់ដូចដែលឯកឧត្តម គាត ឈន់ លោកបានលើកថ្ងៃមុនថាមិនមែនជាស្ថាប័នទេ តែវាជាយន្តការ ។ ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញគ្រាន់តែ យើងប្រើពាក្យនេះទាល់តែយើងខិតខំពិចារណាប្រើពាក្យពេចន៍នេះឲ្យត្រឹមត្រូវឲ្យសមរម្យដែរ គឺយើងប្រើពាក្យថាអង្គជំនុំជម្រះវិសាមញ្ញនេះដែលជាអាចថាយន្តការមួយ នៅក្នុងក្របខ័ណ្ឌនៃតុលាការដែលមានស្រាប់ ។ អ៊ីចឹងគឺក្នុងក្របខ័ណ្ឌនៃតុលាការកម្រិតទី១របស់យើង តុលាការកម្រិតទី២របស់យើង និងតុលាការ កម្រិតទី៣របស់យើងដែលមានស្រាប់ ។ អ៊ីចឹងយើងហៅថាតុលាការក្រុង ឬតុលាការខេត្ត ឬសាលាដំបូង នៅក្នុងស្មារតីនេះគឺមានន័យដូចគ្នា គឺមានន័យដូចគ្នា ។ អ៊ីចឹងហើយពាក្យសាលាដំបូងនេះគឺមានន័យតែប៉ុណ្ណឹងទេ គឺជាភាសាច្បាប់ធម្មតាដែលយើងតែងប្រើសំដៅលើតុលាការកម្រិតទី១ ។ សំណួរទី៣ អំពីពាក្យថាច្បាប់ព្រហ្មទណ្ឌដែលឯកឧត្តម ជាម យៀប លោកបានលើកឡើងដែរ គឺនៅក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺមានចែងអំពីទោសទណ្ឌដែលត្រូវប្រហារជីវិត ។ ចំណុចនេះគឺមិនសមស្របទៅនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣របស់យើងទេ ដែលចែងថានៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មិនមានទោសប្រហារជីវិតទេ អ៊ីចឹងនៅពេលដែលយើងបានលើកឡើងនូវមាត្រាខ្លះដែលដកស្រង់ចេញពីច្បាប់ឆ្នាំ១៩៥៦នេះ គឺយើងក៏បានពិគ្រោះពិភាក្សាជាមួយអ្នកច្បាប់ធំៗជាច្រើនថាតើយើងដាក់អ៊ីចឹងមានទំនាស់អី មានទំនាស់នឹងស្មារតីនៃរដ្ឋធម្មនុញ្ញរបស់យើងទេ អ៊ីចឹងការពិភាក្សាជារួមក៏ឈានទៅដល់ការសន្និដ្ឋានថាគ្រាន់តែតុលាការចៅក្រមលោកមិនអនុវត្តនៅចំណុចប្រហារជីវិត បើអ៊ីចឹងស្មារតីច្បាប់ជារួម គឺអាចជាច្បាប់ដែលមានសារសំខាន់ប្រើប្រាស់បាន គ្រាន់តែចំណុចដែលប្រហារជីវិតហ្នឹង គឺតុលាការចៅក្រមគេមិនអនុវត្ត ។ ដូចនេះច្បាប់មាត្រាទី៣៨ ជំពូកទី១១ មាត្រាទី៣៨ យើងបានសរសេរច្បាស់ហើយថា អំពីទោសបញ្ញត្តិ ព្រោះថាជំពូក ជំពូកទី១១នេះ គឺជាជំពូកដែលកំណត់នូវទោសបញ្ញត្តិ ។ អ៊ីចឹងយើងបានសរសេរច្បាស់ថា ទណ្ឌកម្មទាំងអស់ដែលត្រូវយកមកដាក់ត្រូវកំណត់ត្រឹមទោសដាក់ពន្ធនាគារ បើអ៊ីចឹងអាចជាប់ពន្ធនាគារ១០ឆ្នាំ ២០ឆ្នាំ ៣០ឆ្នាំ ឬអស់មួយជីវិត ក៏ប៉ុន្តែមិនអាចត្រូវបានប្រហារជីវិតទេ ។ សំណួរទី៤អំពីអង្គជំនុំជម្រះវិសាមញ្ញ ចង់ថែមទៀតថា "ឯករាជ្យ" ។ ទូលបង្គំខ្ញុំបាទយល់ឃើញថា ចំណុចនេះ ស្មារតីនៃតុលាការឯករាជ្យនេះ យើងបានចែងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញរបស់ យើងហើយ បាទ គឺនីតិបញ្ញត្តិ នីតិប្រតិបត្តិ

និងអំណាចតុលាការ ។ ដូច្នេះជាស្មារតីដែលយើងនិយាយថា តុលាការដែលមានស្រាប់នេះ គឺស្មារតីនៃការបែងចែកអំណាចនេះគឺមានច្បាស់លាស់ហើយ ហើយម្យ៉ាងទៀតអង្គជំនុំជម្រះវិសាមញ្ញនេះគឺក៏ស្ថិតនៅក្នុងក្របខ័ណ្ឌនៃតុលាការដែលមានស្រាប់ ។ ដូច្នេះទូលបង្គំខ្ញុំបាទយល់ថា យើងមិនបាច់ដាក់ពាក្យឯករាជ្យទេ គឺមានន័យគ្រប់គ្រាន់ថាឯករាជ្យ ហើយមាត្រា២នេះ គឺតុលាការឯករាជ្យ ហើយបើតាមស្មារតីច្បាស់លាស់នៃរដ្ឋធម្មនុញ្ញ ។ ហើយយើងក៏ត្រូវយល់ថា អង្គជំនុំជម្រះវិសាមញ្ញនេះ គឺគ្រាន់តែជាយន្តការមួយដាក់ទៅក្នុងតុលាការដែលមានស្រាប់នៅកម្ពុជា ។ ដូច្នេះមានន័យថាស្ថិតនៅក្នុងក្របខ័ណ្ឌនៃតុលាការកម្រិតទីមួយ ដែលយើងចង់ហៅថាតុលាការក្រុងក៏បានហៅថាតុលាការខេត្តក៏បាន គេហៅថាសាលាដំបូងក៏បាន ។ ស្ថិតក្នុងរចនាសម្ព័ន្ធនៃតុលាការកម្រិតទីពីរគឺតុលាការឧទ្ធរណ៍ ហើយនិងស្ថិតក្នុងរចនាសម្ព័ន្ធតុលាការកម្រិតទី៣ គឺតុលាការកំពូល ។ សំណួរទី៥ អាជ្ញាយុកាល អាជ្ញាយុកាលនេះគឺយើងបានកំណត់នៅក្នុងនេះ២០ឆ្នាំ ដោយយល់ថា ការបន្តអាជ្ញាយុកាលច្បាប់បានចែងច្បាប់ដើម១៩៥៦បានចែងថា អាជ្ញាយុកាលគឺមាន១០ឆ្នាំ ។ អ៊ីចឹងឥឡូវនេះ យើងរៀបចំមកប្រើឥឡូវនេះ គឺយើងដាក់ថែម២០ឆ្នាំទៀតដើម្បីទៅជា៣០ឆ្នាំ ។ អ៊ីចឹង៣០ឆ្នាំ របៀបយើងគិត គឺយើងគិតយកពេលដែលទោសទណ្ឌត្រូវបានប្រព្រឹត្ត ។ ដូច្នេះ គឺចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ អ៊ីចឹងបើយើងគិតពី៧៥ យើងបូក ១០ បូក២០បានន័យ៣០ឆ្នាំ ។ អ៊ីចឹងវាត្រូវអាចពន្យារមកដល់២០០៥ គឺជារយៈកាលដែលយើងអាចធ្វើការបានព្រោះឥឡូវឆ្នាំ ២០០០, ២០០១, ២០០២, ២០០៣, ២០០៤, ២០០៥ ។ ហើយសួរថា តើការអនុវត្តនូវគោលការណ៍ប្រតិសកម្ម *La rétroactivitée* នេះ តើវាមានខុសអីនឹង *Principle* នៅគោលការណ៍ច្បាប់ព្រហ្មទណ្ឌមួយទៀតថាទោស...ទណ្ឌអីទោសព្រហ្មទណ្ឌនេះមិនអាចជាប្រតិសកម្មបាននោះទេ ចំណុចនេះគឺអ្នកច្បាប់បានពិភាក្សាគ្នា ហើយសន្និដ្ឋានថា នៅក្នុងអង្គព្រហ្មទណ្ឌនៅក្នុងបទឧក្រិដ្ឋកម្មនេះយើងអាចចែងជាខ្លឹមសារពិតប្រាកដនៃច្បាប់ ហើយនិងអ៊ីដែលជានីតិវិធី ។ អ៊ីដែលជានីតិវិធី គឺមិនមានគោលការណ៍ហាមមិនឲ្យមានប្រតិសកម្មទេ ។ ប៉ុន្តែអ៊ីដែលជាខ្លឹមសារពិតប្រាកដនៃច្បាប់នោះគឺមិនអាចប្រតិសកម្មបានទេ ។ ដោយឈរលើគោលការណ៍នេះ ហើយប៉ុន្តែមុនៗនឹងលើកជាការធ្វើសន្និដ្ឋាន ទូលបង្គំខ្ញុំបាទក៏សូមធ្វើឧទាហរណ៍ ស្អីជាខ្លឹមសារពិតប្រាកដ ស្អីនីតិវិធី? អ៊ីចឹងគឺយើងលើកឧទាហរណ៍មួយឲ្យស្រណុកយល់ ឧទាហរណ៍ថាគេចែងពីលួច ស្អីដែលហៅថាលួច គឺជាការដកហូតសម្បត្តិរបស់អ្នកដទៃដោយមិនត្រឹមត្រូវដោយខុសច្បាប់ អ៊ីចឹងចាប់ត្រូវជាប់គុកពីប៉ុន្មានឆ្នាំទៅប៉ុន្មានឆ្នាំ នេះជាឧទាហរណ៍មួយនៃខ្លឹមសារពិតប្រាកដនៃច្បាប់ព្រហ្មទណ្ឌ ហើយនីតិវិធី គឺជារបបដែលយើងអនុវត្ត ។ អ៊ីចឹងហើយអ៊ីដែលយើងចែងនេះ គឺមិនចូលទៅក្នុងខ្លឹមសារពិតប្រាកដដែលយើងហៅថា *Substance* ជាខ្លឹមសារនៃច្បាប់បទព្រហ្មទណ្ឌនោះទេ គឺគ្រាន់តែពាក់ព័ន្ធទៅនឹងបញ្ហានីតិវិធី ។ ដូច្នេះជាការសន្និដ្ឋានគឺយើងអាចអនុវត្តនូវធាតុប្រតិសកម្មដែលយើងដាក់ថាពន្យារ២០ឆ្នាំនោះ ដើម្បីឲ្យការអនុវត្តរបស់យើងនេះវាធ្វើបានពីឥឡូវរហូតដល់ឆ្នាំ២០០៥ ។ ចន្លោះ...អឺ... ចន្លោះពី២០០៥ ១៩៧៥ដល់១៩៧៩នោះ អ៊ីចឹងទូលបង្គំខ្ញុំបាទសូមមានយោបល់តែត្រឹមប៉ុណ្ណេះ ។

**សម្តេច ហេង សំរិន**: ឯកឧត្តរដ្ឋមន្ត្រីមានមតិអ៊ីបន្ថែមទេ? រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានមតិទេ? សូមថែមបាទ ។

**ឯកឧត្តម អ៊ុក ឌិធន់:** សុំគោរពសម្តេចអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ អង្គប្រជុំសភាដ៏ខ្ពង់ខ្ពស់ ចំពោះសំណួរអាជ្ញាយុកាលប្រតិសកម្មនៃច្បាប់របស់ឯកឧត្តមអ្នកតំណាងរាស្ត្រដ៏ខ្ពង់ខ្ពស់ បានសួរឯកឧត្តមទេសរដ្ឋមន្ត្រីដូចបានជម្រាបអស់ហើយ ធម្មតាប្រតិសកម្មនៃច្បាប់ទូទៅវាមាន ប៉ុន្តែនៅក្នុងអង្គប្រជុំវិសាមញ្ញនេះដែលគេបានកំណត់ច្បាស់ពីថ្ងៃ១៧ មេសា ៧៥ ដល់៦ មករា ៧៩ អ្នកជំនាញការច្បាប់ ច្បាប់អន្តរជាតិទាំងអស់បានឯកភាពគ្នាជាគោលការណ៍ថា ចំពោះច្បាប់ពិសេសនេះ អង្គប្រជុំវិសាមញ្ញនេះ គោលការណ៍ប្រតិសកម្មនៃច្បាប់ដែលពន្យារបន្ថែម២០ឆ្នាំទៀត គឺគ្មានទេ សូមអរគុណ ។

**សម្តេច ហេង សំរិន**: បាទសូមអញ្ជើញឯកឧត្តម

**ឯកឧត្តម ម៉ោញ សាផាន:** ទូលបង្គំខ្ញុំបាទសូម អានេះប្រហែលជាបច្ចេកទេសក្នុងការវាយអង្គុលីលេខ ព្រោះនៃមាត្រា១ កន្លែងនៃ ថ្ងៃ១៧ មេសា ៧៥ អូស ១៩៧៥ ដល់ថ្ងៃ៩ មករា ១៩៧៩ អង្គសភាបានអនុម័តហើយ ហើយនៃ ៩៦លើ ៩៦ អ៊ីចឹងទូលបង្គំខ្ញុំបាទសូមនៃ មាត្រាក្រោយនេះទៀត សូមកុំដាក់ឆ្នាំ មាត្រា៣សុំលុបចោលដែលដាក់ថាឆ្នាំ១៩៧៥ ឆ្នាំ១៩៧៩ អ៊ីចឹងសុំលុបចោល មានតែឆ្នាំ គឺនៅមាត្រា៣ មាត្រា៤ មាត្រា៥ និងមាត្រា៦ដែលមានពាក្យឆ្នាំ គឺសុំលុបចោលមាត្រា៧មួយទៀតនិងមាត្រា៨ទៀតដើម្បីឲ្យវាតាមដែលខ្លឹមសារដែលកាលពីអនុម័តនៅជំពូកទី១ អ៊ីចឹងពាក្យដែលមានឆ្នាំសុំមេត្តាលុបចោល សូមអរគុណៗ ។

**សម្តេច ហេង សំរិន:** បាទអញ្ជើញឯកឧត្តម

**ឯកឧត្តម ឈួរ លាងហួត:** សូមអរគុណដល់សម្តេចប្រធានអង្គប្រជុំ ហើយសូមគោរពអង្គប្រជុំ ខ្ញុំបាទឡើងមកនេះដើម្បីបញ្ជាក់បន្ថែមនូវអ៊ីដែល

ឯកឧត្តម ជាម យៀប បានលើកគឺអំពីពាក្យថាសាលាដំបូងឬតុលាការខេត្តក្រុងនេះ ហើយអម្បាញ់មិញឯកឧត្តមតំណាងរាជរដ្ឋាភិបាលក៏បានឆ្លើយហើយដែរ ។ ខ្ញុំបាទឡើងមកនេះគ្រាន់តែយកឯកសារពិតប្រាកដដែលគេមានប្រើពាក្យនេះហើយ ។ ខ្ញុំបាទសូមជម្រាបជូនអង្គសភាយើងត្រង់ពាក្យថា នៅក្នុងបទបញ្ញត្តិស្តីពីប្រពន្ធ័តុលាការដែលរៀបចំឡើងដោយអ៊ុនតាក់ ហើយដែលបានក្រុមប្រឹក្សាជាតិជាន់ខ្ពស់អនុម័តនៅថ្ងៃ១០ កញ្ញា ៩២ បានចែងនៅក្នុងមាត្រា៣ស្តីអំពីសាលាជម្រះក្តី ហើយក្នុងនោះគេបានចែងថា ដោយសហការ ដោយមានសហការជាមួយអ៊ុនតាក់ភាគីកម្ពុជាទាំងអស់សន្យាថានឹងចាត់ចែងឲ្យមានសាលាដំបូងមួយយ៉ាងតិចនៅក្នុងតំបន់ឬខេត្តណាដែលខ្លួនមិនទាន់បានចាត់តាំង ។ ដូច្នេះតុលាការសាលាដំបូងនេះ គឺជាតុលាការដែលចាត់តាំងនៅក្នុងខេត្តនីមួយៗ ហើយដូចឯកឧត្តមបានលើកអម្បាញ់មិញអ៊ីចឹង គឺថាសាលាដំបូងគឺជាតុលាការខេត្តក្រុង ។ នេះគឺថាពាក្យសាលាដំបូងនេះមានប្រើនៅក្នុងច្បាប់អន្តរកាលរបស់យើង ។ ហើយក្នុងនោះដែរ ពាក្យថាភាគីកម្ពុជានេះកាលជំនាន់ហ្នឹងយើងដឹងហើយមានពីរភាគី ភាគីរដ្ឋកម្ពុជាមួយ ហើយក្នុងភាគីរដ្ឋកម្ពុជានោះដែលមានការគង់វង្សដែលហៅថាធ្វើទាំងស្រុងអ៊ីចឹងហើយប្រពន្ធ័តុលាការខេត្តក្រុងហ្នឹងមានស្រាប់ហើយ អ៊ីចឹងអត់មានចាំបង្កើតអីទៀតទេ យកតុលាការខេត្តក្រុងនេះទៅប្រើការមកទល់នឹងសព្វថ្ងៃនេះតែម្តង ។ នេះសូមជម្រាបជូនអង្គសភាសូមមេត្តាជ្រាបថា សាលាដំបូងនេះមាននៅក្នុងមាត្រា៣នៃច្បាប់នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការឆ្នាំ១៩៩២ ។ សូមអរគុណ ឯកឧត្តមប្រធាន អីសម្តេចប្រធាន ។

**សម្តេច ហេង សំរិន:** អ៊ីចឹងបើអង្គសភាពុំមានមតិអីបន្ថែមទៀតទេ សូមធ្វើការអនុម័តនូវជំពូកទី២ ជា ទ ។

**អគ្គលេខាធិការនៃរដ្ឋសភា:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យលើជំពូក២ មានចំនួន៩៤លើ៩៤ ។ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិន:** ក្រោយពីការអនុមត័លើជំពូកទី២ សូមអញ្ជើញប្រធានគណៈកម្មការអាននូវជំពូកទី៣ ។

**ឯកឧត្ត ម៉ោញ សាផាន:** ជំពូកទី៣ៈ សមាសភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ មាត្រា៩ៈ សាលាដំបូងជាអង្គជំនុំជម្រះវិសាមញ្ញដែលចៅក្រមវិជ្ជាជីវៈ៥រូបដែលរួមមានចៅក្រមខ្មែរ៣រូប មួយរូបធ្វើជាប្រធាននិងមានចៅក្រមបរទេស២រូប និងក្រឡាបញ្ជី១រូបឬច្រើនរូបតាមការចាត់តាំងរបស់ប្រធានចូលរួមព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខសាលាដំបូងនេះ ។ សាលាឧទ្ធរណ៍ជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រម៧រូបដែលរួមមានចៅក្រមខ្មែរ៤រូប ដែលមួយរូបធ្វើជាប្រធាន និងចៅក្រមបរទេស៣រូប និងមានក្រឡាបញ្ជី១រូបឬច្រើនរូបតាមការចាត់តាំងរបស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខសាលាឧទ្ធរណ៍នេះ ។ តុលាការកំពូលជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រម៩រូបដែលរួមមានចៅក្រមខ្មែរ៥រូប ដែលមួយរូបធ្វើជាប្រធាន និងចៅក្រមបរទេស៤រូប និងមានក្រឡាបញ្ជី១រូបឬច្រើនរូបតាមការចាត់តាំងរបស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខតុលាការកំពូលនេះ ។ អ៊ីចឹងនៅក្នុងជំពូកទី៣នេះ គឺនិយាយអំពីសមាសភាពចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញ ។ ទូលបង្គំខ្ញុំបាទសូមសរុបថានៅសាលាដំបូងមានចៅក្រម៥រូប ខ្មែរ៣រូប បរទេស២រូប ។ ចៅក្រមខ្មែរ៣រូបនិងមួយរូបជាប្រធាន ហើយបន្ទាប់មកមានក្រឡាបញ្ជីតាមការចាត់តាំងរបស់ប្រធាន២រូបក៏បាន ៣រូបក៏បានតាមតម្រូវការ ហើយនឹងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខសាលាដំបូង ។ សាលាឧទ្ធរណ៍មានចៅក្រម៥រូបសម្រាប់នៃជំនុំ...អឺ ៧រូបសម្រាប់អង្គចំនុំជម្រះវិសាមញ្ញ ៧រូបនោះមានខ្មែរ៤រូប ១រូបជាប្រធាន ហើយបរទេស៣រូប ។ នៅតុលាការកំពូលមាន៩រូប ចៅក្រមខ្មែរ៥រូប មួយរូបធ្វើជាប្រធាន និងចៅក្រមបរទេស៤រូប ។ អ៊ីចឹងនេះជាសមាសភាពនៃសាលានៃអង្គជំនុំជម្រះវិសាមញ្ញនៅគ្រប់លំដាប់ថ្នាក់នៃតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។ ទូលបង្គំខ្ញុំបាទសូមដាក់ជូននូវជំពូកទី៣ ថ្វាយនិងជូនអង្គសភាដើម្បីពិភាក្សានិងអនុមត័តាមការគួរ ។ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិន:** សូមអង្គសភាពិភាក្សានូវជំពូកទី៣បាទ!.... បើអង្គសភាមិនមានមតិលើជំពូកទី៣ទេសូមធ្វើការអនុមត័ ។

**អគ្គលេខាធិការនៃរដ្ឋសភា:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យលើជំពូក៣ មាន៩៣លើ៩៤ ។ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹងបន្ទាប់ពីការអនុមត័នៅជំពូកទី៣ សូមអញ្ជើញប្រធានគណៈកម្មការអាននូវជំពូកទី៤ ។

**ឯកឧត្តម ម៉ោញ សាផាន:** ជំពូកទី៤ៈ ការតែងតាំងចៅក្រមជម្រះ ក្តីមាត្រា១០ៈ ចៅក្រមជម្រះក្តីនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានជ្រើសតាំង

*ក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់មិនលម្អៀង និងសុចរិត មានបទពិសោធន៍ខាងក្នុងការងារជំនាញ ជាពិសេសខាងច្បាប់ព្រហ្មទណ្ឌឬច្បាប់អន្តរជាតិ ។ ចៅក្រមជម្រះក្តីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួលឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។ មាត្រា១១ៈ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមខ្មែរយ៉ាងតិច១២រូបឲ្យធ្វើជាចៅក្រមជម្រះក្តីសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ និងជ្រើសតាំងចៅក្រមជម្រះក្តីបម្រុងមួយចំនួនតាមតម្រូវការ ព្រមទាំងត្រូវជ្រើសតាំងផងដែរនូវប្រធាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងចំណោមចៅក្រមខ្មែរខាងលើ តាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ។ ចៅក្រមបម្រុងខ្មែរត្រូវធ្វើចៅក្រមជម្រះក្តីខ្មែរពេញសិទ្ធិនៅពេលដែលចៅក្រមនេះអវត្តមានឬមានធុរៈ ។ ចៅក្រមជម្រះក្តីទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងយ៉ាងតិចបុគ្គល៩រូបដែលមានសញ្ជាតិបរទេសឲ្យធ្វើជាចៅក្រមជម្រះក្តីបរទេសសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ក្រោយពីការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនជាចៅក្រមបរទេសដែលមានចំនួនយ៉ាងតិច១២រូប ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមពេញសិទ្ធិ៩រូប និងចៅក្រមបម្រុងយ៉ាងតិច៣រូបពីក្នុងបញ្ជីឈ្មោះនោះ ។ បន្ថែមពីចៅក្រមបរទេសដែលចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងដែលមានវត្តមាននៅគ្រប់ដំណាក់កាលនៃដំណើរការជំនុំជម្រះ ប្រធានអង្គជំនុំជម្រះវិសាមញ្ញអាចចាត់តាំងតាមប្រក្រតីនីមួយៗនូវចៅក្រមបម្រុងមួយរូប ឬច្រើនរូបដែលបានជ្រើសរើសរួចហើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយមានវត្តមាននៅដំណាក់កាលជំនុំជម្រះនីមួយៗ ហើយឲ្យជំនួសចៅក្រមបរទេស ប្រសិនបើចៅក្រមរូបនោះពុំមានលទ្ធភាពអាចបន្តការជំនុំជម្រះតទៅទៀតបាន ។ មាត្រា១២ៈ ចៅក្រមជម្រះក្តីទាំងអស់ដែលស្ថិតនៅក្រោមច្បាប់នេះ មានឋានៈនិងលក្ខខណ្ឌការងារស្មើៗគ្នាទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ។ ចៅក្រមជម្រះក្តីមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។ មាត្រា១៣ៈ ចៅក្រមជម្រះក្តីត្រូវមានបុគ្គលិកខ្មែរនិងបុគ្គលិកអន្តរជាតិជាជំនួយការទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន ។ ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការនិងអ្នកជំនួយការច្បាប់ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ក្នុងករណីចាំបាច់ និងត្រូវមានការយល់ព្រមដោយមតិភាគច្រើនពីចៅក្រមខ្មែរក្នុងការជួលបុគ្គលិកដែលនឹងត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកអន្តរជាតិទាំងអស់ ។ ចំនួនបុគ្គលិកនិងអ្នកជំនួយការច្បាប់ត្រូវជ្រើសរើសទៅតាមសមាមាត្រនៃចៅក្រមខ្មែរនិងចៅក្រមបរទេស ។ បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋឬជនជាតិខ្មែរដទៃទៀតដែលមានសមាសភាពក្នុងករណីចាំបាច់ ។ នៅក្នុងជំពូកនេះគឺការតែងតាំងចៅក្រមទាំងបរទេស ទាំងខ្មែរ គឺនៅលើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ហើយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញគឺត្រូវមានចៅក្រម ត្រូវតែងតាំងចៅក្រមពេញសិទ្ធិយ៉ាងតិច១២រូប ហើយនិងចៅក្រមបម្រុងអី៩រូប ហើយនិងចៅក្រមបម្រុង៣រូប ក្នុងហ្នឹងទាំងអស់វា១២រូប ។ នៅក្នុងនេះបន្ទាប់មកទៀតអំពីប្រធានការិយាល័យរដ្ឋបាល ប្រធានការិយាល័យរដ្ឋបាល គឺជាខ្មែរដែលគ្រប់គ្រងប្រធានការិយាល័យរដ្ឋបាល ហើយជាអនុប្រធានការិយាល័យរដ្ឋបាលគ្រប់គ្រងដោយបរទេស គឺឲ្យបរទេសធ្វើជាអនុប្រធានការិយាល័យរដ្ឋបាលសម្រាប់មើលបុគ្គលិកដែលជាបរទេសដែលផ្ញើមកតាមបញ្ជីនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ចំណែកឯបុគ្គលិកខ្មែរគឺប្រធានជាអ្នកគ្រប់គ្រង ហើយដែលជ្រើសរើសពីនៅក្នុងបុគ្គលិកមន្ត្រីរាជការនៃរាជរដ្ឋាភិបាល ។ អ៊ីចឹងនៅក្នុងហ្នឹងគឺការតែងតាំងចៅក្រមទាំងអស់គឺស្ថិតនៅលើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលជាស្ថាប័នគ្រប់គ្រងជាយន្តការគ្រប់គ្រងស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។ ទូលបង្គំខ្ញុំបាទសូមដាក់ជូននូវជំពូកទី៤ ថ្វាយនិងជូនអង្គសភាដើម្បីពិភាក្សានិងអនុម័តតាមការគួរ ។ សូមអរព្រះគុណ និងអរគុណ ។*

**សម្តេច ហេង សំរិន:** *សូមអញ្ជើញអង្គសភាទាំងមូលដើម្បីពិភាក្សានូវជំពូកទី៤ ។...អ៊ីចឹងបើអង្គសភាមិនមានមតិយោបល់នូវជំពូកទី៤ទេ សូមធ្វើការអនុមត័ដោយលើកដៃ ។*

**អគ្គលេខាធិការនៃអង្គប្រជុំ:** *សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធានអង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី៤នៃច្បាប់នេះមាន៩៣លើ៩៤ ។ សូមអរព្រះគុណ និងអរគុណ ។*

**សម្តេច ហេង សំរិន:** *បន្ទាប់ពីការអនុមត័នូវជំពូកទី៤ សូមអញ្ជើញលោកប្រធានគណៈកម្មការអាននូវជំពូកទី៥ ។*

**ឯកឧត្តម ម៉ោញ សាផាន:** *ជំពូកទី៥ៈ ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ មាត្រា១៤ៈ ១) ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឲ្យ*

បានភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន ។ ប្រសិនបើភាពឯកច្ឆ័ន្ទនេះពុំអាចរកបានទេ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោមៈ ក) ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងតម្រូវឲ្យមានការបោះឆ្នោតគាំទ្រពីចៅក្រម៤រូបយ៉ាងតិច ។ ខ) ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍តម្រូវឲ្យមានការបោះឆ្នោតគាំទ្រពីចៅក្រម៥រូបយ៉ាងតិច ។ គ) ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកំពូលតម្រូវឲ្យមានការបោះឆ្នោតគាំទ្រពីចៅក្រម៦រូបយ៉ាងតិច ។ ២) នៅពេលដែលពុំមានភាពឯកច្ឆ័ន្ទនោះទេសេចក្តីសម្រេចនៃអង្គជំនុំជម្រះត្រូវកត់ត្រាទុកនូវយោបល់របស់មតិភាគច្រើននិងមតិភាគតិច ។ មាត្រា១៥ៈ ប្រធានត្រូវធ្វើការកោះប្រជុំចៅក្រមដែលបានតែងតាំងនៅក្នុងរយៈពេលសមស្រមដើម្បីដំណើរនៃអង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងជំពូកនេះគឺនិយាយអំពីការសម្រេច ។ ការសម្រេចនេះគឺត្រូវមានភាពជាឯកច្ឆ័ន្ទ ប៉ុន្តែបើអត់មានភាពជាឯកច្ឆ័ន្ទទេ ការសម្រេចទាំងឡាយត្រូវយកតាមមតិភាគច្រើនលើសលប់ បានន័យថានៅសាលាដំបូងមានចៅក្រម៥ត្រូវយក៤ អ៊ីចឹងបានន័យថានៅក្នុងនោះមានសំឡេងបរទេសមួយចូលរួម ។ គឺ៤សំឡេងគឺ៥ ស្មើ៣ បរទេស២ អ៊ីចឹងត្រូវយក៤ត្រូវចាំបាច់តែមានបរទេសម្នាក់ចូលរួម អាហ្នឹងជាការសម្រេចនៅសាលាដំបូង ។ ការសម្រេចនៅសាលាឧទ្ធរណ៍ គឺត្រូវមានការគាំទ្រ៥រូប ។ អ៊ីចឹងខ្មែរនៅសាលាឧទ្ធរណ៍មានខ្មែរ៤ បរទេស៣ អ៊ីចឹងការសម្រេចត្រូវយក៤រូប អឺយក៥រូប អ៊ីចឹងវាត្រូវមាន បរទេសមួយរូបចូលរួម ។ បើនៅតុលាការកំពូល ចៅក្រមវា៩រូប អ៊ីចឹង ការសម្រេចត្រូវយក៦រូប ។ បើក្នុង៩រូបហ្នឹង ខ្មែរ៥ បរទេស៤ ដល់សម្រេចយកតែ៦រូប គឺត្រូវមានបរទេសមួយរូបចូលរួម ។ អាណឹងខ្លឹមសារអត់មានដាក់អ៊ីចឹងទេ ប៉ុន្តែក្នុងន័យដែលសរសេរយ៉ាងដូច្នេះ ។ អ៊ីចឹងហើយគឺថាទូលបង្គំខ្ញុំបាទសូមសង្ខេបតែប៉ុណ្ណេះ ហើយសូមដាក់ជូនជំពូកទី៥ ថ្វាយនិងជូនអង្គសភាពិភាក្សានិងអនុម័តតាមការគួរ ។ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិនៈ** អ៊ីចឹងសូមអង្គសភាទាំងមូលពិភាក្សាលើជំពូកទី៥ ។...អ៊ីចឹងបើអង្គសភាមិនមានពិភាក្សាលើជំពូកទី៥ទេ សូមធ្វើការអនុម័តបាទ ។

**អគ្គលេខាធិការនៃរដ្ឋសភាៈ** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន និងអង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី៥ លើសេចក្តីព្រាងច្បាប់នេះមានចំនួន៩៤លើ៩៤ ។ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិនៈ** បន្ទាប់ពីការអនុម័តនូវជំពូកទី៥ ហើយសូមអញ្ជើញប្រធានគណៈកម្មការអាននូវជំពូកទី៦ ។

**ឯកឧត្តម ម៉ោង សាផានៈ** ជំពូកទី៦ៈ សហព្រះរាជអាជ្ញា មាត្រា១៦ៈ រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ គឺជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថាសហព្រះរាជអាជ្ញាដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំឯកសារនិងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។ មាត្រា១៧ៈ សហព្រះរាជអាជ្ញានៃសាលាដំបូងមានសិទ្ធិប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ។ សហព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍មានសិទ្ធិប្តឹងសារទុក្ខពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍ ។ មាត្រា១៨ៈ ឧត្តម ក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរមួយចំនួនតាមតម្រូវការពីក្របខ័ណ្ឌចៅក្រមវិជ្ជាជីវៈខ្មែរ ។ ព្រះរាជអាជ្ញាបម្រុងត្រូវជំនួសព្រះរាជអាជ្ញាពេញសិទ្ធិនៅពេលដែលព្រះរាជអាជ្ញានោះអវត្តមានឬមានធុរៈ ។ ព្រះរាជអាជ្ញាទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជំនុំជម្រះក្តីដែលខ្លួនកំពុងបំពេញ ។ ព្រះរាជអាជ្ញាបរទេសមួយរូបដែលមានសមត្ថកិច្ចបង្ហាញខ្លួនក្នុងគ្រប់លំដាប់ថ្នាក់ទាំងបីនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោយពីការជ្រើសរើសឲ្យឈរឈ្មោះ ដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ជាសហព្រះរាជអាជ្ញាបរទេសជូនរាជរដ្ឋាភិបាលកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញាពេញសិទ្ធិមួយរូប និងព្រះរាជអាជ្ញាបម្រុងមួយរូបអ៊ីចឹងពីបញ្ជីបេក្ខជននេះ ។ មាត្រា១៩ សហព្រះរាជអាជ្ញាត្រូវបានជ្រើសតាំងក្នុងចំណោមបុគ្គលទាំងឡាយដែលបានជ្រើសតាំងតាមនីតិវិធីនៃការជ្រើសតាំងព្រះរាជអាជ្ញា ហើយដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់ សុចរិត និងមានបទពិសោធន៍ ជំនាញក្នុងការធ្វើការស៊ើបអង្កេតនិងក្នុងការចោទប្រកាន់រឿងក្តីព្រហ្មទណ្ឌ ។ សហព្រះរាជអាជ្ញាត្រូវឯករាជ្យក្នុងការបំពេញនូវមុខងាររបស់ខ្លួន និងមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពមួយផ្សេងទៀតឡើយ ។ មាត្រា២០ សហព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមានប្រសិនបើចាំបាច់ ហើយនីតិវិធីនៅជាធរមានមានការខ្វះចន្លោះនោះ សហព្រះរាជអាជ្ញាអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលមានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាត្រូវអនុវត្តគោលការណ៍ដូចខាងក្រោមៈ ការចោទប្រកាន់ត្រូវបន្តដរាបណាសហព្រះរាជអាជ្ញា ឬក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេល៣០ថ្ងៃថាភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយដោយអនុលោមតាមបទបញ្ញត្តិដូចខាងក្រោមៈ សហព្រះរាជអាជ្ញាត្រូវដាក់ជូនកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុនិងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នារបស់គេដល់ប្រធានការិយាល័យរដ្ឋបាល ។ ភាពខ្វែងយោបល់គ្នាត្រូវ

ដោះស្រាយភ្លាមដោយអង្គបុរេជំនុំជម្រះដែលមានចៅក្រម៥រូប ចៅក្រមខ្មែរ៣រូបត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានចៅក្រមមួយរូបជាប្រធាន ហើយនិងចៅក្រមបរទេស២រូបត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបន្ទាប់ពីមានការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការជ្រើសរើសចៅក្រមខាងលើនេះត្រូវអនុវត្តតាមបទបញ្ញត្តិនៃមាត្រា១០នៃច្បាប់នេះ ។ បន្ទាប់ពីទទួលបានកំណត់ហេតុដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌទី៣ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយត្រូវជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឲ្យមានបណ្តឹងឧទ្ធរណ៍តម្រូវឲ្យមានសំឡេងវិជ្ជមានពីចៅក្រម៤រូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងទៅដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាត្រូវចាត់ការបន្តជាបន្ទាន់ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។ ប្រសិនបើពុំមានមតិភាគច្រើនដូចតម្រូវឲ្យមានចំពោះការធ្វើសេចក្តីសម្រេចទេ ការចោទប្រកាន់ត្រូវធ្វើបន្តទៅទៀត ។ ក្នុងពេលធ្វើការចោទប្រកាន់ សហព្រះរាជអាជ្ញាអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាប្រសិនបើការជួយឧបត្ថម្ភនេះពិតជាមានប្រយោជន៍ចំពោះការចោទប្រកាន់ ហើយការជួយឧបត្ថម្ភនេះត្រូវតែផ្តល់ជូន ។ មាត្រា២១ៈ សហព្រះរាជអាជ្ញាទាំងអស់ដែលឋិតក្រោមច្បាប់នេះមានឋានៈ និងលក្ខខណ្ឌការងារស្មើៗគ្នាទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ព្រះរាជអាជ្ញាមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។ ក្នុងករណីដែលព្រះរាជអាជ្ញាបរទេសអវត្តមានឬមានធុរៈត្រូវជំនួសដោយព្រះរាជអាជ្ញាបម្រុង ។ មាត្រា២២ៈ សហព្រះរាជអាជ្ញាមួយរូបៗមានសិទ្ធិជ្រើសរើសព្រះរាជអាជ្ញារងមួយរូបឬច្រើនរូបដើម្បីជួយខ្លួន ។ ក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះព្រះរាអាជ្ញារងបរទេសត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពីបញ្ជីផ្តល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ សហព្រះរាជអាជ្ញាត្រូវមានបុគ្គលិកខ្មែរនិងបុគ្គលិកអន្តរជាតិជាជំនួយការទៅតាមតម្រូវការដាក់ស្តែងសម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួនក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ក្នុងករណីចាំបាច់និងត្រូវមានការយល់ព្រមពីសហព្រះរាជអាជ្ញាខ្មែរក្នុងការជួលបុគ្គលិកដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិកបរទេសទាំងអស់ចំនួនបុគ្គលិកជំនួយការត្រូវជ្រើសរើសតាមសមាមាត្រព្រះរាជអាជ្ញាខ្មែរនិងព្រះរាជអាជ្ញាបរទេស ។ បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌរដ្ឋឬជនជាតិខ្មែរដទៃទៀតដែលមានសមត្ថភាពក្នុងករណីចាំបាច់ ។...នៅក្នុងជំពូកទី៦ នេះគឺចង់បញ្ជាក់អំពីខ្លឹមសាររួមគឺថាចង់បញ្ជាក់អំពីដំណោះស្រាយដែលមានភាពខ្វែងគ្នានៃរបស់ដែលហៅថាការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ។ នៅពេលដែលសហព្រះរាជអាជ្ញាគឺមានភាពខុសគ្នាក្នុងការចោទប្រកាន់ ឧទាហរណ៍ថាមួយឲ្យចោទ ហើយមួយមិនឲ្យចោទ នៅក្នុងហ្នឹងត្រូវមានបង្កើតឲ្យមានអង្គបុរេជំនុំជម្រះមួយសម្រាប់ដោះស្រាយបញ្ហាហ្នឹង ហើយអង្គបុរេជំនុំជម្រះហ្នឹងគឺត្រូវមានចៅក្រម ចៅក្រម៥រូបៗសម្រាប់ដោះស្រាយពេលទំនាស់រវាងសហព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ហើយបើខ្មែរ៣ បរទេស២ ហើយចៅក្រមអូស៉សហព្រះរាជអាជ្ញាហ្នឹងគឺអាចចាត់តាំងព្រះរាជអាជ្ញាបម្រុង អូស៉ព្រះរាជអាជ្ញារងសម្រាប់ជួយការងារទៀត ហើយខ្មែរយើងថា ក្នុងការចាត់តាំងសហព្រះរាជអឺ ក្នុងការចាត់តាំងព្រះរាជអាជ្ញាបម្រុងនឹងគឺត្រូវឧត្តមក្រុមប្រឹក្សាអង្គចៅក្រមអ្នកតែងតាំង ហើយបរទេសគឺគេផ្ញើតាមបញ្ជីរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ឯចៅក្រមខ្មែរយើងគឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយចំណែកឯបុគ្គលិកក៏ដូចគ្នា សហត្រូវព្រះរាជអាជ្ញាត្រូវមានបុគ្គលិកបម្រើការដែរគឺខ្មែរបានមកពីរាជរដ្ឋាភិបាល ។ ចំណែកឯបុគ្គលិកបរទេសគឺផ្តល់មកតាមបញ្ជីរបស់អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ហើយបញ្ហាមួយទៀត បញ្ហាដែលសំខាន់គឺថានឹងអាចស្វែងរកការជួយពីរាជរដ្ឋាភិបាល ហើយរាជរដ្ឋាភិបាលគឺត្រូវតែផ្តល់នូវការជួយឧបត្ថម្ភជាចាំបាច់ដែលមានចែងនៅក្នុងច្បាប់នេះ គឺថារាជរដ្ឋាភិបាលត្រូវតែឧបត្ថម្ភចំពោះការដែលស្នើសុំរបស់សហព្រះរាជអាជ្ញា អឺចឹងនៅក្នុងខ្លឹមសារនៅជំពូកទី៦នេះ ទូលបង្គំខ្ញុំបាទសង្ខេបតែប៉ុណ្ណេះ ហើយសូមដាក់ជូនអង្គសភាពិភាក្សានិងអនុម័តតាមការគួរ ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេច ហេង សំរិន :** សូមអញ្ជើញអង្គសភាយើងពិភាក្សានៅជំពូកទី៦ ។... អឺចឹងអង្គសភាមិនមានមតិអីនៅចំពូកទី៦នេះ គឺឯកភាព បើឯកភាពនៅលើជំពូកទី៦នេះ សូមអង្គសភាទាំងមូលធ្វើការអនុម័ត ។

**អគ្គលេខាធិការនៃអង្គប្រជុំ:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី៦លើសេចក្តីព្រាងនៃច្បាប់នេះមាន៩៤លើ៩៤ សូមអរព្រះគុណ អរគុណ ។

**(នៅមានត)**

# ទទួលបានប៉ុនណាបាត់ទៅវិញប៉ុណ្ណឹង

ជំនោរបក់មកពីកំពូលភ្នំហិមាល័យបាននាំមកនូវខ្យល់ត្រជាក់ដល់ទំនាបអន្ទរសាជាថ្មីម្តងទៀតដូចកាលពីសម័យយូរលង់ណាស់មកហើយ ។ វាលស្រែល្វឹងល្វើយដាច់កន្ទុយភ្នែករំលេចដោយពណ៌ខៀវខ្ចីមួយរយៈក្រោយមកត្រូវបានហ៊ុមព័ទ្ធដោយជំនោរត្រជាក់ដែលប្រែក្លាយវាលស្រែទៅជាពណ៌លឿងទុំដូចកម្រាលមាស ។ ដើមស្រូវបក់បោកបេរាំម្តងឆ្វេងម្តងស្តាំទៅតាមខ្យល់ ។ សត្វសេកនិងបក្សាបក្សីដទៃទៀតបានមកជុំគ្នាចចឹកចំណីនៅក្នុងទីវាលពណ៌មាសនេះ ។ មនុស្សម្នានិងសត្វទាំងឡាយខំរកទឹកក្តៅនៅជុំវិញភ្លក់ភ្លើងនារាល់ពេលព្រឹកព្រលឹម ។ មិនយូរប៉ុន្មានស្រូវក៏ទុំ ហើយរដូវច្រូតកាត់ក៏មកដល់ ។ បន្ទាប់មកមានការប្រារព្ធពិធីស្តារលានយ៉ាងអធឹកអធមដែលជាពេលមួយបោសជម្រះនូវគំនិតចាស់ហើយចាប់យកគំនិតនិងព្រលឹងថ្មីវិញ ។

ក៏ប៉ុន្តែទាំងអស់នេះមិនមែនដូច្នេះឡើយ ។ ប្រជាជនស្ថិតនៅក្រោមអំណាចដ៏តឹងរ៉ឹងរបស់អង្គការនៅឡើយទេ ។ នៅមានកិច្ចការច្រើនណាស់ដែលត្រូវធ្វើ ហើយប្រជាជនកំពុងតែស្ថិតនៅក្រោមរបបខ្មែរក្រហមនៅឡើយ ។

ពេលគឺនៅខែធ្នូ ឆ្នាំ១៩៧៨ អាហារហូបចុកមានគ្រប់គ្រាន់ហើយឥឡូវនេះ ប៉ុន្តែអង្គការរកអាហារឲ្យតែមួយគ្រប់ៗតាមរបបកំណត់តែប៉ុណ្ណោះ ។ ប្រជាជននៅតែទទួលបបររាវប៉ុន្តែគ្មានបន្លែ និងរុក្ខជាតិលាយទេ ។ ខ្ញុំគិតថាបាយសុទ្ធហូបមិន



ឆ្ងាញ់ទេ ។

ការផ្តោតសំខាន់មុនបង្អស់គឺការសម្រុកប្រូតកាត់ប្រមូលផលស្រូវឲ្យបានស្រួតតាមតែអាចធ្វើទៅបាន ។ ប្រជាជននៅតែធ្វើការច្រើនម៉ោងដដែល គ្រាន់តែមានបរិយាកាសធូរស្រាលជាងមុន ។ មានមនុស្សតិចតួចដែលស្លាប់បាត់បង់ជីវិតដោយសារជំងឺ ។ អង្គការតឹងតែងណាស់ ប៉ុន្តែគ្មានអ្នកណាម្នាក់ត្រូវបានសម្លាប់ចោលឡើយចាប់ពីការបង្កើតរដ្ឋបាលថ្មីមក ។ អង្គការនៅតែបញ្ជាឲ្យយើងធ្វើការជាទម្ងន់ដដែល ប៉ុន្តែក្រោមនយោបាយស្លូត ។ ពលករួមទាំងប្រជាជន “មិត្តថ្មី” នៅតាប៉ាងត្រូវបានផ្តល់រង្វាន់លើកទឹកចិត្តឲ្យមានការសម្រាក និងមានថែមរបបហូបចុកដោយសារតែខ្លួនបានធ្វើការចប់ចុងចប់ដើម ។ មានការផ្លាស់ប្តូរដល់ម្ល៉ឹងផង! មិនថាយប់មិនថាថ្ងៃទេ នេះពិតជាការផ្លាស់ប្តូរមួយ ។

និយាយតាមត្រង់ខ្ញុំហាក់ដូចជាឡើងទម្ងន់និងមានសុខភាពជាងមុនបន្តិចដែរ ។ ខ្ញុំបានបាក់ធ្មេញថ្គាមក្រោមអស់២ ហើយដង្កូវស៊ីធ្មេញអស់ជាច្រើន ។ ចំពោះខ្ញុំ “បាយស្ងួ” ពុំចាំបាច់មានម្ហូបនៅឆ្ងាញ់នៅឡើយទេ ។ ប្រជាជនបានធ្វើការនៅជាប់ផ្ទះនិងជួយធ្វើកិច្ចការនៅជិតៗភូមិដ្ឋាន ។ ឥឡូវនេះខ្ញុំមានពេលរស់នៅក្នុងកូនខ្ទមរបស់ខ្ញុំច្រើនជាងកាលពី២ឆ្នាំមុន ។ នៅក្រោមអង្គការខ្ញុំមានពេលទំនេរច្រើន ។ ខ្ញុំប្រកបរបរឡើងត្នោតនិងមុខរបរកំប៉ិកកំប៉ុកបន្តិចបន្តួចនៅមុខផ្ទះ ។ ខ្ញុំបានរកត្រីនិងក្តាមស្រែដើម្បីបន្ថែមអាហាររបស់យើងនៅពេលយប់ ។ មិនយូរប៉ុន្មានស្ករត្នោតក៏ក្លាយជាបន្ថែមយ៉ាងពិសេសដែលគ្មានអ្នកណាគិតដល់កាលពីរបីខែកន្លងទៅក្រោមរបបអង្គការចាស់ ។ ការធ្វើដំណើរនៅមានការកម្រិតតឹងតែង ប៉ុន្តែមានការធូរស្រាលបន្តិចបន្តួចជាងមុន ។ ដោយមានការសុំការអនុញ្ញាតត្រឹមត្រូវខ្ញុំអាចធ្វើដំណើរទៅភូមិមួយទៀតនៅជិតគ្នារកប្រហុកហូប ។ នេះហើយជាជីវិត ។ ខ្ញុំគិតថាយើងមិនអាចរអ៊ូរទាំចំពោះ “ការបើកទូលាយ” ជាងកាលពីប៉ុន្មានឆ្នាំមុនដែលគ្មានសិទ្ធិសេរីភាព និងការអត់អាហារហូបចុកនោះឡើយ ។

មានពេលខ្លះអង្គការផ្តល់ជារបបបន្ថែមពិសេសសម្រាប់គ្រួសារនីមួយៗនៅក្នុងទីក្រុង ។ ខ្ញុំមិនដឹងថាតើរបបផ្គត់ផ្គង់ទាំងនេះបានមកពីណាទេដូចជាប្រេងបន្លែ ក្រណាត់ អំបិល ស្ករស និងប្រេងកាតជាដើម ។ អ្វីដែលខ្ញុំដឹងគឺថារាល់ពេលដែលចិនដឹកយកសម្ភារផ្គត់ផ្គង់ទាំងនេះគឺពេលត្រឡប់ទៅវិញចិនបានដឹកស្រូវដែលយើងទើបប្រមូលបានពេញៗរថយន្ត ។ ក្រោយមកមានរថយន្តកាន់តែច្រើនឡើងៗចូលមកដោយគ្មានគ្រឿងឧបត្ថម្ភអ្វីទៀតឡើយ ។ ពេលនោះស្រូវអង្កររបស់យើងក៏ចេះតែខ្សត់ទៅៗ ហើយផ្ទះបាយរួមរបស់យើងត្រឡប់បែរទៅមានបបររាវជាថ្មីម្តងទៀត ។ ប្រជាជន ជាពិសេសមិត្តថ្មី ក៏ទទួលការអត់ឃ្លានសាជាថ្មីទៀត ។

ក្រុមទីមួយនៃមិត្តថ្មីដែលត្រូវយកទៅគឺមិត្តរបស់ខ្ញុំឈ្មោះ ឡៃ និងគ្រួសាររបស់គាត់ ។ នៅមានគ្រួសារដទៃទៀតដែលមកជាមួយ ឡៃ ត្រូវបានយកទៅនៅពេលតែមួយ ។ មិនខុសពីមិត្តរបស់ខ្ញុំនិងគ្រួសាររបស់គាត់ទេ ប្រជាជនទាំងនេះភាគច្រើនជាស្ត្រីមេម៉ាយនិងកូនៗដែលឪពុកត្រូវបានស្លាប់ចោលមុននេះបន្តិច ។ ឥឡូវនេះដល់ពេលសម្រាប់ខ្លួនហើយ ។

យប់មុនពេលខ្មែរក្រហមយក ឡៃ និងគ្រួសារគាត់ពីតាប៉ាង ឡៃ បានមកជួបខ្ញុំទាំងទឹកមុខក្រៀមក្រំ ។ ឡៃ ដឹងក្នុងចិត្តថាខ្លួនពិតជាមិនអាចឃើញមុខខ្ញុំសាជាថ្មីទេ ។ គាត់ឈប់នៅត្រឹមកូនខ្ទមខ្ញុំ ហើយឱបខ្ញុំលាជាលើកចុងក្រោយ ។ “ខ្ញុំលាឯងសិនហើយ ។ គេយកខ្ញុំទៅថ្ងៃស្អែកហើយ” ។ ឡៃ ឈប់និយាយបន្តិចហើយសម្លឹងមើលទៅមេឃ ហើយព្រលយពាក្យថា “ចាប់ពីថ្ងៃស្អែកទៅខ្ញុំមិនដឹងថាបានមើលពន្លឺព្រះអាទិត្យម្តងទៀតដែរឬក៏អត់ទេ ។ ពេលខ្ញុំទៅសូមឯងជួយប្រាប់ ជល្លី (មិត្តស្រី) ផងថាគ្នាលាហើយ” ។

ពេលឮដំណឹងនេះខ្ញុំមិងមាំងនិយាយមិនចេញទាល់តែសោះ ។ ឡៃ បន្តទៀតថា “សម្លាញ់ឯងមិនស្លាប់ទេ ។ ស្តាប់ខ្ញុំ “ឯងមិនស្លាប់ទេ” ។ សង្ឃឹមថាសម្លាញ់ឯងនឹងបានជួបគ្រួសារវិញជាមិនខាន” ។ ឡៃ និយាយទាំងទប់ទឹកភ្នែកថា “សូមថែរក្សាខ្លួនឲ្យបានល្អណា៎” ។

ពេលនោះ ឡៃ ក៏ដើរចេញទៅ ។ ពេលដើរបានបន្តិច ឡៃ និយាយបន្ថែមថា “សូមប្រយ័ត្នផងឮទេ” ។

ឡៃ ចេះតែនិយាយតទៅទៀតពេលដើរកាន់តែឆ្ងាយៗទៅតែខ្ញុំស្តាប់មិនបានទាល់តែសោះ ។ ខ្ញុំមិនដឹងនិយាយយ៉ាងដូចម្តេចក៏ចេះតែស្ងាត់មាត់ឈឹងអឺចឹងទៅ ។ ខ្ញុំស្ថិតនៅក្នុងសភាពរន្ធត់

និងមិនអាចទទួលយកសភាពបែបនេះបានឡើយ ។ ពេលនោះខ្ញុំនិយាយតែម្នាក់ឯងថា “ចាប់ពីពេលនេះទៅ ខ្ញុំនឹងនឹកអាឡោះអាល័យដល់ ឡៃ ជារៀងរហូត” ។ នៅពេលដំបូងនៃការបែកពីគ្រួសារជាទីស្រលាញ់របស់ខ្ញុំ ខ្ញុំក៏ចាប់ផ្តើមនឹកមនុស្សម្នាក់ជាលើកទីមួយ ។ ខ្ញុំបានយំតិចៗ ហើយគ្មាននិយាយអ្វីទាំងអស់ នៅពេលដែលយោធារបស់អង្គការបណ្តើរ ឡៃ និងគ្រួសារចេញទៅ ។ ខ្ញុំបានសង្កេតឃើញមេបញ្ជាការខ្មែរក្រហមដដែល ដែលបានទាត់ក្តួចខ្ញុំកាលពីមុន ។ ម្នាក់នោះជាអ្នកដែលបានយកមេឃុំនិងចៅហ្វាយក្រុងកាលពីប៉ុន្មានខែកន្លងទៅ ។ ខ្ញុំដឹងថា ឡៃ និងអ្នកដទៃទៀត នឹងគ្មានឱកាសរស់បានឡើយ ។

បន្តិចមកខ្ញុំដឹងថាក្រោមអំណាចរបស់អង្គការជីវិតមនុស្សថោកណាស់ ។ នេះហើយជារបៀបដែលអង្គការឬអង្គការលើរបស់ខ្មែរក្រហមកាប់សម្លាប់ ។ ប្រមាណមួយសប្តាហ៍ក្រោយពីសង្គ្រាមត្រូវបានបញ្ចប់ ពោលគឺនៅក្នុងខែមេសា ឆ្នាំ១៩៧៥ កម្មាភិបាលបានបញ្ជារដ្ឋការ វេជ្ជបណ្ឌិត អ្នកច្បាប់ គ្រូបង្រៀន និងសិស្ស និស្សិត ឲ្យទៅជួបអង្គការថ្មីឬអង្គការលើ ។

ប្រជាជនជាច្រើនបានស្តាប់បញ្ជានេះ ។ មានមនុស្សជាច្រើនត្រូវបានដឹកដោយរថយន្តទ័ពជាច្រើនរយគ្រឿងទៅជួបអង្គការ ។ តាមធាតុពិតគ្មានអង្គការឬមេដឹកនាំណាមកជួបនឹងបុគ្គលទាំងនេះឡើយ ។ ផ្ទុយទៅវិញនេះគ្រាន់តែជាល្បិចកលនិងផែនការសម្លាប់ប្រជាជនទាំងនេះតែប៉ុណ្ណោះ ។ អ្នកដែលនៅក្នុងរថយន្តទាំងប៉ុន្មាននឹងប្រាកដជាស្លាប់ដោយពិតប្រាកដ ។ ជនរងគ្រោះត្រូវបានសម្លាប់ទាំងចំណងស្លាបសេកហើយទម្លាក់ទៅក្នុងរណ្តៅរាក់ៗ ។ ការសម្លាប់រង្គាលនេះមិនចាំបាច់ចំណាយគ្រាប់កាំភ្លើងមួយគ្រាប់ឡើយ ។ នេះជានយោបាយរបស់ខ្មែរក្រហមក្នុងការសន្សំសំចៃគ្រាប់កាំភ្លើងក្នុងពេលសម្លាប់មនុស្ស ។ ខ្មែរក្រហមបានប្រើដំបងប៉ុនកំភួនដៃវាយចំកញ្ចឹងកជនរងគ្រោះទាល់តែស្លាប់ ។ នេះជារបៀបសម្លាប់មនុស្សដ៏សាហាវយង់ឃ្នងនិងងាយបំផុត ។

របៀបសម្លាប់នេះត្រូវបានដឹងជាទូទៅ ហើយខ្ញុំបានឃើញជាច្រើនលើកមកហើយ ។ “វាលពិឃាត” មិនដែលជាកន្លែងស្អាតបាតទេ គឺជាកន្លែងដែលមានឈាមហូរដាបពាសពេញរាងកាយសាកសព ហើយជួនកាលមានខួរជនរងគ្រោះបែកចេញពាសវាលពាសកាល ។ ខ្មែរក្រហមមិនចាំបាច់ប្រើកាំភ្លើងក្នុងការសម្លាប់មនុស្សទេ គ្រាន់តែប្រើឈើមួយដុំយកមកវាយចំកន្លែងសំខាន់តែប៉ុណ្ណោះ ។

វាលពិឃាតមានចរិតប្រហាក់ប្រហែលនឹងឋាននរកដូច្នេះដែរ ។ នៅពេលខ្លះមុខរបស់ជនរងគ្រោះនៅជាប់ដោយក្រណាត់ចងមុខនៅឡើយ ។ ដៃរបស់ជនរងគ្រោះតែងតែត្រូវបានចងស្លាបសេកយ៉ាងតឹងម៉ឹង ហើយមានពេលខ្លះដៃជនរងគ្រោះត្រូវបាក់ដោយសារខ្មែរក្រហមចងរឹតតឹងពេក ។ រណ្តៅខ្លះមានសាកសពប្រមាណ២០០នាក់ ហើយមានខ្លះទៀតមានរហូតដល់៥០០នាក់ ។ សាកសពតែងតែត្រូវបានកប់ពាក់កណ្តាលខ្លួន ហើយពាក់កណ្តាលខ្លួនទៀតនៅហាលវាល ។ វាពិតជាសោកនាដកម្មយ៉ាងជាក់ស្តែង ។ ខ្ញុំមិនដែលជឿថារឿងនេះអាចកើតឡើងនៅក្នុងសម័យកាលទំនើបរបៀបនេះទេ ។ ប៉ុន្តែការពិតត្រូវបានកើតឡើងក្រោមស្នាដៃរបស់ខ្មែរក្រហម ។

ថ្ងៃមួយខ្ញុំឈរនៅកន្លែងកប់សាកសពជាមួយមិត្តរបស់ខ្ញុំឈ្មោះ ឡៃ នៅជាយទីកដីតាប៉ាង ។ ឡៃ និយាយមកកាន់ខ្ញុំទាំងទឹកភ្នែកហូររហាមថា “ឆ្អឹងទាំងអស់នេះក៏មានឆ្អឹងរបស់ឪពុកខ្ញុំដែរ” ។ ខ្ញុំក៏សួរ ឡៃ ថា “ធ្វើដូចម្តេចបានឯងដឹង?” ឡៃ និយាយយឺតៗមកកាន់ខ្ញុំថា “ពេលដែលខ្ញុំមកដល់ត្រពាំង អង្គការដឹងថាឪពុករបស់ខ្ញុំជាអ្នករដ្ឋការ ដូច្នេះហើយបានជាខ្មែរក្រហមយកគាត់ទៅជួបអង្គការលើជាមួយនឹងមនុស្សទាំងអស់នេះ (ឡៃបានចង្អុលទៅកាន់ផ្នូរខ្មោចទាំងអស់)” ។ ឡៃ ឈប់បន្តិចហើយនិយាយថា “ខ្ញុំដឹងថាអ្នកណាជាអ្នកសម្លាប់ពិតប្រាកដ” ។

ឪពុករបស់ ឡៃ និងអ្នកដទៃទៀតត្រូវបានសម្លាប់ដោយមិត្តចាស់រួមទាំងអតីតប្រធានឃុំនិងចៅហ្វាយក្រុងសព្វថ្ងៃនេះផង ក្រោយពេលដែលពីរនាក់នេះមកកាន់កាប់នៅភូមិតាប៉ាង ។ ប៉ុន្តែ ឡៃ មិនបានដឹងថាឪពុករបស់ខ្លួនស្លាប់ទេ ។ យូរក្រោយមកទៀតទើបគាត់បានដឹង ។ បន្ទាប់មកទៀត ឡៃ បានក្លាយជាអ្នកប្រសប់និយាយនិងជាជាងគំនូរទៀតផង ។ គាត់អាចធ្វើឲ្យប្រជាជនបំពេញការងារសំខាន់ៗក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ ។ ក្រោយពី ឡៃ បានរស់នៅតាប៉ាងមួយរយៈមកគាត់ក៏ចាប់ផ្តើមស្គាល់មិត្ត

ចាស់ជាច្រើនរូម ទាំងពេជ្ឈឃាតសម្លាប់ឪពុករបស់ខ្លួននិងអ្នកដទៃទៀត ។ មិនយូរប៉ុន្មាន ឡៃ ក៏បានឲ្យពេជ្ឈឃាតនោះនាំខ្លួនទៅកាន់វាលពិឃាតនោះ ។ មុនពេលខ្មែរក្រហមយក ឡៃ ទៅ ឡៃ បាននាំខ្ញុំទៅមើលកន្លែងគួរឲ្យខ្ពើមរអើមនេះ ។ ខ្ញុំមានកិត្តិយសណាស់ដែលបានចូលរួមរំលែកទុក្ខដល់ ឡៃ ។

រាល់ពេលដែលខ្ញុំស្គាល់ ឡៃ ពោលគឺក្នុងអំឡុង៣ឆ្នាំ គាត់បានបង្រៀនខ្ញុំជាច្រើនអំពីជីវិតនិងការរស់នៅក្នុងភូមិនេះ ។ ឥឡូវដល់ពេលដែលគាត់ត្រូវចាកចេញទៅហើយ ។ នេះគឺជាផែនការមួយទៀតដើម្បីសម្លាប់គ្រួសារអ្នករដ្ឋការ ។ មិត្តរបស់ខ្ញុំឈ្មោះ ឡៃ គឺជាមនុស្សម្នាក់ក្នុងចំណោមជនរងគ្រោះទាំងអស់នេះ ។

បីថ្ងៃក្រោយមក ខ្ញុំបានឮពត៌មានដ៏គួរឲ្យរន្ធត់មួយតាមរយៈមិត្តចាស់ (ប្រជាជនចាស់) ដែលជួយឲ្យក្រុមនេះឲ្យរត់គេចខ្លួន ។ ប្រជាជនចាស់និយាយថា «ឡៃ បានរត់គេចខ្លួនបាត់ហើយ» ។ ពេលឮដំណឹងនេះខ្ញុំមានអារម្មណ៍ក្តុកក្តួល ។ ពេលនោះខ្ញុំគិតថាគ្រួសាររបស់ ឡៃ និងអ្នកដទៃទៀតត្រូវបានសម្លាប់ ហើយប៉ុន្តែមាន ឡៃ ម្នាក់បានរត់រួចខ្លួន ។ កម្មាភិបាលនិងយោធាខ្មែរក្រហមចាប់ផ្តើមស៊ើបសួររកចាប់ខ្លួន ឡៃ ។ ខ្ញុំឮពាក្យចចាមអារ៉ាមថា ឡៃ បានវិលមកតាប៉ាងវិញហើយ ព្រមទាំងបានលាក់ខ្លួននៅក្នុងព្រៃនៅក្រៅភូមិនេះ ។ យោធាបាននិយាយថា ខ្លួនបានឃើញស្លឹកឈើមួយគរយ៉ាងក្រាស់ ។ ពេលនោះការតាមរកចាប់ខ្លួន ឡៃ ចេះតែបន្ត ។

ខ្ញុំជឿថាកាលពីពេលនោះនិងពេលឥឡូវ ឡៃ បានធ្វើឲ្យខ្មែរក្រហមរង្កៀសចិត្តហើយច្បាស់ជាត្រូវបានចាប់ខ្លួននិងសម្លាប់នៅទីងកន្លែងជាក់ជាមិនខាន ។ ឡៃ ជាព្រលឹងដ៏ក្លាហាន ។ ខ្ញុំបានបន់ស្រន់ដល់គាត់យ៉ាងអស់ពីចិត្តពីថ្លើម ។

មានព្រឹកមួយ មួយសប្តាហ៍បន្ទាប់ពីខ្មែរក្រហមស្វែងរក ឡៃ ក្រុមស្រាវជ្រាវតាមចាប់ខ្លួនបានត្រឡប់មកភូមិវិញដោយក្តីអំណររីករាយ ។ ពេលនោះខ្ញុំដឹងថាការរស់របស់ ឡៃ ដើម្បីសេរីភាពនិងជីវិតត្រូវបានបញ្ចប់យ៉ាងឃោរឃៅ ។ ខ្ញុំយំហើយយំទៀត ។ មិត្តសម្លាញ់បំផុតរបស់ខ្ញុំបានលាចាកលោកនេះទៅហើយត្រូវបានខ្មែរក្រហមដេញនិងកាប់សម្លាប់ដូចឆ្កែដូចឆ្មាអីចឹង ។ បើខ្ញុំអាចជួយគាត់បាន ខ្ញុំនឹងជួយមិនខាន ទោះបីជាវាជាការគ្រោះថ្នាក់ដល់ជីវិតខ្ញុំក៏ដោយ ។ សេចក្តីក្លាហាននិងព្រលឹងរបស់មិត្តសម្លាញ់ខ្ញុំនឹងស្ថិតជាប់នៅក្នុងរូបខ្ញុំអស់មួយជីវិត ។

ប៉ុន្មានសប្តាហ៍ក្រោយមក ពោលគឺនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៧ គ្រួសារមិត្តថ្មីផ្សេងទៀតនៅក្នុងភូមិតាប៉ាង និងគ្រួសារមួយចំនួនទៀតនៅជិតៗភូមិត្រូវបានប្រកាសឲ្យចាកចេញពីភូមិនេះ ។ អង្គការទុកពេលឲ្យយើងតែ៥ម៉ោងតែប៉ុណ្ណោះ ។ ការបញ្ជូនរបស់អង្គការនេះគឺរួមទាំងបងប្រុសរបស់ខ្ញុំនិងគ្រួសាររបស់ ឡៃ និងអ្នកដទៃៗទៀត ។ មានអ្នកខ្លះស្រែកយំក្រោយពីបានទទួលការប្រកាសនេះ ។ នៅក្នុងអារម្មណ៍ប្រជាជនម្នាក់ៗគិតថាខ្លួននឹងត្រូវបានសម្លាប់គ្រាន់តែយូរនឹងឆាប់តែប៉ុណ្ណោះ ។ ពេលវេលាបានមកដល់ ។ ប្រជាជនដែលជាមុខសញ្ញាពុំមានពេលគ្រប់គ្រាន់ដើម្បីវេចខ្ចប់របស់របរសំខាន់ៗទេ ។

ប្រជាជនក៏ចាប់ផ្តើមប្រមូលខ្ចប់ជាបង្វេចនូវរបស់របរកំប៉ិកកំប៉ុកដោយប្រញាប់ប្រញាល់បំផុតដើម្បីចាកចេញតាមបញ្ជារបស់អង្គការ ។ កម្មាភិបាលអង្គការបានប្រាប់ទៅអ្នករាល់គ្នាដែលជាមុខសញ្ញាថាកុំយករបស់របរទាំងអស់ធ្វើអ្វី ។ តាមការនិយាយរបស់កម្មាភិបាលខ្មែរក្រហមដែលថាឥវ៉ាន់និងរបស់របរផ្សេងៗនឹងយកទៅដល់កន្លែងដែលប្រជាជននឹងទៅដល់មិនមានការច្បាស់លាស់សោះឡើយ ។ ខ្ញុំចង់យករបស់របរដែលមានតម្លៃរបស់ខ្ញុំឲ្យអស់ ប៉ុន្តែមិនអាចទៅរួច ។ ខ្ញុំត្រូវធ្វើដំណើរដោយថ្មើរជើងនិងចងចាំយ៉ាងច្បាស់នូវការលំបាកពីអតីតកាល ។ ខ្ញុំបានចំណាយពេលរាប់ម៉ោងសម្លឹងមេមាន់ដែលខ្ញុំបានចិញ្ចឹម ។ នេះជារឿងមួយដែលខ្ញុំបានភ្ជាប់ទៅនឹងជីវិតរបស់ខ្ញុំជាមួយនឹងឪពុកម្តាយនិងបងប្អូននៅខេត្តសៀមរាប ។ ខ្ញុំមិនឃើញមេមាន់ពិសេសដែលបានផ្តល់ឲ្យខ្ញុំនូវស៊ុតនិងកូនជាច្រើននោះទេ ។ ទុក្ខសោកបានគ្រសោបអារម្មណ៍របស់ខ្ញុំនៅពេលដែលខ្ញុំចំណាយពេលវេលាដ៏មានប្រយោជន៍របស់ខ្ញុំរកមើលមេមាន់ដែលបាត់ទៅនោះ ។ ខ្ញុំមានអារម្មណ៍ជ្រួលច្របល់នៅពេលដែលខ្ញុំបាត់ត្រឹមតែសមាជិកគ្រួសារម្នាក់ប៉ុណ្ណោះ នៅពេលមានការកៀរប្រជាជនក្រោមក្រសែភ្នែករបស់ឆ្នាំប្រដាប់អាវុធខ្មែរក្រហម ។

**(នៅមានត)**

**យិមស៊ុត រ៉ាណាឌិត**

# សៀវភៅកំណត់ហេតុជីវិត

### (តពីលេខមុន) រូអឺ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៥

ឱជីវិតនៃខ្ញុំ! ក្នុងមួយជាតិនេះខ្ញុំប្រាថ្នាអ្វីមិនដែលបានសម្រេចទេ តើមកពីអ្វី? ស្នេហាមួយ ស្នេហាមានតែមួយតែខ្ញុំមិនសង្ឃឹមនឹងបានសម្រេច ចុះបើដឹងតាំងពីដើមដែរតើហេតុអ្វីនៅតែខំបង្កើតទៀត? ឱស្នេហាខ្ញុំដែលខ្ញុំបានសច្ចាថាស្រឡាញ់តែម្នាក់ឯងល្អឬអាក្រក់វាជាស្នេហាខ្ញុំ ខ្ញុំស្រឡាញ់តែម្តងស្រឡាញ់តែម្នាក់ បើបែរជាខកខានត្រូវខករហូត ខ្ញុំឥតមានស្តាយទេ ។ ស្រឡាញ់បងម្នាក់ដែលក្នុងចិត្តមិនសង្ឃឹមថាបានជួបសោះតែនៅតែស្រឡាញ់ ស្រឡាញ់ព្រោះអាណិត ព្រោះបងមានរឿងក្នុងគ្រួសារ ចង់យកខ្លួនទៅផ្សះផ្សារឿងប្រេះឆានេះ ទោះបីខ្លួនយល់ថាជាការពិបាកក៏ដោយ ។ បងម្នាក់ធ្វើឲ្យខ្ញុំគិត ខ្ញុំព្រួយ បេះដូងប្រេះឆាដោយសេចក្តីអាណិត ចង់ជួយ តើស្នេហាខ្ញុំជាការយល់ច្រឡំឬយ៉ាងណា? ទោះជាការយល់ច្រឡំក៏វាជាស្នេហាខ្ញុំ ជាការសម្រេចចិត្តរបស់ខ្ញុំ ។ តើយើងអាចជួបគ្នាឬទេ? តើបងមានស្រឡាញ់ខ្ញុំដូចខ្ញុំស្រឡាញ់បងឬទេ? គ្រាម្តងដែលខ្ញុំបានសម្រេចចិត្តរួចហើយ ការស្តីដណ្តឹងផ្សេងៗទៀតទោះជាមានលក្ខណៈល្អជាងបងមួយរយពាន់ដងក៏គ្មានតម្លៃសម្រាប់ខ្ញុំដែរ គឺស្រឡាញ់តែមួយគឺចប់ ។ បើមិនជួបគ្នាទេក៏អារម្មណ៍មិនវិលវល់ដែរ ថ្វីត្បិតតែស្នេហាខ្ញុំមានទំហំធំក៏ដោយ ។ ឱស្នេហា ផុតក្តីសង្ឃឹម! ពីព្រោះយើងនៅឆ្ងាយពីគ្នាពេកក្រៃ ។ តែមិនដឹងឥឡូវបងសុខទុក្ខយ៉ាងណា ចិត្តប្រែប្រួលដូចម្តេច? តែខ្ញុំនៅតែដដែលគ្មានប្រែប្រួល ។ ឱស្នេហាខ្ញុំ!

### រូអឺ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៥

ឱ! ធាតុអាកាសត្រជាក់ណាស់ ត្រជាក់ណាស់ ខ្ញុំត្រឡប់មកពីរៀនវិញដើរស្ទើរនឹងដួលព្រោះធាតុអាកាសត្រជាក់ពេក ខ្ញុំពាក់អាវមិនគ្រប់គ្រាន់ ឱ! ធាតុអាកាសនៅរាល់រដូវរងាខ្ញុំតែងមានរឿងប្រេះឆាក្នុងជីវិតជានិច្ច រឿងរ៉ាវទាំងឡាយហាក់ដិតជាប់ជានិច្ចក្នុងគំនិតគិតអ្វីមិនយល់មានបងមួយធ្វើឲ្យព្រួយរហូតគ្មានពេលរសាយ តើកម្មអ្វីក៏អាក្រក់ម្ល៉េះជាតិនេះ ឥឡូវប្តេជ្ញាចិត្តថាត្រឡប់ទៅវិញសាងជីវិតថ្មីទោះជាលំបាកយ៉ាងណាក៏ដោយ ត្រូវតែត្រឡប់ទៅវិញជាដាច់ខាត ជួបម៉ែជាទីស្រឡាញ់ ជាឪពុកជាទីគោរព ការព្រាត់ប្រាសនិរាសជាយូរ កូននឹកៗលោកទាំងពីរណាស់ ជីវិតពោរពេញដោយគ្រោះកាចចង្រៃ ព្រាត់ប្រាសពីម្តាយឪពុកជាទីស្រឡាញ់ ព្រាត់ប្រាសស្នេហាដែលទើបតែដុះពន្លក ខាតបង់ចំណេះវិជ្ជាដែលជាទីស្រឡាញ់ មានបងមួយដែលគេទាំងអស់គ្នាគ្មានដូច ។ ឱជីវិតដ៏ខុសគេ! តើថ្ងៃស្អែកជីវិត ខ្ញុំប្រែប្រួលទៅជាយ៉ាងណាទៀត ស្អែកទឹកភ្នែកតទៅទៀតឬស្អែកសប្បាយ ឬស្អែកក្លាយជារឿងសោកសង្រេង ឬជាភ្លេងមរណៈ ឱ!តើនរណាអាចដឹងបានពីសភាពការណ៍នៃថ្ងៃស្អែក? ហ៊ឹះ នៅសល់តែសេចក្តីផុតសង្ឃឹមគ្រប់ផ្លូវមិនដឹងថ្ងៃណាទើបអាចឆ្លងផុតពីទុក្ខទាំងនេះ តែហាក់ដូចជាគ្មានសង្ឃឹម បើថ្ងៃនៅតែរះដីនៅតែដើរ ជីវិតនៅតែមានទោះទុក្ខនៅតែមាន ឱជីវិតឥតន័យ! ដូចដើមឈើដែលឥតស្លឹកនៅរដូវត្រជាក់ដូច្នេះឯង ។

### រូអឺ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៥

ថ្ងៃនេះជាថ្ងៃពុធ ជាថ្ងៃបុណ្យណូអែល ជាថ្ងៃ២៤ណូអែលចុងក្រោយបំផុតដែលខ្ញុំបានចូលរួមនៅក្នុងរយៈពេលដែលខ្ញុំស្នាក់នៅប៉ារីស ។ ថ្ងៃនេះខ្ញុំគេងនៅម៉ោង២ព្រឹកបានធ្វើឲ្យខ្ញុំស្គាល់នូវជីវិតបន្តរបស់ពួកបារាំងថ្នាក់ខ្ពស់នៅពេលណូអែល ។ ជីវិតមួយដែលស្គាល់តែភាពហ៊ឺហារនៃពួកអ្នកមាននៃពួកដែលគេហៅថាសេដ្ឋី។ រាត្រីនេះមិនជាធ្វើឲ្យខ្ញុំសប្បាយចិត្តទេព្រោះហត់ហេវណាស់ ។

### រូអឺ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៥

រសៀលថ្ងៃនេះខ្ញុំបានទៅមើលកុនមួយឈ្មោះថា Le 3 Jours du Codois ដែលបង្ហាញនូវជីវិតនិងគោលបំណងនៃពួកសេ.អ៊ី.អា មានតែការកាប់សម្លាប់ ដើម្បីប្រយោជន៍ផ្ទាល់របស់

កុនមួយ ទៅមើលតែឯង នេះជាលើកទី១ ហើយដែលខ្ញុំទៅមើលកុនតែឯង រួចហើយខ្ញុំទៅផ្ទះចិក ស៊ុន ហ្វួន ជជែកពីរឿងស្រុកទេស ។

### ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៥

រំឭកឡើងវិញនូវអនុស្សាវរីយ៍គ្រោតគ្រាតដែលជារឿងនាំឲ្យខ្ញុំមានការរការកែកូសជាមួយបងជាថ្មី ។ រឿងកើតនៅថ្ងៃសៅរ៍ទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ក្រោយពេលដែលខ្ញុំជួប ពៅ ញាំបាយល្ងាចរួចខ្ញុំមើលរឿង *Flût Euclonbi* នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ (ថ្ងៃសុក្រ) ជាមួយ បូផា អំពីរឿងមិនសប្បាយចិត្តរបស់បងសម្លាញ់ខ្ញុំ ។ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ (ថ្ងៃច័ន្ទ) បងសម្លាញ់គេឡេហ្វូនមកស្តីឲ្យខ្ញុំទៀត ស្រក់ទឹកភ្នែកទាំងយប់ ។ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៥ ខ្ញុំធ្វើដំណើរសាជាថ្មីទៅផ្ទះបងសម្លាញ់ជាមួយ រិទ្ធ នឹកថានឹងផ្សះផ្សាជាថ្មីរឿងដែលប្រេះឆារួចទៅហើយឲ្យជាឡើងវិញ តែផ្ទុយទៅវិញរឹតធ្ងន់ជាងការដែលខ្ញុំស្មានធ្វើឲ្យខ្ញុំសម្រេចចិត្តថានឹងឈប់ទៅជួបរហូតដើម្បីឲ្យគេបំភ្លេចខ្ញុំចោល កុំឲ្យមានទុក្ខដោយសារខ្ញុំ ហើយសម្រេចចិត្តជាឯកច្ឆ័ន្ទដោយគ្មានរារែកចំពោះគំនិតអ្នកណាទៀត ត្រូវតែត្រឡប់ទៅស្រុកវិញក្នុងពេលយ៉ាងឆាប់បំផុត ។ បងមួយដែលខ្ញុំមិនស្មានថាមានចិត្តដល់ម្ល៉ឹង អ្វីៗខ្ញុំសុខចិត្តចាញ់គ្រប់ផ្លូវ តែលើកនេះគឺខ្ញុំឆ្អែតចិត្តហួសប្រមាណទៅហើយ បើសិនជាខ្ញុំខុសក៏ដោយខ្ញុំត្រូវតែធ្វើយ៉ាងនេះដើម្បីឲ្យដឹងខ្លួនខ្លះ ។

ជាងមួយខែហើយដែលខ្ញុំមិនដែលបានជួប បូផា សោះ ។ បានស្គាល់មិត្តម្នាក់ដែលមានចិត្តដែលខ្ញុំមិនអាចស្មានត្រូវ ។ ជាតិនេះខ្ញុំរកមិនបានទេមិត្តដែលមានចិត្តដូចខ្ញុំ ។ គ្មានទេ រកមិនបានទេកល្យាណមិត្ត ។ ឱ! ជីវិតដែលស្គាល់តែការប្រេះឆាគ្រប់កន្លែងអ្វីដែលគេទាំងអស់គ្នាស្មានថាល្អសម្រាប់រូបខ្ញុំសុទ្ធតែជារឿងក្តៅក្រហាយខ្លោចផ្សានិងវីងវៃទាំងអស់ ។

### ថ្ងៃអាទិត្យ ទី២៨ ខែធ្នូ ឆ្នាំ១៩៧៥

ឱជីវិត!

ថ្ងៃនេះខ្ញុំមើលកុនមួយឈ្មោះថា *Lime Light: Les feuse des sampes* ។ ជាកុនអង់គ្លេសដែលកើតនៅទីក្រុងឡុងដ៍ក្នុងឆ្នាំ១៩១៤ កុននេះបង្ហាញពីជីវភាពនៃអ្នករបាំនិងអ្នកកំប្លែងពីរនាក់ ។ គំនិតចម្បងនៃកុននេះគឺថាដើម្បីយកជ័យជំនះលើអ្វីមួយត្រូវមានសេចក្តីក្លាហាន ការស្ម័គ្រចិត្ត និងចិត្តអំណត់ ទីបំផុតនោះគោលបំណងនឹងបានសម្រេច និងបង្ហាញនូវសេចក្តីស្នេហាមួយដែលកើតឡើងអំពីការដឹងគុណ អាណិតស្រឡាញ់ ព្រោះគេបានធ្វើអំពើល្អដល់ខ្លួនច្រើនពេក ស្នេហាដែលមិនអាចលេចចេញជារូបរាងបានព្រោះតួប្រុសយល់ថាខ្លួនជាមនុស្សចាស់ ទោះបីនាងសុខចិត្តស្រឡាញ់ខ្លួនយ៉ាងណាក៏ដោយ ។ មនុស្សម្នាក់អាចឲ្យដំបូន្មានគេឲ្យធ្វើតាមគំនិតរបស់ខ្លួនដើម្បីឲ្យអ្នកដែលខ្លួនយល់ថាយល់ខុសឲ្យត្រឡប់មកត្រង់ផ្លូវវិញបាន តែចំពោះខ្លួនឯងគេពិបាកនឹងគោរពនិងពុះពារធ្វើតាមទ្រឹស្តីរបស់ខ្លួនដែលប្រាប់ឲ្យគេធ្វើតាមណាស់ ។

### រូអឺ ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦

ឱ! អ្នកម៉ែពុកជាទីរឭកនិងជាទីគោរព តើលោកទាំងពីរមានសុខទុក្ខយ៉ាងណា? កូនតែងនឹករឭកទៅលោកជានិច្ច ហើយកូនសម្រេចចិត្តថានឹងត្រឡប់ទៅស្រុកវិញក្នុងពេលឆាប់ៗនេះ ដើម្បីឲ្យបានជួបលោកទាំងពីរបានចូលរួមក្នុងការកសាងប្រទេសជាថ្មី ។ កូនខុស កូនព្រួយគ្មានល្ហែដល់លោកទាំងពីរ ។ ការដើរលេងរបស់កូនមានគំនិត២ឆ្នាំចាត់ទុកថាជាការចប់សព្វគ្រប់ហើយ កូនសែនរីករាយនឹងត្រឡប់ទៅវិញណាស់ ។ កូនតែងរឭកនឹកឃើញពាក្យប្រៀនប្រដៅរបស់ម៉ែ រាល់ៗពេលវេលាថ្វីត្បិតតែកូននៅឆ្ងាយៗពីម៉ែ តែគំនិតម៉ែគុណសម្បត្តិរបស់ម៉ែនៅជាប់នឹងកូនជានិច្ច ។ ហើយកូនតែងគិតហើយចិញ្ចឹមចិត្តថាត្រូវតែត្រឡប់ទៅវិញជាដាច់ខាត ។ ឱម៉ែជាទីស្រឡាញ់! ពាក្យសម្តីរបស់ម៉ែពេញជាត្រូវណាស់ បងមួយធ្វើឲ្យកូនព្រួយរហូតព្រួយលែងរៀនកើត គឺព្រួយក្តៅក្រហាយរហូតគ្មានថ្ងៃចប់ ។ កូនត្រូវតែត្រឡប់ទៅវិញ ។ **(នៅមានត)**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigpond.com.kh

***(តមកពីទំព័រទី៥)*** ព្រមានមិនឲ្យប្រព្រឹត្តខុសសីលធម៌និងបទឧក្រិដ្ឋផ្លូវភេទយ៉ាងណាក៏ដោយ ក៏កម្មាភិបាលខ្មែរក្រហមទាំងនោះនៅតែបន្តទាញយកផលប្រយោជន៍ពីស្ត្រីជាធម្មតា ព្រោះបានដឹងថាខ្លួនអាចគេចផុតពីការដាក់ពិន័យឬទណ្ឌកម្ម ។ ទោះបីជាអ្នកមីង (ស៊ាន ផាន) មិនដែលត្រូវបានរំលោភបំពានលើផ្លូវភេទ នៅពេលដែលគាត់ជាប់នៅមន្ទីរសន្តិសុខកោះគរក៏ដោយ ក៏មានស្ត្រីក្មេងៗជាច្រើនទៀតត្រូវបានបោកបញ្ឆោតហើយចាប់រំលោភនិងសម្លាប់ដោយអ្នកយាមមន្ទីរសន្តិសុខនៅទីនោះ ។

*"ខ្មែរក្រហមចាប់រំលោភស្ត្រីក្មេងៗ រួចហើយច្រានទម្លាក់ទៅក្នុងទឹក ។ ខ្មែរក្រហមជ្រើសរើសស្ត្រីក្មេងដែលស្អាតៗ ។ ខ្មែរក្រហមស្រឡាញ់ស្ត្រីក្មេងៗ ហើយស្ត្រីក្មេងទាំងនោះមិនដឹងខ្លួនទេ ។ ស្ត្រីក្មេងៗនោះស្មោះត្រង់រួចគិតថាកម្មាភិបាលខ្មែរក្រហមទាំងនោះអាណិតខ្លួន ហើយស្រឡាញ់ខ្លួនយ៉ាងពិតប្រាកដ ។ ដូច្នោះស្ត្រីទាំងនោះបានធ្វើតាមខ្មែរក្រហមដោយមិនដឹងថារឿងបែបនោះនឹងកើតឡើង ។ ប្រសិនបើខ្មែរក្រហមមិនសម្លាប់ស្ត្រីទាំងនោះចោល គឺកម្មាភិបាលខ្មែរក្រហមមិនអាចបំផ្លាញភ័ស្តុតាងបានទេ ។ ដូច្នោះកម្មាភិបាលទាំងនោះនឹងត្រូវទទួលពិន័យ" ។*

យោងទៅតាម អ្នកមីង (ចាន់ សាន) ការប្រព្រឹត្តខុសសីលធម៌គឺជាទោសក្បត់ប្រឆាំងនឹងរបបខ្មែរក្រហម ដូច្នោះហើយបានជាមានការព្យាយាមលាក់ឲ្យផុតពីភ្នែកអង្គការ ។ នៅពេលដែលអ្នកមីង (ចាន់ សាន) ជាប់ឃុំឃាំងនៅមន្ទីរ១៥ ស្ត្រីវ័យក្មេងៗដែលជាប់ នៅទីនោះត្រូវបានរំលោភរហូតដល់មានផ្ទៃពោះ ។ បន្ទាប់មកស្ត្រីទាំងនោះត្រូវបានកម្ទេចចោលដើម្បីបំផ្លាញភ័ស្តុតាង ។ ធ្វើដូចនេះអ្នកយាមមន្ទីរសន្តិសុខអាចរក្សាអាថ៌កំបាំងបាន ។

*"ខ្មែរក្រហមទាំងនេះប្រហែលជាព្យាយាមលាក់មិនឲ្យថ្នាក់លើដឹងអំពីរឿងនេះ ពីព្រោះនៅមន្ទីរ១៥ មានយុទ្ធជន ១០នាក់ដែលជាអ្នកយាមពួកខ្ញុំ ដូច្នោះវាមានការងាយស្រួលសម្រាប់កម្មាភិបាលខ្មែរក្រហមដើម្បីលាក់បំបាំងនូវអ្វីដែលខ្លួនបានធ្វើ ។ គ្មានអ្នកណាចេញចូលទេ" ។*

អ្នកមីង (ដា ជាតិ) ដែលត្រូវបានយកទៅដាក់នៅកងស្ត្រីមេម៉ាយ បន្ទាប់ពីប្តីរបស់គាត់ត្រូវបានសម្លាប់ បានឃើញការឈឺចាប់របស់ស្ត្រីដែលត្រូវបានរំលោភដោយប្រធានសហករណ៍ ។

*"នៅពេលយប់ប្រធានសហករណ៍ បានដើរគោបសន្តត់ខ្ញុំដោយដឹងថាខ្ញុំជាអ្នក១៧ មេសា ។ ដូច្នោះនៅពេលយប់ខ្មែរក្រហមដើរយាមពួកខ្ញុំ ។ ប៉ុន្តែកម្មាភិបាលខិលខូចណាស់ ព្រោះធាតុពិតគឺដើរមើលរកស្ត្រីស្អាតៗហើយចាប់រំលោភ ។ នៅពេលយប់ពួកខ្ញុំដាក់កាំបិតនិងពូថៅនៅក្បែរខ្លួន ។ ម្នាក់ៗខ្លាចខ្មែរក្រហមគ្រប់ៗគ្នា" ។*

ទោះបីជាកម្មាភិបាលខ្មែរក្រហមត្រូវបានហាមប្រាមមិនឲ្យរំលោភបំពានផ្លូវភេទទៅលើស្ត្រីក៏ដោយ អ្នកមីង (ដា ជាតិ) ជឿជាក់ថាប្រធានសហករណ៍នៅតែបន្តទោសឧក្រិដ្ឋនេះពីព្រោះដឹងថាខ្លួនអាចគេចផុតពីការដាក់ពិន័យ ។

កម្មាភិបាលខ្មែរក្រហមមានអំណាចយ៉ាងខ្លាំងទៅលើស្ត្រីដែលខ្លួនបានបំពានលើផ្លូវភេទ ឬចាប់រំលោភរួច ។ កម្មាភិបាលខ្មែរក្រហមដឹងថាស្ត្រីទាំងនោះត្រូវបានគំរាមកំហែងដោយដាក់ពិន័យឬក៏កម្ទេចចោល ប្រសិនបើស្ត្រីទាំងនោះហ៊ានលាតត្រដាងទោសឧក្រិដ្ឋនោះទៅថ្នាក់ដឹកនាំខាងលើ ។ អ្នកមីង (សាំង ហេង) ចងចាំថានៅពេលដែលគាត់នៅកោះខ្សាច់ជន្លា មានស្ត្រីមួយចំនួនព្យាយាមចង់បានការគាំទ្រពីប្រធានកង ដោយសង្ឃឹមថាការបង្កើតទំនាក់ទំនងខាងផ្លូវភេទជាមួយប្រធានកងទាំងនោះនឹងធ្វើឲ្យជីវិតរបស់ខ្លួនមានភាពងាយស្រួល ។ បន្ទាប់ពីបានរំលោភរួចហើយ ស្ត្រីទាំងនោះមិនហ៊ានរាយការណ៍ទៅឲ្យថ្នាក់លើដោយក្តីភ័យខ្លាចថា ខ្លួននឹងត្រូវពិន័យឬកម្ទេចចោល ។

*"ខ្ញុំឃើញកម្មាភិបាលខ្មែរក្រហម ហើយខ្ញុំចង់បានការគាំទ្រពីកម្មាភិបាលខ្មែរក្រហម ។ ប្រសិនបើខ្មែរក្រហមចង់រំលោភខ្ញុំ ខ្ញុំមិនហ៊ាននិយាយអ្វីទេ ។ ប្រសិនបើខ្ញុំហ៊ាននិយាយអ្វី ខ្មែរក្រហមនឹងយកខ្ញុំទៅសម្លាប់ ។ ដូច្នោះខ្ញុំមិនហ៊ាននិយាយស្អីទេ ហើយខ្ញុំត្រូវធ្វើតាមខ្មែរក្រហមទាំងនោះ" ។*

ច្បាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានការចោទប្រកាន់និងដាក់ពិន័យដល់ជនណាដែលបានប្រព្រឹត្តខុសសីលធម៌ ។ ជនរងគ្រោះដឹងថាប្រសិនបើខ្លួនប្តឹងផ្តល់ពីអ្នកចាប់រំលោភខ្លួនក៏ដូចប្តឹងចោទប្រកាន់ខ្លួនឯងដែរ ហើយប្រថុយនិងការយកទៅ

កម្ទេចចោលដូចអ្នកចាប់រំលោភខ្លួន ។ អ្នកមីង (អ៊ូច ចាន់ថា) ដែលជាសមាជិកកងស្រ្តីវ័យក្មេងក៏ជាសាក្សីរឿងរ៉ាវដែលបានកើតឡើងចំពោះមិត្តសម្លាញ់របស់គាត់ដែលបានខំលាក់អាថ៌កំបាំង ។

*«ពេលនោះគាត់ (មិត្តសម្លាញ់អ្នកមីងចាន់ថា) កំពុងតែដើរទៅយកបាយ ស្រាប់តែឈ្លបក៏មករំលោភគាត់ ។ ក្រោយមកខ្មែរក្រហមក៏ប្រាប់គាត់ថា បើគាត់ប្រាប់អ្នកការគាត់ត្រូវស្លាប់ ។ មនុស្សតែងតែចង់ប្រាប់មិត្តភក្តិរបស់ខ្លួន ។ ដូច្នោះខ្មែរក្រហមក៏បាញ់សម្លាប់គាត់តែម្តង ។ ប្រសិនបើគាត់មិនប្រាប់ទេ គាត់មិនស្លាប់ទេ ។ ខ្មែរក្រហមគ្រាន់តែរំលោភគាត់តែប៉ុណ្ណោះ ។ ប្រសិនបើគាត់នៅស្ងៀម គាត់មិនស្លាប់ទេ ប៉ុន្តែគាត់រាយការណ៍អំពីកម្មាភិបាលដែលបានរំលោភគាត់ ហើយគាត់ប្រាប់មិត្តភក្តិរបស់គាត់ ដូច្នោះខ្មែរក្រហមនោះក៏សម្លាប់គាត់ចោលទៅ»* ។

ឈ្លប (ខ្មែរក្រហម) នោះបានសម្លាប់មត្តិភក្តិរបស់អ្នកមីង (អ៊ូច ចាន់ថា) ដើម្បីបំផ្លាញភ័ស្តុតាងចោទប្រកាន់ ។ ច្បាប់បង្កើតឡើងយ៉ាងរបៀបនេះដែលធ្វើឲ្យស្រ្តីគ្មានអ្វីដើម្បីនិយាយ ហើយកម្មាភិបាលខ្មែរក្រហមគ្មានអ្វីត្រូវបាត់បង់ក្នុងការសម្លាប់ស្រ្តីជនរងគ្រោះ ។ ប្រសិនបើមនុស្សពីរនាក់ប្រព្រឹត្តខុសសីលធម៌មិនទាក់ទងថាតើដោយស្ម័គ្រចិត្ត ឬដោយបង្ខំទេ ទាំងបុរសទាំងស្រ្តីត្រូវកម្ទេចចោលទាំងពីរនាក់ ។ ប៉ុន្តែបើតាមអ្នកមីង (ជា សាន) ជាទូទៅស្រ្តីត្រូវបានបង្ខំឲ្យនៅស្ងៀម ។

*«ស្ទើរតែគ្រប់ពេលដែលខ្មែរក្រហមរំលោភស្រ្តីម្តង ឬក៏ពីរដង ស្រ្តីទាំងអស់ធ្វើពុតជាគ្មានរឿងអ្វីកើតឡើង ។ យើងមិនហ៊ានធ្វើអ្វីទាំងអស់ គ្មាននណាម្នាក់ប្តឹងតវ៉ាអ្វីទេ ។ ប្រសិនបើអ្នកប្តឹង ហើយអ្នកនៅរស់នោះគឺជារឿងអស្ចារ្យណាស់ ។ ប៉ុន្តែប្រសិនបើអ្នកណាហ៊ានប្តឹងរឿងពិតគឺអ្នកនោះនឹងស្លាប់ទាំងពីរនាក់»* ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ច្បាប់ដែលតាក់តែងឡើងដើម្បីហាមប្រាមសកម្មភាពផ្លូវភេទ ប៉ុន្តែបែរជាជំរុញឲ្យមានការរំលោភបំពានផ្លូវភេទទៅវិញ ។ ការគ្មានសមត្ថភាពដើម្បីទាមទារសិទ្ធិរបស់ខ្លួនបាន ស្រ្តីទាំងនោះយល់ថាខ្លួនគឺជាកម្មសិទ្ធិរបស់ខ្មែរក្រហមដែលស្ថិតនៅក្នុងដៃបិសាចពីរដែលមិនអាចគេចផុត ។ ស្រ្តីទាំងនោះអាចជ្រើសរើសយកផ្លូវ «នៅស្ងៀមមិនមាត់ក» ឬក៏ «ប្រថុយប្រថាននឹងការយកទៅកម្ទេចចោល» ។

មានស្រ្តីមួយចំនួនដែលខ្ញុំបានជួបសម្ភាសន៍បានទទួលស្គាល់ថាមានទោសខក្រិដ្ឋផ្លូវភេទបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែរួមរក្សមុនពេលរៀបការត្រូវបានហាមឃាត់ ហើយត្រូវបានពិន័យយ៉ាងធ្ងន់ធ្ងរ ។ មានស្រ្តីជាច្រើនសន្មតថាគ្មានទោសខក្រិដ្ឋផ្លូវភេទកើតឡើងទេ ។ តែទោះជាយ៉ាងណាក៏ដោយ បើយោងតាមការសិក្សាទៅលើបទសម្ភាសន៍បានបង្ហាញថា ទោសខក្រិដផ្លូវភេទ ពិតជាមានមែន ពីព្រោះជនរងគ្រោះជាទូទៅត្រូវបានកម្ទេចចោលក្រោយពេលត្រូវបានរំលោភ ហើយជនរងគ្រោះទាំងនេះមិនមានជីវិតរស់នៅដើម្បីនិយាយរឿងរ៉ាវរបស់ខ្លួន ។ ប៉ុន្តែនៅមានសាក្សីដែលនៅមានជីវិតរស់នៅដើម្បីបង្ហាញថាទោះបីជាការចាប់រំលោភមិនមែនកើតឡើងក្នុងលក្ខណៈជាប្រព័ន្ធដែលដាក់ចេញដោយរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏ច្បាប់នេះបានតាក់តែងឡើងដោយរដ្ឋអំណាចនៃសង្គមមួយដែលបណ្តោយឲ្យសមាជិករបស់ខ្លួនប្រព្រឹត្តទោសខក្រិដ្ឋហើយបិទបាំងការពិតទាំងស្រុង ។

**ម៉ម កល្យាណី**


ថោង ថា


ពត ឡូន


តូច សែ


ប៊ុន ជីង

# ហួត បុប្ផាណា




ថ្ងៃចាប់ ១២.១០.១៩៧៦

ថ្ងៃកម្ទេច ១៨.៣.១៩៧៧


ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.



A magazine of the Documentation Center of Cambodia: Searching for the Truth! Number 15, March 2001.

Funded by the Royal Ministry of Foreign Affairs,Oslo, Norway, Section for the Human Rights and Humanitarian Assistance; the Canada Funds, Canadian Embassy,Phnom Penh; the Swedish International Development Cooperation Agency (Sida), Embassy of Sweden, Phnom Penh; the Royal Danish Government and the Royal Netherlands Government, *The Hague*.